ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- យុត្តិធម៌ និងការចងចាំពីសម័យខ្មែរក្រហមដើម្បីសិទ្ធិមនុស្ស
- ហេតុអ្វីបានអំពើប្រល័យពូជសាសន៍នៅតែបន្តកើតមាន?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២២៨ ខែធ្នូ ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២២៨ ខែធ្នូ ឆ្នាំ២០១៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


### សំបុត្រ

◆ យុត្តិធម៌ និងការចងចាំពីសម័យខ្មែរក្រហមដើម្បីសិទ្ធិមនុស្ស........១

### ផ្នែកឯកសារ

◆ ចម្លើយសារភាពរបស់ វឿង ង៉ុកស៊ន់ អតីតកងទ័ពវៀតណាម...... ៨

◆ ត្រិន ង៉ុកតឿង ភ្នាក់ងារចារកម្មវៀតណាម ........................ ១១

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ស្នួររថភ្លើង រំឭកដល់អនុស្សាវរីយ៍ពីអតីតកាលរបស់ខ្ញុំ............ ១៥

◆ ប្រជាជនរស់នៅស្រុកអន្លង់វែង រៀបរាប់ពីបទពិសោធន៍ .......... ១៨

◆ ផ្កា «ខេមីលា» ជាតំណាងឲ្យសន្តិភាព យុត្តិធម៌..................... ២៤

◆ កូនខ្ញុំឈ្មោះ សៅ រី ស្លាប់ដោយសារកើតកញ្ជ្រឹល ................. ២៦

◆ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺ និងព្រួយចិត្តបែកពីកូន......... ២៩

### ផ្នែកច្បាប់

◆ ដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហម........................៣២

◆ សំណុំរឿង០០៣ ទាក់ទងនឹង មាស មុត ........................... ៣៦

### វេទិកាពិភាក្សាសាធារណៈ

◆ ហេតុអ្វីបានអំពើប្រល័យពូជសាសន៍នៅតែបន្តកើតមាន? ......... ៤២

◆ ពិព័រណ៍សហសម័យ៖ «ប្រសិនបើមិនមានសង្គ្រាម................៤៤

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៤៩

◆ កូវ ជ័រ ៖ ពលទាហាន ..............................................៥៣

◆ ខ្ញុំនៅតែចង់ដឹងពីដោគវាសនាពូរបស់ខ្ញុំ................................៥៥

◆ អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ ...........................................៥៨






## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ៣៧៥ ព.មប្រក

ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨


រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា


***ស្នេរលេខនេះ៖*** *ឆាំង យុ,យី សុឃី,សូវិចិត្រ មេត្តា,អ៊ុន សុដារី,សាន ធីតា,សុន ស្រីពេជ្រ,វ៉ាន់ថាន់ ពៅដារ៉ា,ឡុង ដានី,ប៊ាង ពីរ័ន្ត,វេនី ខកហ្កៀល និង គ្រាន ម៉ូនីកា* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *អ៊ុន សុដារី, ដារ៉ារដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *អ៊ុន សុដារី* ***ចាងហ្វាង និងនិពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ថុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គីម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វើង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# យុត្តិធម៌ និងការចងចាំពីសម័យខ្មែរក្រហមដើម្បីសិទ្ធិមនុស្ស

រយៈពេល៤០ឆ្នាំ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ប្រទេសកម្ពុជានៅតែបន្ត ព្យាយាមដោះស្រាយជាមួយនឹងកេរដំណែលដ៏សោកសៅនៃអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅទ្រង់ទ្រាយធំ។ ស្នាមរបួសជាច្រើនដែលបានបន្សល់ទុកពីសម័យ ប៉ុល ពត មិនទាន់បានជាសះស្បើយនៅឡើយ។ ក្នុងខណៈពេលដែលមានការបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០១៨ ទំនាស់នយោបាយដ៏ជូរចត់នៅតែកើតមានឡើងចំពោះរាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្នដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការដឹកនាំប្រទេស ជំនួសឲ្យមេដឹកនាំរបបខ្មែរក្រហម។ ភាពបែកបាក់រវាងសង្គម និងនយោបាយនៅតែមានភាពស៊ីជម្រៅ រីឯតម្រូវការនៃភាពយុត្តិធម៌នៅតែបន្ត ចំណែកការផ្សះផ្សាជាតិ នៅមិនទាន់ខិតជិតទៅរកភាពជោគជ័យនៅឡើយ។ ការកាត់ក្តីនៅក្នុងតុលាការខ្មែរក្រហម គឺជាជំហានមួយដ៏សំខាន់បំផុត ប៉ុន្តែ ការផ្តន្ទាទោសអតីតមេដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហម មានតែ៣រូបតែប៉ុណ្ណោះ រួមមានៈ ឌុច ប្រធានមន្ទីរសន្តិសុខស២១ ដែលទទួលខុសត្រូវលើជីវិតអ្នកទោសប្រមាណ ១ម៉ឺន ៨ពាន់នាក់ ត្រូវបានកាត់ទោសជាប់ពន្ធនាគារអស់មួយជីវិត នៅថ្ងៃសុក្រ ទី៣ ខែកុម្ភៈ ឆ្នាំ២០១២។ នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ តុលាការខ្មែរក្រហមបានសម្រេចផ្តន្ទាទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលកំពុងរស់រានមានជីវិត រួមមាន នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានប្រព្រឹត្តនៅតាមទីកន្លែងនានានៅទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះបានសម្រេចផ្តន្ទាទោស នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារ


ប្រជាជនចូលរួមស្តាប់សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម

អស់មួយជីវិត។ ទោះបីជាយ៉ាងនេះក៏ដោយ នៅមិនទាន់បានដោះស្រាយចំពោះភាពអយុត្តិធម៌និងកេរដំណែល ដែលបានបន្សល់ទុកដោយច្បាប់គ្រប់គ្រងប្រទេសរបស់មេដឹកនាំ ក្នុងរបបខ្មែរក្រហម។

នៅរវាង ឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងប្រកាន់ខ្ជាប់នូវបេសកកម្មដ៏យូរអង្វែងរបស់ខ្លួនក្នុងការលើកកម្ពស់ដល់ការចងចាំ យុត្តិធម៌ និងការផ្សះផ្សា។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងប្រមូលចងក្រងប្រទេសកម្ពុជា។ គម្រោងយុទ្ធសាស្រ្តសង្ខេបនេះ បង្ហាញអំពីជំហានបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចូលរួមចំណែកដោះស្រាយទៅលើស្រមោលអន្ធការនៃភាពតក់ស្លុតដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងប្រែក្លាយសង្គមកម្ពុជាឲ្យមានអនាគតភ្លឺស្វាងឡើងវិញ។

១) កេរដំណែលជាក់ស្តែង

*ការសាងសង់នូវមជ្ឈមណ្ឌលស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍អចិន្ត្រៃយ៍*



*រូបខាងស្តាំ៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក អេនឌ្រូ ខេលី សហព្រះរាជអន្តរជាតិ រួមជាមួយលោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិនៃសាលាក្តីខ្មែរក្រហម នៅក្នុងពិធីសម្ពាធពាក្យស្ងោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅវិទ្យាល័យតូរទេវី។*

ភ័ស្តុតាងប្រវត្តិសាស្រ្តបន្ថែម ទាក់ទងនឹងអំពើប្រល័យពូជ-សាសន៍ និងឧក្រិដ្ឋកម្មដ៏ឃោរឃៅប្រឆាំងមនុស្សជាតិ ព្រមទាំងអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្រ្តខ្មែរក្រហម។ មិនតែប៉ុណ្ណោះ យើងនឹងផ្តោតសំខាន់ទៅលើដំណោះស្រាយនៃតម្រូវការរបស់ជនរងគ្រោះ និងកូនចៅជំនាន់ក្រោយ ដែលជាគន្លឹះយ៉ាងសំខាន់មួយ សម្រាប់អនាគតដ៏ភ្លឺស្វាងរបស់

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតវិទ្យាស្ថានស្លឹករឹតគឺជាមជ្ឈមណ្ឌលស្រាវជ្រាវអចិន្ត្រៃយ៍ដើម្បីពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននិងធានានូវការប្តេជ្ញារយៈពេលយូរអង្វែងចំពោះការការពារសិទ្ធិមនុស្ស និងការរារាំងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ ការរចនាប្លង់សម្រាប់វិទ្យាស្ថានស្លឹករឹត ត្រូវបានរៀបចំឡើងដោយស្ថាបត្យករ

កម្រិតសកលលោកគឺ អ្នកស្រី ហ្សាហា ហាឌីត។ វិទ្យាស្ថានស្លឹករឹត គឺជាការរចនាមួយដែលបានបំផុសគំនិតតាមរយៈការរួមបញ្ចូលទៅក្នុងគ្រឹះស្ថានតែមួយ ដែលមានមុខងារផ្សេងៗគ្នារួមមាន ១) សារមន្ទីរនៃការចងចាំ ២) វិចិត្រសាលសិល្បៈសហសម័យ ៣) មជ្ឈមណ្ឌលស្រាវជ្រាវ ៤) គ្រឹះស្ថានសិក្សាពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស និង ៥) បណ្ណសារដ្ឋានឯកសារនៃរបបខ្មែរក្រហម។ វិទ្យាស្ថានស្លឹករឹតហ៊ុមព័ទ្ធទៅដោយធម្មជាតិពណ៌បៃតង ដែលឆ្លុះបញ្ចាំងអំពីអតីតកាល។រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានូវដីដែលមានទំហំដ៏ធំមួយកន្លែងនៅកណ្តាលរាជធានីភ្នំពេញសម្រាប់បរិវេណនៃការសាងសង់វិទ្យាស្ថានស្លឹករឹត មានទីតាំងស្ថិតនៅក្បែរវិទ្យាល័យបឹងត្របែក ដែលជាអតីតមន្ទីរកែប្រែអប់រំរបស់ខ្មែរក្រហម។

ឈ្មោះរបស់វិទ្យាស្ថានស្លឹករឹត បានឆ្លុះបញ្ចាំងពីគោលគំនិតស្នូលនៃបេសកកម្មដ៏សំខាន់របស់យើង ក៏ដូចជាបេតិកភណ្ឌរបស់ប្រជាជនកម្ពុជា។ ស្លឹករឹត គឺជាប្រភេទស្លឹកឈើស្ងួតម្យ៉ាង ដែលមេដឹកនាំសាសនា និងអ្នកប្រាជ្ញ បានប្រើប្រាស់អស់ជាច្រើនសតវត្សរ៍ ដើម្បីចងក្រងប្រវត្តិសាស្ត្រ ការផ្សព្វផ្សាយចំណេះដឹង និងត្រូវបានប្រើប្រាស់សម្រាប់ការអភិរក្សវប្បធម៌ក្នុងអំឡុងពេលនៃការគ្រប់គ្រងដ៏ឃោរឃៅ។ ស្លឹករឹតគឺជាស្លឹកឈើមួយប្រភេទដែលតំណាងឲ្យភាពស្រស់ ស្អាតនៃចំណេះវិជ្ជា និងអំណាចនៃការតស៊ូរបស់មនុស្សក្នុងគ្រាដ៏លំបាកមួយ។

វិទ្យាស្ថានស្លឹករឹតនឹងបង្ហាញពីគុណតម្លៃទាំងអស់ ព្រោះវិទ្យាស្ថានស្លឹករឹតគឺជាវិទ្យាស្ថាន មួយដែលជួយរំឭកដល់ការចងចាំពីអតីតកាល និងជាផ្នែកមួយដើម្បីជួយលើកទឹកចិត្តដល់ភ្ញៀវ ទេសចរឲ្យគោរព និងចងចាំអ្នកដែលបានស្លាប់ ឬជនរងគ្រោះដែលបានទទួលរងការឈឺចាប់ ក្រោមការគ្រប់-គ្រងរបស់ខ្មែរក្រហម។ វិទ្យាស្ថានស្លឹករឹត នឹងក្លាយទៅជាមជ្ឈមណ្ឌលអប់រំដ៏ សំខាន់មួយដែលអាចឲ្យមនុស្សនាពេលបច្ចុប្បន្ន និងកូនចៅជំនាន់ក្រោយរៀនសូត្រអំពីអតីត កាលដ៏គួរឲ្យខ្លោចផ្សាដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយនិងផ្តល់ឱកាសឲ្យក្មេងៗ ជំនាន់ក្រោយក្នុងការជួយទប់ស្កាត់ការរំលោភបំពាន ដែលមានភាពស្រដៀងគ្នានាពេលអនាគត។ ជាចុងក្រោយ វិទ្យាស្ថានស្លឹករឹត នឹងក្លាយទៅជាមជ្ឈមណ្ឌលដ៏សំខាន់មួយសម្រាប់ការសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះទៀតសោតយើង មានគោលបំណងប្រែក្លាយវិទ្យាស្ថានស្លឹករឹតឲ្យទៅជាស្ថាប័នឈានមុខបង្អស់ ដោយផ្តោត សំខាន់ទៅលើការសិក្សាពីអំពើប្រល័យពូជសាសន៍ប្រចាំនៅអាស៊ី និងដើម្បីកសាងទំនាក់ទំនង ដ៏រឹងមាំជាមួយអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងស្ថាប័នឈានមុខជាច្រើននៅទូទាំងពិភពលោក។

បច្ចុប្បន្ននេះ យើងកំពុងតែធ្វើយុទ្ធនាការរៃអង្គាសថវិកា និងមានគម្រោងសាងសង់វិទ្យាស្ថានស្លឹករឹតក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។

## ២) *កេរដំណែលនៃការចងចាំ*

ការថែរក្សាការចងចាំ គឺសំដៅលើការចងចាំ និងការស្គាល់អំពីអតីតកាលរបស់ខ្លួន ដែលជាការគោរពដល់អ្នកដែលបានស្លាប់ ឬជនរងគ្រោះដែលនៅរស់រានមានជីវិតក្រោមការគ្រប់គ្រងក្នុងរបបខ្មែរក្រហម និងអាចទប់ស្កាត់ការរំលោភបំពាន ដែលមានលក្ខណៈស្រដៀងគ្នាក្នុងពេលអនាគតកាល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ យើងនឹងផ្តោតសំខាន់ទៅលើការងារមួយ ដែលជួយដល់ការបង្កើតឲ្យមាន«គណៈកម្មការប្រវត្តិសាស្ត្រជាតិស្តីអំពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា»។ គណៈកម្មការនេះ នឹងក្លាយទៅជាអ្នកថែរក្សាការចងចាំប្រវត្តិសាស្ត្រ និងផ្តល់នូវការបំពេញបន្ថែមដល់តុលាការខ្មែរក្រហមសម្រាប់ការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះពីរបបខ្មែរក្រហម។ ទន្ទឹមនឹងនេះ យើងនឹងបន្តលើកកម្ពស់គម្រោង ដើម្បីពង្រឹងការយល់ដឹងជាសាធារណៈអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

### *ការអប់រំពីអំពើប្រល័យពូជសាសន៍*

ការអប់រំពីអំពើប្រល័យពូជសាសន៍ ពិតជាមានសារ

សំខាន់ណាស់ដល់ប្រជាជនកម្ពុជា ដើម្បីថែរក្សាប្រវត្តិសាស្ត្រ និងការចងចាំដល់ប្រជាជនកម្ពុជា ប្រមាណ២លាននាក់ ដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ព្រមទាំងអាចយល់ដឹងអំពីមូលហេតុ និងផលវិបាកនានានៃអំពើប្រល័យពូជសាសន៍។ អស់រយៈពេលប្រហែលជាងមួយទសវត្សរ៍កន្លងមកហើយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការជាមួយក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងអ្នកជំនាញក្នុងប្រទេស និងអន្តរជាតិ ដើម្បីអនុវត្តកម្មវិធីសិក្សាគោលមួយ ស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាដោយផ្អែកទៅលើ «សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ការផ្តល់វគ្គបណ្តុះបណ្តាលឲ្យកាន់តែមានភាពស៊ីជម្រៅដល់គ្រូបង្រៀន និងសិស្សនៅក្នុងប្រទេសកម្ពុជាបានជួយបំពេញនូវចំណេះដឹងជាសាធារណៈ បន្ទាប់ពីការខកខានមិនបានបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងសាលារៀន និងសាកលវិទ្យាល័យនានា ក្នុងប្រទេសកម្ពុជាអស់ជាច្រើនទសវត្សរ៍កន្លងមក។

នាឆ្នាំខាងមុខនេះ យើងនឹងបន្តពង្រីកការងារទាំងអស់តាមរយៈការលើកកម្ពស់ដល់ការផ្សព្វផ្សាយបន្ថែមអំពីសារៈសំខាន់នៃប្រវត្តិសាស្ត្រ។ «គម្រោងនៃការចងក្រងប្រវត្តិសាស្ត្រភូមិ» នឹងជួយអភិវឌ្ឍន៍ ថែមទាំងផ្សព្វផ្សាយប្រវត្តិសាស្ត្រពីសហគមន៍ដែលងាយទទួលរងផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជា។ យើងនឹងបណ្តុះបណ្តាលគ្រូបង្រៀនក្នុងសហគមន៍អំពីរបៀបប្រមែប្រមូលឯកសារ និងការចងក្រងប្រវត្តិសាស្ត្រភូមិ។ យើងក៏នឹងចូលរួមជាមួយគ្រូបង្រៀនទាំងអស់តាមរយៈការបណ្តុះបណ្តាល និងការណែនាំទៅលើការចងក្រង ដ៏ដូចជាការប្រមែប្រមូលសាច់រឿងរបស់ភូមិនីមួយៗនៅតាមតំបន់ដាច់ស្រយាល។ បន្ទាប់មក យើងនឹងផ្សព្វផ្សាយ«ប្រវត្តិសាស្ត្រភូមិ» ដើម្បីជាការប្រើប្រាស់សម្រាប់ជាព័ត៌មានបន្ថែមទៀតនៅតាមសាលារៀន និងក្នុងកម្មវិធីអប់រំក្រៅផ្លូវការ រួមទាំងអ្នកដែលស្ថិតនៅក្នុងសហគមន៍ដាច់ស្រយាលដើម្បីឈានទៅរកប្រជាធិបតេយ្យលើប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។

### *ការចងចាំអំពីប្រវត្តិរបស់ជនរងគ្រោះ*

គម្រោងស្តីពី«ប្រវត្តិជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺផ្តោតសំខាន់ទៅលើភាពតក់ស្លុតរបស់ជនរងគ្រោះ។ យើងកំពុងតែបន្តចងក្រងរឿងរ៉ាវរបស់ជនរងគ្រោះពីរបបខ្មែរក្រហមឲ្យក្លាយជាសៀវភៅនៃការចងចាំដើម្បីរំឭកដល់អ្នកដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម តាមរយៈការប្រើប្រាស់បណ្ណសារ មូលដ្ឋានទិន្នន័យប្រវត្តិសាស្ត្រ និងសាច់រឿងរបស់ជនរងគ្រោះ។ សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមនឹងក្លាយជាសៀវភៅដំបូងបង្អស់ ដែលកត់ត្រាឈ្មោះរបស់អ្នកស្លាប់ ហើយបង្ហាញអំពីរឿងរ៉ាវរបស់ជនរងគ្រោះនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម។ យើងចង់ឲ្យជនរងគ្រោះពីអំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហម ត្រូវបានមនុស្សជាតិចងចាំ និងស្តាប់ពីរឿងរ៉ាវជីវិតរបស់បុគ្គលម្នាក់ៗ ដោយមិនមែនគ្រាន់តែជាការចងចាំជាតួលេខ ឬក្រុមនៃមនុស្ស។ ក្រៅពីឈ្មោះ និងប្រវត្តិរូបរបស់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម យើងនឹងបញ្ចូលព័ត៌មានអំពីប្រវត្តិសាស្ត្រខ្មែរក្រហម រួមជាមួយរចនាសម្ព័ន្ធនៃការកើតឡើង និងការដួលរលំនៃរបបខ្មែរក្រហម។ សៀវភៅនេះ ក៏នឹងរៀបរាប់អំពីមូលហេតុនៃការបាត់ខ្លួន និងផលប៉ះពាល់ផ្លូវចិត្តចំពោះជនរងគ្រោះ។ ដោយគោលបំណងនៃការចងក្រងនេះផ្តោតសំខាន់លើរឿងរ៉ាវរបស់អ្នកស្លាប់ក្នុងរបបខ្មែរក្រហមនៅទូទាំងប្រទេស សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម នឹងក្លាយជាសៀវភៅមួយ ដែលអាចបំពេញបន្ថែមលើដំណើរការក្នុងតុលាការខ្មែរក្រហម និងរឿងរ៉ាវប្រវត្តិសាស្ត្រដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

### *ដំណើរការពិភាក្សាលើការចងចាំ*

នៅពេលដែលតុលាការខ្មែរក្រហមផ្អាក ឬបញ្ឈប់ដំណើរការ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានគម្រោងបន្តធ្វើការងាររបស់ខ្លួនលើការផ្តល់អាទិភាព ដល់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ឲ្យទទួលបានឱកាសក្នុងការនិយាយ

រៀបរាប់ដោយបើកចំហពីបញ្ហាទាក់ទងនឹងកេរដំណែលរបស់របបខ្មែរក្រហម។ យើងមានគម្រោងបង្កើតសមាគមជាផ្លូវការសម្រាប់អ្នកដែលនៅរស់រានមានជីវិត ដើម្បីជួយដល់ជនរងគ្រោះឲ្យទទួលបានការចូលរួមជាផ្លូវការជាមួយស្ថាប័នសង្គមស៊ីវិល ទាក់ទងនឹងយុត្តិធម៌ ការរំឭកដល់ការចងចាំ និងការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាដើម។ គម្រោងនេះមានបំណងជួយលើកកម្ពស់ឲ្យមានការចូលរួមយ៉ាងសកម្មរបស់ប្រជាជននៅក្នុងកិច្ចការសាធារណៈ ដែលជាគន្លឹះដើម្បីចន្លោះ តាមរយៈការស្វែងរកព័ត៌មានថ្មីៗ ដែលតុលាការខ្មែរក្រហមមិនទាន់បានរកឃើញ ដើម្បីជំរុញឲ្យមានការលើកកម្ពស់ដល់ការទទួលខុសត្រូវ និងធ្វើឲ្យប្រភពព័ត៌មានទាំងអស់អាចចកែរំលែកឲ្យបានកាន់តែទូលំទូលាយដល់សាធារណជន។

### រឿងរ៉ាវពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

វិធីសាស្ត្រមួយទៀត យើងនឹងស្ដាបនាព្រមទាំងផ្សព្វផ្សាយពីការងាររបស់តុលាការខ្មែរក្រហមតាមរយៈការចែក



រូបកណ្ដាល៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក អេនទ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ រួមជាមួយលោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិនៃសាលាក្ដីខ្មែរក្រហម នៅក្នុងពិធីសម្ពោធពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ នៅវិទ្យាល័យឥន្ទ្រទេវី។

រំលែកបទពិសោធន៍ការងាររបស់តុលាការខ្មែរក្រហមដែលនៅខ្វះទប់ស្កាត់ការរំលោភបំពានពីសំណាក់រដ្ឋាភិបាល ដូចទៅនឹងការរំលោភបំពានពី សម័យ ប៉ុល ពត។

### ៣) កេរដំណែលយុត្តិធម៌

ការកាត់ក្ដីក្នុងតុលាការខ្មែរក្រហមមិនទាន់បានផ្ដល់យុត្តិធម៌សម្រាប់ជនរងគ្រោះគ្រប់គ្រាន់នៅឡើយទេ។ បេសកកម្មរបស់យើង រួមបញ្ចូលទាំងការប្ដេជ្ញាគឺដើម្បីបំពេញបន្ថែមលើរំលែកបទពិសោធន៍ការងាររបស់បុគ្គលិកដែលបម្រើការងារនៅក្នុងតុលាការខ្មែរក្រហម។ តាមរយៈគម្រោងមួយដែលមានឈ្មោះថា «រឿងរ៉ាវពីតុលាការខ្មែរក្រហម» យើងនឹងចងក្រងរក្សាទុកនិងផ្សព្វផ្សាយពីសកម្មភាពរបស់អតីតមន្ត្រីនៃភាគីពាក់ព័ន្ធ និងភាគីដែលបានចូលរួមក្នុងរឿងរ៉ាវពីតុលាការខ្មែរក្រហម និងធ្វើឲ្យសាក្សីអាចស្វែងរកបានក្នុងទម្រង់ជាភាពយន្តឯកសារតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ បទសម្ភាសន៍

ទាំងនេះនឹងក្លាយជាវិធីសាស្ត្រអប់រំមួយដ៏សំខាន់ពីតុលាការខ្មែរក្រហម រួមទាំងការផ្តល់ចំណេះដឹង និងការពិភាក្សាដេញដោលបន្ថែមទៀតអំពីភាពជោគជ័យ ការរៀនសូត្រពីការងារ និងកេរដំណែលរបស់តុលាការខ្មែរក្រហម។

*អតីតកាលដែលត្រូវបានលាតត្រដាង*

យើងបានប្រមូលព័ត៌មានជាច្រើន អស់រយៈពេលយ៉ាងយូរ ដើម្បីកំណត់និងចង្អុលបង្ហាញអំពីរចនាសម្ព័ន្ធរបស់ខ្មែរក្រហម។ ព័ត៌មានដែលយើងប្រមូលបានតាមរយៈ«គម្រោងលើកកម្ពស់ឲ្យមានការទទួលខុសត្រូវ» បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ដំណើរការរបស់តុលាការខ្មែរក្រហម។ នៅឆ្នាំខាងមុខនេះ យើងនឹងពង្រីក ព្រមទាំងផ្សព្វផ្សាយឲ្យទូលំទូលាយដោយផ្អែកលើបញ្ហាមួយចំនួនដែលបានកើតឡើងចំពោះករណីផ្សេងៗនៅក្នុងដំណើរការកាត់ក្តីរបស់តុលាការខ្មែរក្រហម។ យើងមានគោលបំណងស្វែងរកនូវព័ត៌មានបន្ថែមពីបទឧក្រិដ្ឋបង្កឡើងដោយសមាជិកខ្មែរក្រហមថ្នាក់ក្រោមដែលជាបទល្មើសដ៏មានសារសំខាន់យ៉ាងខ្លាំងសម្រាប់ជនរងគ្រោះ។ យើងនឹងបន្តសម្ភាសន៍កម្មាភិបាលខ្មែរក្រហម ដែលនៅរស់រានមានជីវិត និងស្វែងយល់អំពីកិច្ចការសម្ងាត់ព្រមទាំងភាពអាថ៌កំបាំងផ្សេងៗនៃរចនាសម្ព័ន្ធ និងប្រតិបត្តិការក្នុងរបប ប៉ុល ពត។ យើងនឹងចងក្រងពត៌មានទាំងអស់នៅក្នុងមូលដ្ឋានទិន្នន័យ និងបទសម្ភាសន៍ដែលនឹងក្លាយជាមូលដ្ឋានគ្រឹះដ៏យូរអង្វែងរបស់ប្រវត្តិសាស្ត្រ ហើយអាចនឹងក្លាយទៅជាការទទួលខុសត្រូវតាមផ្លូវច្បាប់។

*ដំណើរការនៃការដាក់ឲ្យប្រើប្រាស់ឯកសារប្រវត្តិសាស្ត្រជាសកល*

វិធីម្យ៉ាងទៀត យើងនឹងនៅតែបន្តលើកកម្ពស់ដល់ការចងចាំ និងយុត្តិធម៌ ទាំងនៅក្នុង និងក្រៅប្រទេស គឺដើម្បីបង្កើន និងការពារការប្រមូលបណ្ណសាររបស់យើង។ នៅរវាងឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ យើងនឹងធ្វើការអភិវឌ្ឍន៍គេហទំព័រ ដើម្បីបញ្ចូលឯកសារបន្ថែមប្រមាណ៥០០.០០០ ទំព័រ ចេញពីបណ្ណសាររបស់យើង ដែលបច្ចុប្បន្នមិនទាន់អាចស្វែងរកបានជាសាធារណៈនៅលើប្រព័ន្ធអ៊ីនធឺណែត។ កិច្ចការនេះ អាចជួយសម្រួលដល់អ្នកសិក្សាជាន់ខ្ពស់ អ្នកសារព័ត៌មាន មន្ត្រីរាជការ និងប្រជាពលរដ្ឋដែលមានចំណាប់អារម្មណ៍ធ្វើការសិក្សាស្រាវជ្រាវ អំពីរបបខ្មែរក្រហមឲ្យកាន់តែមានប្រសិទ្ធភាព។ យើងនឹងចាត់វិធានការដើម្បីកែលម្អប្រព័ន្ធប្រមូលទិន្នន័យ ដើម្បីផ្សព្វផ្សាយពីប្រវត្តិសាស្ត្រ ព្រមទាំងប្រភពទិន្នន័យនៃទីតាំងភូមិសាស្ត្រ និងចម្លើយសារភាពឲ្យបានកាន់តែទូលំទូលាយ។

យើងសង្ឃឹមថា នឹងសាងសង់វិទ្យាស្ថានស្លឹករឹតក្នុងពេលខាងមុខនេះ និងបន្តការគាំទ្រលើការជំរុញឲ្យមានការចងចាំ និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាជាមួយនឹងការខបត្តម្ភដោយសប្បុរស ពីមិត្តភក្តិទាំងអស់នៅក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោក។

**ឆាំង យុ**

*មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលនូវសេចក្តីកោតសរសើរ និងពានរង្វាន់ជាច្រើន ចំពោះការងាររបស់ខ្លួនក្នុងការគាំទ្រដល់ការចងចាំ និងយុត្តិធម៌ សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងឆ្នាំ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលពានរង្វាន់សិទ្ធិមនុស្ស Judith Lee Stronach Human Rights ពីមជ្ឈមណ្ឌលដើម្បីយុត្តិធម៌ និងការទទួលខុសត្រូវ។ នៅក្នុងឆ្នាំដដែល ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ជូនចំពោះលោក ឆាំង យុ ចំពោះភាពថ្លៃថ្នូរនៃស្នាដៃបម្រើជាតិមាតុភូមិ។ នៅក្នុងឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលពានរង្វាន់ Ramon Magsaysay Award ដែលជារង្វាន់ណូបែលសន្តិភាពប្រចាំនៅអាស៊ី ចំពោះការចងក្រងនៃការចងចាំ និងថែរក្សាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម សម្រាប់ការផ្សះផ្សា និងយុត្តិធម៌។*

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោងប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង សុង ថាណៃ តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truththanay.s@dccam.org។




















# ចម្លើយសារភាពរបស់ ឡឿង ង៉ុកស៊ន់ អតីតកងទ័ពវៀតណាម

## *ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD0៧១៥៦*

ខ្ញុំឈ្មោះ ឡឿង ង៉ុកស៊ន់ ភេទប្រុស អាយុ២០ឆ្នាំ មានស្រុកកំណើតនៅក្នុងសហករណ៍ បាន គឿងឃុំង៉ុកខឿង ស្រុកវិសៀន ខេត្តហាយ៉ាង នៃប្រទេសវៀតណាមខាងជើង។ ខ្ញុំគឺជាកងទ័ពវៀតណាម និងមានឋានន្តរសក្តិជាពលទោផ្កាយ២ ដែលមានតួនាទីជាយុទ្ធជននៅកងពលលេខ ៣៤១ វរសេនាធំលេខ២៦៦ វរសេនាតូចលេខ៩ អនុសេនាធំលេខ១០ និងអនុសេនាតូចលេខ៤។ ខ្ញុំបានចូលបម្រើការងារនៅអង្គការយុវជនកុម្មុយនីស្តហូជីមិញនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៧ ដោយឈ្មោះ ឡៀង វ៉ាន់ឡឹប លេខាឃុំ ង៉ុកខឿង គឺជាអ្នកខទ្ទេសនាមខ្ញុំ។ ក្រោយមក ខ្ញុំបានចូលបំពេញភារកិច្ចជាកងទ័ព ដោយរៀនខាងបច្ចេកទេសយោធា និងនយោបាយអស់រយៈពេល ៣ ខែ។ អនុសេនីយ៍ផ្កាយ២ឈ្មោះ ឡៀង វ៉ាន់ញ៉ឹក គឺជាគណៈគ្រប់គ្រងសាលាទៀនក្វាង ផ្នែកនយោបាយដែលខ្ញុំបានរៀន។ ការអប់រំនៅទីនោះផ្តោតសំខាន់ទៅលើមាគ៌ាយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីសឥណ្ឌូចិន។ រហូតដល់ចុងខែកុម្ភៈ ឆ្នាំ១៩៧៨ ទើបអង្គភាពរបស់ខ្ញុំ ត្រូវបានបញ្ជូន មកប្រទេសវៀតណាមខាងត្បូង។ ដំបូងអង្គភាពរបស់ខ្ញុំ បានមកបោះទ័ពនៅឡុងមិញអស់រយៈពេលមួយសប្តាហ៍ បន្ទាប់មកទើបទៅបន្តទៅបោះទ័ពនៅដុងថាប់។ មុនពេលចូលសមរភូមិ អនុសេនីយ៍ផ្កាយ៤ឈ្មោះ ហ្វាង វ៉ាន់កុក បានឃោសនាអប់រំដូចខាងក្រោមនេះថា៖




«លើកនេះអង្គភាពយើងមានភារកិច្ចសំខាន់ណាស់ ដែលប្រទេសជាតិ និងបក្សយើងបាន ចាត់តាំងឲ្យវាយលុកចូលផ្នែកខាងត្បូងនៃប្រទេសកម្ពុជា។ ចំពោះការវាយលុកចូលក្នុងប្រទេសកម្ពុជា កងពលយើងត្រូវសហការជាមួយកងពលដទៃទៀត ដែលប្រចាំការនៅភាគខាងត្បូងនេះ។ នេះគឺជាការវាយលុកដ៏ធំ គឺត្រូវតែវាយលុកយកប្រទេសកម្ពុជាឲ្យបាន ដោយយើងនឹងបង្ខំ ប្រទេសកម្ពុជាឲ្យចូលក្នុងសហព័ន្ធឥណ្ឌូចិន បន្ទាប់មកគៀបសង្កត់ប្រទេសកម្ពុជាឲ្យដើរតាម បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមានប្រទេសយើងជាអ្នកដឹកនាំ និងត្រួតត្រា។ នេះមានន័យថា យើងត្រូវវាយឲ្យប្រទេសកម្ពុជាចុះញ៉ម ព្រមធ្វើជាវណបរបស់ប្រទេសយើង និងព្រមនៅក្រោមការត្រួតត្រារបស់យើងជាដាច់ខាត ទើបយើងមានកេរ្តិ៍ឈ្មោះល្បីល្បាញថែមទាំងអាចដះ ឥទ្ធិពលគ្រប់ដណ្តប់លើតំបន់អាស៊ីអាគ្នេយ៍ទាំងមូលនាពេលអនាគតដ៏ខ្លីខាងមុខនេះ។ ពេលវាយយកប្រទេសកម្ពុជាបាន យើងនឹងបំបាត់ព្រំដែនប្រទេសទាំងពីរ (កម្ពុជា និងវៀតណាម) ចោល។ យើង

ត្រូវតែរួមបញ្ចូលប្រទេសទាំងពីរឲ្យទៅជាប្រទេសតែមួយរួមទាំងមានប្រជាជន រដ្ឋអំណាច និងបក្សតែមួយដែរ។ ស្របពេលជាមួយគ្នានេះផងដែរ យើងនឹងបញ្ជូនកងទ័ព និងកម្មាភិបាលយើងឲ្យទៅធ្វើការត្រួតត្រា និងមើលការខុសត្រូវលើប្រទេសកម្ពុជា។ កងទ័ពរបស់យើងនឹងទៅដល់មុនគេ ហើយយើងនឹងទទួលបានផលប្រយោជន៍ច្រើនជាងគេព្រោះយើងនឹងរឹបអូសយកសម្ភារពីប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជា និងដឹកជញ្ជូនមកប្រទេសយើង ដើម្បីចែករំលែកឲ្យឪពុកម្តាយ បងប្អូន ហើយសម្ភារផ្សេងៗទៀតយើងនឹងលក់ក្នុងតម្លៃថោកៗឲ្យប្រជាជនដែលកំពុងជួបការលំបាកក្នុងការហូបចុក និងស្លៀកពាក់។ បញ្ហាចំពោះមុខ យើងនឹងបានប្រសើរ ព្រោះយើងបានដោះស្រាយជីវភាពប្រជាជនយើងបានមួយកម្រិតបន្ថែមទៀត។

ការវាយលុកលើកនេះ យើងពិតជាឈ្នះព្រោះកម្លាំងរបស់យើងមានច្រើនណាស់នៅតាមព្រំដែន ហើយប្រទេសយើងក៏បានត្រៀម និងត្រៀមខ្លួនរួចជាស្រេចជាមុនដែរ។


អត្ថបទបកប្រែពីខ្សែអាត់សំលេង
សេចក្តីសារភាព របស់ទីពហ្លួន ឈ្មោះ
ទៀវ វ៉ឹង ដុំកណិន ពលទោផ្កាយពីរ
——— * ———
អំពី
ប្រវត្តិ និងសកម្មភាពឈ្លានពាន

ប្រទេសកម្ពុជាមិនទាន់ដឹងខ្លួនទេ និងមិនអាចទប់ទល់ជាមួយយើងបានទេ ដែលនេះគឺជាខបាយកលមួយនៃជ័យជម្នះរបស់យើង។ ម្យ៉ាងទៀត យើងនឹងឃោសនាផ្សព្វផ្សាយជាសកលអំពីបញ្ហា ចរចា សន្តិភាព មិត្តភាព សាមគ្គីភាព និងព្រមគោរពបូរណភាពដែនដីថា គ្មានសហព័ន្ធឥណ្ឌូចិនទេ។ នេះគឺជាជំនួយមួយក្នុងការវាយសម្រុករបស់យើងដែរ គឺធ្វើឲ្យកម្ពុជាភ្លេចខ្លួនគិត តែពីបញ្ហាចរចាតែប៉ុណ្ណោះ។ ការធ្វើបែបនេះទើបយើងអាចវាយយកកងទ័ពរបស់ប្រទេសកម្ពុជា បានដោយងាយស្រួល ហើយកម្ពុជានឹងធ្លាក់ក្នុងកណ្តាបដៃយើងទាំងស្រុង។ ម្យ៉ាងទៀត ពិភពលោកនឹងមានការស្រពេចស្រពិល និងគិតស្មានមិនដល់ ថែមទាំងមិនចាប់អារម្មណ៍ថាយើងមានផែនការធំវាយយកប្រទេសកម្ពុជាឡើយ។ ពេលនោះ ប្រទេសទូទាំងពិភពលោក នឹងមើលមិនឃើញពីការឈ្លានពានរបស់យើងទៅលើប្រទេសកម្ពុជានោះទេ។ ផ្ទុយទៅវិញ ប្រទេសទាំងនោះនឹងឃើញតែរឿងល្អៗ ដូចជា ការចង់បានមិត្តភាព សាមគ្គីភាព និងសន្តិភាព។ នៅពេលវាយឈ្នះប្រទេសកម្ពុជា យើងនឹងបង្ខំឲ្យប្រទេសកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិន ហើយយើងនឹងធ្វើការ ប្រកាសពីរូបរាងសហព័ន្ធឥណ្ឌូចិនដែលបានកើតឡើងតាមបណ្តាំរបស់ ហូ ជី មិញ។

យើងគឺជាកងទ័ព កុំឆ្ងល់ និងកុំគិតពីបញ្ហាទាំងនេះ។ យើងគិតតែពីវាយចូលប្រទេសកម្ពុជាឲ្យបានទៅតាមសំណូមពររបស់មជ្ឈិមបក្សរបស់យើងនេះជាដាច់ខាត គឺត្រូវតែវាយយកប្រទេសកម្ពុជាទាំងមូល ប៉ុន្តែប្រសិនបើមិនសម្រេចតាមផែនការនេះទេ យើងនឹងវាយយកផ្នែកណាមួយនៃប្រទេសកម្ពុជា។ បើយើងនៅតែវាយមិនទាន់សម្រេចទៀត យើងនឹងវាយរំកិលព្រំដែនឲ្យបាន គឺនៅពេលយើងទៅដល់ទីណាយើងត្រូវតែបោះទីតាំងនៅទីនោះ។ កាលមុន យើងធ្លាប់បានវាយចូលបានប្រហែលចន្លោះពី ២០ ទៅ ៣០គីឡូម៉ែត្រម្តងហើយ តែពេលនោះយើងភ្លើតភ្លើនសប្បាយពេក វល់តែស៊ីផឹក ហើយដឹកជញ្ជូនសម្ភារ គោក្របី ស្រូវអង្ករ ពីប្រទេស

កម្ពុជា ដោយគិតស្មានថាប្រទេសកម្ពុជាមិនហ៊ានវាយកម្ទាត់វិញៗ ផ្ទុយទៅវិញប្រទេសកម្ពុជា បានវាយទប់ និងកម្ទេចយើងទាំងអស់ៗ ពេលយើងរត់មកដល់ស្រុកយើងវិញ យើងអត់បានអ្វីទេ មានតែខូចខាត ថែមទាំងបាត់បង់កងទ័ពអស់មួយចំនួនធំទៀតៗ ថ្វីបើនៅពេលនោះយើងបាត់បង់កម្លាំងទ័ពយ៉ាងច្រើនសន្ធឹកក៏ដោយ ក៏នៅពេលនេះយើងត្រូវវាយចូលប្រទេសកម្ពុជាម្តងទៀត ព្រោះកម្លាំងទ័ពយើងលើកនេះមានច្រើន និងរឹងមាំណាស់ ព្រមទាំងមានយុទ្ធវិធីល្អៗ និងស្ទាត់ជំនាញទៀតផងៗ សមរភូមិលើកនេះ បើអ្នកណាមិនចូល ឬរត់ចោលសមរភូមិត្រូវតែបាញ់សម្លាប់ចោល ដោយគ្មានជំនុំជម្រះ ឬអនុគ្រោះអ្វីឡើយៗ

បន្ទាប់ពីបានឆ្លងកាត់ការឃោសនាអប់រំ ដោយអនុសេនីយ៍ផ្កាយ៤ឈ្មោះ ហ្វាង វ៉ាន់ភុក កង វរសេនាធំរបស់ខ្ញុំបានចាប់ផ្តើមធ្វើសកម្មភាពវាយចូលក្នុងប្រទេសកម្ពុជានៅប៉ែកខាងកោះអណ្តែត ខេត្តតាកែវ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៨ ប៉ុន្តែវាយចូលមិនបានសម្រេច ក៏ត្រូវដកថយចេញទៅវិញៗ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៨ ក្រុមរបស់ខ្ញុំត្រូវបានចាត់តាំងឲ្យដកចេញពី សមរភូមិនេះដើម្បីទៅវាយនៅសមរភូមិលក ខេត្តកំពតវិញ នៅវេលាយប់ថ្ងៃទី៦នោះៗ


កុមារា នង ចាន់ផល និង នង ចាន់នី (រូបទី១ និងទី២ រាប់ពីស្តាំ) រួមទាំងកុមារមិនស្គាល់ឈ្មោះពីរនាក់ដែលនៅរស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង) ត្រូវបាន ជួយសង្គ្រោះដោយកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពកម្ពុជាៗ យោងតាម ហូ វ៉ាន តាយ អ្នកថតរូបជនជាតិវៀតណាម ដែលបានរកឃើញ និងចូលមកដល់គុកទួលស្លែងមុនគេ បានមានប្រសាសន៍ថា មានកុមារ៥នាក់ដែលស្ថិតនៅក្នុងអគារមួយក្នុងចំណោមអគារជាច្រើនដែលខ្លះកំពុងយំ និងខ្លះទៀតកំពុងដេកលក់ៗ កុមារទាំង៥នាក់នោះភាគច្រើនគឺជាកូនរបស់កម្មាភិបាលខ្មែរក្រហមដែល ប៉ុល ពត បានបញ្ជូនទៅកាន់មន្ទីរសន្តិសុខស-២១ៗ ស្ថិតនៅពីមុខគាត់ និង កងទ័ពស្ម័គ្រចិត្តវៀតណាម កុមារទាំងនោះមានសភាពស្គមកំព្រឹង និងជិតស្លាប់ៗ កងទ័ពកម្ពុជាផ្នែកនារី ត្រូវបានហៅឲ្យមកថែទាំកុមារទាំងនោះៗ

ថ្ងៃស្អែកឡើង កាំភ្លើងចាប់ផ្តើមផ្ទុះឡើងនៅសមរភូមិលកៗ ខ្ញុំភ័យខ្លាំងណាស់ ហើយកាន់តែខ្លាចជាងការវាយចូលសមរភូមិនៅកោះអណ្តែត ខេត្តតាកែវ ទៅទៀតៗ ស្នូរកាំភ្លើងក៏បានលាន់ឮមួយប្រាវៗ ខ្ញុំបានក្រាបនៅក្នុងលេណដ្ឋានដោយខ្លួនរបស់ខ្ញុំញ័ររន្ធត់ហើយបន្ទាប់មកស្នូរកាំភ្លើងក៏ស្ងាត់ទៅវិញរហូតៗ ខណៈពេលនោះ ខ្ញុំចង់រត់ចេញពីសមរភូមិនេះណាស់ ប៉ុន្តែ ខ្ញុំមិនស្គាល់ទីតាំងភូមិសាស្ត្រនៅទីនោះទាល់តែសោះៗ ត្រឹមតែមួយពព្រិចភ្នែកតែប៉ុណ្ណោះ កងទ័ពរបស់កម្ពុជាបានចូលមកដល់លេណដ្ឋានរបស់ខ្ញុំ ដោយបានស្រែកបញ្ជាឲ្យលើកដៃ និងក្រោកឈរឡើងៗ ខ្ញុំបានសំឡឹងមើលទៅកាន់មិត្តភក្តិរបស់ខ្ញុំគឺឃើញស្លាប់អស់បន្ទាប់មកកងទ័ពរបស់កម្ពុជាបានចាប់ខ្លួនខ្ញុំតែម្តងៗ

*យី សុឃី*

**កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់អ្នកទោសវៀតណាម វឿង ង៉ុកស៊ិន់ នេះពិតឬយ៉ាងណានោះទេៗ**

# ត្រិន ង៉ុកតឿង ឆ្លាក់ចារចារកម្មវៀតណាម

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD0៧១៥៤*

ខ្ញុំឈ្មោះ ត្រិន ង៉ុកតឿង អាយុ ២៦ឆ្នាំ នៅលីវ មានទីកន្លែងកំណើតនៅក្នុងភូមិហិងឡុង ឃុំផានធាត ស្រុកហាមធន់ ខេត្តបិញធន់ ប្រទេសវៀតណាមខាងត្បូង។ ខ្ញុំមានឋានន្តរសក្តិ សក្តិ១នៃកងទ័ពថ្មើរជើង ធីវ-គី សញ្ញាក្បាលខ្លា។ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧២ ខ្ញុំបានចូលរៀននៅសាលាមហាវិទ្យា-ល័យសង្គ្រាមនយោបាយនាយទាហានធីវ-គីនៅក្រុងដាឡាត់ ខេត្តតៀនទ្ទិក ប្រទេសវៀតណាមខាងត្បូង។ បីឆ្នាំបន្ទាប់មក នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបំពាក់សក្តិមួយនៃកងទ័ពថ្មើរជើងសញ្ញាក្បាលខ្លា។ ប៉ុន្តែនៅពេលនោះ ខ្ញុំមិនទាន់បានទៅអង្គភាព ដើម្បីទទួលតំណែងថ្មីនៅឡើយទេ។ លុះដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ធីវ-គី បានចុះចាញ់សង្គ្រាម។ វៀតណាមខាងត្បូង ត្រូវបានយៀកកុងរំដោះ ដែលពេលនោះខ្ញុំកំពុងនៅឯព្រៃនគរ ជាមួយមិត្តភក្តិរបស់ខ្ញុំនៅឡើយ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៥ រដ្ឋអំណាចយៀកកុងបានចាប់ខ្ញុំយកទៅដាក់សាលាអប់រំ កាទុំ ដែលស្ថិតនៅក្នុងខេត្តតៃនិញ។ ពេលនោះ អនុសេនីយ៍ ផ្កាយ៤ ឈ្មោះការដាងចៀមដែលជាស្នងការនយោបាយនៃកងវរសេនាតូចលេខ៦នៃកងអែហ្វូ ៥00 របស់យោធាភូមិភាគទី៧ គឺជាអ្នកទទួលខុសត្រូវជំរំអប់រំ កាទុំ។ នៅក្នុងជំរំអប់រំ កាទុំ ខ្ញុំបានធ្វើពលកម្មបន្តិចបន្តួចតែប៉ុណ្ណោះ ព្រោះការអប់រំផ្តោតសំខាន់ខ្លាំងទៅលើតែការរៀនសូត្រអំពីនយោបាយ ដោយលើកយកឯកសារនយោបាយជាច្រើនមកខទ្ទេសនាម។ ខ្ញុំចងចាំឯកសារ





កងទ័ពវៀតណាមដែលជាប់ឃុំនៅមន្ទីរសន្តិសុខស-២១។

ពីរ គឺ១)វណ្ណៈតស៊ូវណ្ណៈ និង២) ប្រវត្តិបក្សកុម្មុយនីស្តវៀតណាម។ ក្នុងឯកសារទាំងនោះនិយាយថា ពួកនាយទាហានធីវ-គី គឺជាដៃជើងរបស់វណ្ណៈជិះជាន់ប្រជាជន។ បន្ទាប់មកអនុសេនីយ៍ផ្កាយ៤ការ់វដាងចៀម បាននិយាយថា បក្សកុម្មុយនីស្តវៀតណាមក្នុងឆ្នាំ១៩៣០ ធ្លាប់មានឈ្មោះថា ជាបក្សកុម្មុយនីស្តឥណ្ឌូចិន ហើយអ្នកដែលបានបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិននេះគឺ ហូ ជីមិញ។ នៅពេលនោះ ហូ ជីមិញ បានលើកមាគ៌ាជាយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តឥណ្ឌូចិនថានឹងវាយចក្រពត្តិបារាំងដើម្បីរំដោះប្រទេសទាំងបីនៅឥណ្ឌូចិនគឺ វៀតណាម កម្ពុជា និង ឡាវ។ លុះបានរំដោះហើយ បក្សកុម្មុយនីស្តឥណ្ឌូចិន នឹងចាត់តាំងប្រទេសទាំងបីនេះជាសហព័ន្ធឥណ្ឌូចិនដែលមានវៀតណាមជាអ្នកដឹកនាំនិងគ្រប់គ្រង។ ក្រោយមកបក្សកុម្មុយនីស្តឥណ្ឌូចិន ក៏បានដូរឈ្មោះទៅជាបក្សពលករវៀតណាម ហើយបន្ទាប់មកគឺជាបក្សកុម្មុយនីស្តវៀតណាម។ ប៉ុន្តែ បក្សកុម្មុយនីស្តវៀតណាមមិនទាន់បានសម្រេចគោលគំនិតសហព័ន្ធឥណ្ឌូចិនបាននៅឡើយទេ ពីព្រោះបន្ទាប់ពីប្រទេសទាំង៣បានរំដោះរួចហើយ ប្រទេសកម្ពុជាមិនព្រមចូលជាសមាជិកសហព័ន្ធឥណ្ឌូចិនទេ ថែមទាំងបានប្រឆាំងនឹងមាគ៌ាបក្សកុម្មុយនីស្តឥណ្ឌូចិនរបស់វៀតណាមទៀតផង។ ដូច្នេះ ប្រទេសកម្ពុជា គឺជាសត្រូវរបស់ប្រទេសវៀតណាម។ ប្រទេសវៀតណាមគឺជាវៀមច្បងគេនៅឥណ្ឌូចិនដែលមិនព្រមឲ្យប្រទេសប្អូនៗដូចជាប្រទេសកម្ពុជានិងប្រទេសឡាវ ធ្វើអ្វីតាមតែអំពើចិត្តនោះទេ គឺបក្សកុម្មុយនីស្តកម្ពុជាត្រូវតែដើរតាមវៀតណាមជាដាច់ខាត។ ដោយសារមូលហេតុនេះ ក្នុងពេលកន្លងមក បក្សកុម្មុយនីស្តវៀតណាម បានសម្រេចចិត្តវាយលុកប្រទេសកម្ពុជា និងបង្ខំឲ្យកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិន ដែលមានវៀតណាមជាអ្នកត្រួតត្រាឲ្យទាល់តែបាន។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧ ក្រុមរបស់ខ្ញុំត្រូវបានអង្គភាពបញ្ជូនទៅ កៀកឡុង ស្ថិតក្នុងខេត្តសុងប៊ែ ដែលនៅទីនោះ ក្រុមរបស់ខ្ញុំ ធ្វើពលកម្មផង និងរៀនសូត្រនយោបាយផង។ អនុសេនីយ៍ផ្កាយ៣ ក្វាច់-បាវី បានលើកពីសភាពការណ៍តាមព្រំដែនកម្ពុជា-វៀតណាមមកអប់រំថា «សព្វថ្ងៃនេះកងទ័ពវៀតណាមកំពុងតែវាយលុកចូលប្រទេសកម្ពុជា។


កុមារា នង ចាន់ផល និង នង ចាន់នី (រូបទី១ និងទី២ រាប់ពីស្តាំ) រួមទាំងកុមារមិនស្គាល់ឈ្មោះពីរនាក់ដែលនៅរស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង) ត្រូវបាន ជួយសង្គ្រោះដោយកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពកម្ពុជា។ យោងតាម ហូ វ៉ាន តាយ អ្នកថតរូបជនជាតិវៀតណាម ដែលបានរកឃើញ និងចូលមកដល់គុកទួលស្លែងមុនគេ បានមានប្រសាសន៍ថា មានកុមារ៥នាក់ដែលស្ថិតនៅក្នុងអគារមួយក្នុងចំណោមអគារជាច្រើនដែលខ្លះកំពុងយំ និងខ្លះទៀតកំពុងដេកលក់។ កុមារទាំង៥នាក់នោះភាគច្រើនគឺជាកូនរបស់កម្មាភិបាលខ្មែរក្រហមដែល ប៉ុល ពត បានបញ្ជូនទៅកាន់មន្ទីរសន្តិសុខស-២១។ ស្ថិតនៅពីមុខគាត់ និង កងទ័ពស្ម័គ្រចិត្តវៀតណាម កុមារទាំងនោះមានសភាពស្គមកំព្រីង និងជិតស្លាប់។ កងទ័ពកម្ពុជាផ្នែកនារី ត្រូវបានហៅឲ្យមកថែទាំកុមារទាំងនោះ។

យើងវាយលុកប្រទេសកម្ពុជាដើម្បីយកស្រូវ អង្ករ គោ ក្របី មកដោះស្រាយជីវភាពរបស់យើងដែលកំពុងតែ អត់ឃ្លាន ក្នុងពេលបច្ចុប្បន្ននេះ ជាពិសេសគឺដើម្បីបញ្ចូលប្រទេសកម្ពុជា ទៅក្នុងសហព័ន្ធឥណ្ឌូចិន»។ លុះដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៧៨ អនុសេនីយ៍ផ្កាយ៣ ក្វាច់ បាវី ប្រធានកងវរសេនា តិនហុង សក្តិ១ កងទ័ពលោតឆ័ត្រ ៣) ហូ វ៉ាន់លិញ សក្តិ១ កងទ័ពដើងទឹកប្រយុទ្ធលើគោក ៤) ភូ សក្តិ១ កងទ័ពដើងទឹក ប្រយុទ្ធលើគោក ៥) ត្រិន ជិត្រុង សក្តិ២ កងទ័ពដើងទឹកធីវ-គី ដើម្បីឲ្យទៅជួបគាត់ជាសម្ងាត់។ អនុសេនីយ៍ផ្កាយ៣ ក្វាច់ បាវី បានលួងលោមក្រុមរបស់ខ្ញុំថាបក្សវៀតណាម មាន ជំនឿទុកចិត្តលើក្រុមរបស់ខ្ញុំច្រើនហើយ ពីព្រោះក្រុមរបស់ខ្ញុំ បានទទួលការអប់រំរៀនសូត្រនយោបាយនិងបានកែប្រែជា ច្រើនដែលរហូតដល់បច្ចុប្បន្ន នេះក្រុមរបស់ខ្ញុំនៅតែបញ្ជាក់ សកម្មភាពជាក់ស្តែងមួយទៀតតែប៉ុណ្ណោះ។ អនុសេនីយ៍ ផ្កាយ៣ ក្វាច់ បាវី ក៏បានបញ្ជាក់ទៀតថា សព្វថ្ងៃវៀតណាម នៅតែវាយលុកប្រទេសកម្ពុជា ហើយចង់ក្តាប់សភាពការណ៍ ប្រទេសកម្ពុជានៅតាមព្រំប្រទល់ ត្រង់ម្តុំភៀកឡុងឲ្យបាន ច្បាស់លាស់។ ដូច្នេះក្រុមរបស់ខ្ញុំដែលជាអ្នកចេះស្ទាត់ជំនាញ ខាងយោធាអាចមានសមត្ថភាពបំពេញភារកិច្ចស៊ើបការណ៍ នេះបាន។ ប្រសិនបើក្រុមខ្ញុំធ្វើបានសម្រេចកិច្ចការទាំងនេះ បក្ស វៀតណាមនឹងកាន់តែទុកចិត្ត និងដោះលែងក្រុមរបស់ខ្ញុំឲ្យ ត្រឡប់ទៅជួបឪពុកម្តាយ និងប្រពន្ធកូនវិញ។ កិច្ចការដែល ក្រុមរបស់ខ្ញុំត្រូវទៅស៊ើបពីប្រទេសកម្ពុជានោះគឺ ទី១) រកឲ្យ ឃើញថាតើទីតាំងបោះទ័ពកម្ពុជានៅត្រង់ណា ២) រកឲ្យឃើញ ទីតាំងកាំភ្លើងធំនៅត្រង់កន្លែងណា ៣) ត្រូវក្តាប់ឲ្យច្បាស់ថា តើប្រទេសកម្ពុជាមានចំនួនរថក្រោះប៉ុន្មាន និងប្រភេទអ្វីខ្លះ ហើយជារថក្រោះដែលជាជំនួយ ឬផលិតនៅក្នុងប្រទេសណា? នៅពេលដែលក្រុមរបស់ខ្ញុំ ទទួលបានដំណឹងច្បាស់លាស់ ហើយ ក្រុមរបស់ខ្ញុំត្រូវនាំកងទ័ពវៀតណាមទៅវាយកម្ទេច ប្រទេសកម្ពុជា និងបង្ខំឲ្យប្រទេសកម្ពុជា ចូលក្នុងសហព័ន្ធ ឥណ្ឌូចិនឲ្យបាន។ អនុសេនីយ៍ផ្កាយ៣ ក្វាច់ បាវី ក៏បានប្រាប់ ខ្ញុំថារយៈពេលកន្លងមក បក្សកុម្មុយនីស្តវៀតណាមបានវាយ ប្រហារប្រទេសកម្ពុជាទាំងផ្នែកយោធា និងនយោបាយ។ ចំពោះផ្នែកនយោបាយ បក្សកុម្មុយនីស្តយើងបានប្រកាស តាមវិទ្យុអំពីការចរចាបញ្ហាព្រំដែនកម្ពុជា ដោយសន្តិវិធី អំពី សាមគ្គីភាព មិត្តភាពពិសេស និងប្រកាសថាមិនតូចលេខ៤ នៃវរសេនាធំ២ អែហូ ៣០០ បានហៅពួកខ្ញុំ៥នាក់គឺ ១) ត្រិន ង៉ុនគឿង សក្តិ១ កងទ័ពថ្មើរជើងធីវ-គី ២) លឿង ឈ្វានពាន ប្រទេសកម្ពុជាទេ។ ប៉ុន្តែនេះគឺជាឧបាយកលរបស់យើងទេ ព្រោះយើងនៅតែប្រើកម្លាំងទ័ព វាយលុកប្រទេសកម្ពុជា ដដែល។ បន្ទាប់ពីទទួលបានភារកិច្ចហើយ ខ្ញុំបានគិតគូរយ៉ាង ហ្មត់ចត់ថា រហូតមកដល់ពេលនេះ បក្សកុម្មុយនីស្តវៀតណាម បានទុកចិត្តខ្ញុំហើយ ដូចច្នេះ ខ្ញុំនៅសល់ត្រឹមតែការបង្ហាញ ពីភាពស្មោះត្រង់របស់ខ្ញុំតែប៉ុណ្ណោះ។ ហេតុនេះទើបខ្ញុំតាំង ចិត្តស៊ើបការណ៍ពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជាឲ្យបាន សម្រេច។

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨ ក្រុមរបស់ខ្ញុំបានធ្វើ ដំណើរមកស៊ើបការណ៍នៅប្រទេសកម្ពុជា។ ដំបូងក្រុមរបស់ ខ្ញុំ បានរុករកទីតាំងកងទ័ពកម្ពុជាដែលស្ថិតនៅជាប់ព្រំដែន ភៀក ឡុង អស់រយៈពេល៥ថ្ងៃ ប៉ុន្តែមិនបានជួបអ្វីសោះ។ រហូតដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៨ នៅពេលដែលក្រុម របស់ខ្ញុំបានសម្រេចចិត្តចូលជ្រៅក្នុងដែនដីកម្ពុជា គឺធ្វើយ៉ាង ណាចូលឲ្យដល់ ភូមិក្រុង ខេត្តមណ្ឌលគិរី។ តែជាអកុសល ខ្ញុំ ក៏ត្រូវបានយោធាខ្មែរក្រហមព័ទ្ធចាប់ខ្លួនបាន និងយកមកឃុំ (នៅមន្ទីរសន្តិសុខស-២១) នៅថ្ងៃទី២៩ខែមេសាឆ្នាំ១៩៧៨។ ធ្វើនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៧៨។

*សូវិចិត្រ មេត្តា*

***កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោស ទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិត បង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់អ្នកទោស វៀតណាម ត្រិន ង៉ុកគឿង នេះពិតឬយ៉ាងណានោះទេ។***

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ខែមីនា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្តី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្តី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប ១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៨ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# ស្ពានរថភ្លើង រំឭកដល់អនុស្សាវរីយ៍ពីអតីតកាលរបស់ខ្ញុំ

នារសៀលថ្ងៃមួយ មានស្ត្រីចំណាស់ម្នាក់កំពុងអង្គុយយ៉ាងស្ងៀមស្ងាត់តែម្នាក់ឯងនៅក្នុងបរិវេណស្ថានីយ៍រថភ្លើង។ គាត់កាត់សក់ខ្លីត្រឹមក និងមានសម្បុរស។ គាត់បានញញឹមរាក់ទាក់ និងបង្ហាញសេចក្តីរីករាយយ៉ាងខ្លាំងនៅពេលឃើញខ្ញុំ។ នៅពេលនោះ ខ្ញុំបានឆ្លៀតឱកាសសួរនាំគាត់ខ្លះៗពីប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម ភ្លាមនោះគាត់ក៏បាននិយាយរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួន ក្រុមគ្រួសាររបស់គាត់ និងរឿងរ៉ាវផ្សេងៗទៀត ដែលគាត់បានលាក់ទុកក្នុងចិត្តជាយូរមកហើយ។ គាត់បានឲ្យដឹងថា គាត់ឈ្មោះ តិច សៀកលីម សព្វថ្ងៃរស់នៅក្នុងខេត្តកំពត។ ខាងក្រោម នេះគឺជាការរៀបរាប់របស់ តិច សៀកលីម ៖

ខ្ញុំមានរឿងរ៉ាវជាច្រើនចង់រៀបរាប់ប្រាប់ក្មួយ អំពីហេតុការណ៍ដែលបានកើតឡើងចំពោះខ្ញុំផ្ទាល់ ក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនខ្មែរទាំងឡាយដែលខ្ញុំបានស្គាល់ក្នុងកំឡុងពេលរស់នៅក្នុងរបបខ្មែរក្រហម។ រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ យើងទាំងអស់គ្នាបានទទួលរងទុក្ខ និងបាត់បង់យ៉ាងធំធេងចំពោះទង្វើដែលមេដឹកនាំខ្មែរក្រហមធ្វើមកលើប្រជាជនខ្លួនឯង។

សព្វថ្ងៃនេះ ខ្ញុំមានអាយុ៧២ឆ្នាំ រស់នៅជាមួយកូនប្រុសម្នាក់ប្រកបមុខរបរធ្វើស្រែចម្ការ និងបង្កើតកសិដ្ឋានចិញ្ចឹមសត្វក្រួច។ ខ្ញុំមានស្រុកកំណើតនៅឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល សព្វថ្ងៃខ្ញុំរស់នៅក្នុងឃុំក្រាំងអំពិល ស្រុក


តិច សៀកលីម និងក្រុមនិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ទឹកឈូ ខេត្តកំពត។ ខ្ញុំបានផ្លាស់ប្តូរទីលំនៅមករស់នៅក្នុងខេត្តកំពតដោយសារមូលហេតុពីរយ៉ាងគឺ ១)សង្គ្រាម និង២) បំលាស់ប្តូរទីតាំងការងាររបស់ប្តីខ្ញុំ។ ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៦៤ និងមានកូន១១នាក់ ប៉ុន្តែនៅមានជីវិតចំនួន៨នាក់តែប៉ុណ្ណោះ ប្រុស៤នាក់ និងស្រី៤នាក់។ កូនរបស់ខ្ញុំម្នាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយសារតែកើតជំងឺកញ្ជ្រឹលខ្វះថ្នាំព្យាបាល។ សព្វថ្ងៃផ្ទះរបស់ខ្ញុំស្ថិតនៅចម្ងាយប្រហែល៥០ម៉ែត្រពីស្ថានីយ៍រថភ្លើង ក្បែរទីរួមខេត្តកំពត។ សមាជិកគ្រួសាររបស់ខ្ញុំភាគច្រើនបម្រើការងារជាបុគ្គលិកផ្លូវដែក។ ប្តីរបស់ខ្ញុំជាបុគ្គលិកផ្លូវដែកចាប់តាំងពីឆ្នាំ១៩៦៦ រហូតដល់គាត់បានស្លាប់ក្នុងឆ្នាំ២០០៥ កន្លងមកនេះ។ ម្តាយរបស់ខ្ញុំ ជាអតីតចុងភៅចម្អិនម្ហូបអាហារឲ្យប្រធានផ្នែករថភ្លើងភូមិភាគនិរតី នៅទីក្រុងភ្នំពេញក្នុងរបបខ្មែរក្រហម។ ចំណែកឯកូនរបស់ខ្ញុំវិញ គឺជាអតីតបុគ្គលិកលក់សំបុត្ររថភ្លើង បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ។

ស្ទើរតែពេញមួយជីវិត ខ្ញុំ និងក្រុមគ្រួសារ បានរស់នៅក្បែរផ្លូវរថភ្លើងដោយបានឮសូរសំឡេងរថភ្លើងបើកឆ្លងកាត់ និងសំឡេងស៊ីផ្លេរបស់វាជាប្រចាំ។ រថភ្លើង គឺជាវត្ថុមួយដែលតែងតែជួយរំឭកអំពីរឿងរ៉ាវអតីតកាលរបស់ខ្ញុំ។ វាបានរំឭកអំពីដំណើរជីវិតរបស់ក្រុមគ្រួសារខ្ញុំ ដែលបានឆ្លងកាត់រឿងរ៉ាវជាច្រើននៅក្នុងរបបខ្មែរក្រហម។ មិនតែប៉ុណ្ណោះ វាបានធ្វើឲ្យខ្ញុំនឹករឭកដល់ប្តីរបស់ខ្ញុំ និងប្រជាជនខ្មែរជាច្រើនដែលធ្លាប់ឆ្លងកាត់សង្គ្រាមដ៏ឃោរឃៅជាមួយគ្នា ទោះបីជាអ្នកខ្លះបានស្លាប់ទៅហើយយ៉ាងណាក៏ដោយ។ ស្ពានរថភ្លើងបានរៀបរាប់ និងផ្តល់ការចងចាំដល់ខ្ញុំនូវរឿងរ៉ាវមិនសូវល្អក្នុងខណៈពេលនោះ ប៉ុន្តែវាក៏ជាអនុស្សាវរីយ៍ និងបទពិសោធន៍មួយ ដែលខ្ញុំនិងក្រុមគ្រួសារបានពុះពារឆ្លងកាត់យ៉ាងលំបាករហូតអាចរក្សាជីវិតរស់បានរហូតដល់សព្វថ្ងៃនេះ។ ពេលខ្លះខ្ញុំបានសម្លឹងមើលទៅរថភ្លើងដែលបានចតនៅក្នុងស្ថានីយ៍រថភ្លើងក្បែរកន្លែងដែលខ្ញុំរស់នៅសព្វថ្ងៃ ហើយខ្ញុំតែងសញ្ជឹងគិតថា ដោយសារតែមានរថភ្លើងនេះហើយ ទើបខ្ញុំ និងគ្រួសារអាចបន្តជីវិតរស់ និងមានជីវភាពប្រសើរជាងប្រជាជនដទៃទៀតនៅក្នុងរបបខ្មែរក្រហម ដែលអ្នកទាំងនោះត្រូវបានខ្មែរក្រហមធ្វើបាប ដឹកតាមរថភ្លើងយកទៅឃុំឃាំង និងសម្លាប់នៅក្នុងគុកទួលស្លែង និងកន្លែងផ្សេងៗទៀត។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំនិងប្តីត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុង ឃុំអង្គកែវ ស្រុកទ្រាំង ខេត្តតាកែវ។ ភាពចលាចលនៃការជម្លៀស និងការប្រព្រឹត្តអំពើហិង្សាក៏ចាប់ ផ្តើមកើតមានឡើងចំពោះប្រជាជន។ ប្រជាជនជាច្រើន ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទី ក្រុងភ្នំពេញទៅកាន់ភូមិភាគនិរតីជាទីកន្លែងដែលខ្ញុំធ្លាប់បានរស់នៅ។ ស្ថិតក្នុងស្ថានភាពវឹកវរនោះ ខ្មែរក្រហមក៏បានជិះឡានប្រកាសហៅកម្មករផ្លូវដែកឲ្យចូលធ្វើការវិញ។ ប្តីរបស់ខ្ញុំបានសម្រេចចិត្តចូលធ្វើការក្នុងអង្គភាពផ្លូវដែកជាមួយខ្មែរក្រហម ព្រោះ




តិច សៀកលីម នៅស្ថានីយ៍រថភ្លើងខេត្តកំពត

គាត់ស្រឡាញ់ការងារនេះណាស់។ គាត់បានដើរជួសជុល និង ត្រួតពិនិត្យមើលផ្លូវរថភ្លើងចាប់ពីខេត្តតាកែវ រហូតដល់ខេត្ត កំពត ហើយគាត់តែងតែត្រឡប់ទៅស្នាក់នៅជាមួយខ្ញុំវិញជា រៀងរាល់ល្ងាចៗ។ ចំណែកខ្ញុំធ្វើស្រែ ចម្ការនៅក្បែរផ្លូវរថភ្លើង ជាមួយស្ត្រីប្រហែល២០នាក់ ដែលប្តីរបស់គេ សុទ្ធតែជា កម្មករផ្លូវដែកដូចប្តីខ្ញុំដែរ។ យើងបរិភោគអាហារផ្សេងគ្នា ដោយក្រុមរបស់ប្តីខ្ញុំហូបអាហារនៅកន្លែងធ្វើការរបស់គាត់ ចំណែកស្រីៗហូបអាហារនៅតាមអង្គភាពរបស់ខ្លួន។ ពេល នោះខ្ញុំមិនសូវជួបការលំបាកដូចប្រជាជននៅតាមសហករណ៍ ផ្សេងៗទេ ទាំងការស្នាក់នៅ និងរបបអាហារ។ ផ្ទះដែលខ្ញុំ ធ្លាប់បានស្នាក់នៅក្នុងរបបខ្មែរក្រហម គឺប្រក់ស័ង្កសី ចំណែក របបអាហារ គឺខ្ញុំបានហូបបាយជាមួយត្រីៗ មានត្រីជាច្រើន ដែលកងដឹកជញ្ជូនរបស់ខ្មែរក្រហមដឹកមកពីខេត្តពោធិ៍សាត់ យកមកឲ្យកម្មករផ្លូវដែក ហើយក៏បានចែករំលែកដល់ប្រពន្ធ របស់កម្មករផ្លូវដែកទាំងនេះដែរ។ ខ្ញុំនិងប្រពន្ធរបស់កម្មករ ផ្លូវដែកទាំងនោះ មិនដែលទទួលការបង្គាប់បញ្ជា ការបង្ខិតបង្ខំ ឲ្យធ្វើការងារ និងការចាំឃ្លាំមើលពីសំណាក់ឈ្លបខ្មែរក្រហម ទេ។ នៅរដូវវស្សា ខ្ញុំបានចេញទៅសាបព្រោះ ដកស្ទូងដូច ប្រជាជនដទៃ ហើយនៅរដូវប្រាំងចូលមកដល់ ខ្ញុំបានចេញ ទៅកាប់ដើមរពាក់យកមក ក្រងធ្វើចង្អេរ កញ្ជើ និងបង្គី សម្រាប់ឲ្យប្រជាជនប្រើប្រាស់។ ខ្ញុំបានធ្វើការងារផ្សេងៗ ដោយមិនដែលរុញរាឡើយ ព្រោះខ្ញុំជាកូនកសិករ។ ខ្ញុំធ្លាប់ ធ្វើស្រែចម្ការ និងការងារធ្ងន់ៗជាច្រើនទៀតតាំងពីនៅពី ក្មេងៗ។ ខ្ញុំបានភ្ញាក់ពីព្រឹកព្រលឹមចេញទៅកាប់រពាក់ ហើយ ថ្ងៃត្រង់ខ្ញុំត្រូវអង្គុយក្រងដើមរពាក់ធ្វើបង្គីនៅក្រោមម្លប់ឈើ។ ក្នុងក្រុមរបស់ខ្ញុំមានស្រីៗប្រហែល២០នាក់ ហើយផលស្រូវ ដែលយើងប្រមូលបាន គឺទុកហូបសម្រាប់តែអង្គភាពតែ ប៉ុណ្ណោះ។ ពេលនោះ ខ្ញុំមានអាហារហូបចុកគ្រប់គ្រាន់ដោយ សារតែប្តីរបស់ខ្ញុំមានជំនាញបច្ចេកទេសផ្លូវដែកច្បាស់លាស់ ហើយខ្មែរក្រហមត្រូវការគាត់ជាចាំបាច់ ដើម្បីជួសជុលផ្លូវ រថភ្លើងឲ្យដំណើរការបានល្អដូចដែលគេចង់បាន។

ខ្ញុំកម្របានទទួលដំណឹងពីប្រជាជនផ្សេងៗនៅតាមសហ-ករណ៍ ព្រោះខ្មែរក្រហមបានលាក់ការណ៍។ ខ្មែរក្រហមមិន អនុញ្ញាតឲ្យខ្ញុំដើរហើរស្រេចតែចិត្តនោះទេ គឺខ្ញុំរស់នៅតែក្នុង អង្គភាពដែលខ្ញុំធ្វើការតែប៉ុណ្ណោះ។ ខ្មែរក្រហមបានជម្លៀស ប្រជាជនដែលរស់នៅក្នុងសហករណ៍ឲ្យទៅរស់នៅភូមិផ្សេងៗ ប៉ុន្តែមិនបានជម្លៀសប្រជាជនដែលរស់នៅក្នុងអង្គភាពចេញ ទេ។ ខ្ញុំចាំថា ក្នុងរបបខ្មែរក្រហមរថភ្លើងដំណើរការទាំងយប់ ទាំងថ្ងៃ ប៉ុន្តែខ្ញុំមិនដឹងថាខ្មែរក្រហមដឹកអ្វីខ្លះទេនៅក្នុងទូរថភ្លើង នោះ ព្រោះខ្មែរក្រហមបាំងទូរថភ្លើងជិតទាំងអស់។ ប្តីខ្ញុំធ្លាប់ ប្រាប់ខ្ញុំថា នៅពេលដែលគាត់ទៅជួសជុលផ្លូវរថភ្លើង គាត់ ធ្លាប់បានឃើញខ្មែរក្រហមដោតស្លឹកត្រចៀកប្រជាជន រួច បណ្តើរឡើងជិះរថភ្លើងទៅបាត់។ ខ្ញុំក៏មិនបានសួរនាំប្តីខ្ញុំដែរ ព្រោះខ្ញុំខ្លាចមានបញ្ហាដល់ខ្ញុំនិងក្រុមគ្រួសារទាំងមូល។

ប្រជាជនថ្មីដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ មកខេត្តកំពតមិនសូវថ្នឹកនឹងការងារលំបាកៗទេ។ ខ្ញុំឃើញ ប្រជាជនថ្មីតែងតែអង្គុយយំ នៅពេលដែលប្រធានកងប្រើ គាត់ឲ្យទៅកាប់ឬស្សី ហើយមិនយូរប៉ុន្មានប្រជាជនថ្មីទាំង នោះក៏បាត់ខ្លួន។ នៅពេលចូលរួមប្រជុំម្តងៗ ក្រុមរបស់ខ្ញុំតែង តែនិយាយគ្នាពីការបាត់ខ្លួនប្រជាជននៅក្នុងភូមិ និងតែងតែ លួចខ្សឹបប្រាប់តៗគ្នាឲ្យដឹងពីរឿងនេះ។ ជាក់ស្តែង ក្រុមគ្រួសារ របស់លោកតឹក សេងអេង ដែលត្រូវបានជម្លៀសមកពីទីក្រុង ភ្នំពេញ ត្រូវបានខ្មែរក្រហមបញ្ជូនតាមរថភ្លើងយកទៅឃុំ ឃាំងនៅគុកទួលស្លែង។ ខ្ញុំ ស្គាល់ តឹក សេងអេង ប្រពន្ធគាត់ និងកូនៗ ដែលមានរូបសម្ផស្សស្អាតៗ។ ចំណែករឿងរ៉ាវ ផ្សេងៗទៀត ខ្ញុំបានដឹងពីប្រជាជនផ្សេងៗនៅពេលដែលខ្ញុំ បានទៅចូលរួមប្រជុំជីវភាពនៅតាមសហករណ៍។

ខ្ញុំ និងប្តី ព្រមទាំងកូនៗបានត្រឡប់ទៅរស់នៅជួបជុំគ្នា នៅក្រុងភ្នំពេញ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅ ឆ្នាំ១៩៧៩ ហើយប្តីរបស់ខ្ញុំក៏បានចូលធ្វើការងារនៅកន្លែង ចាស់របស់គាត់នៅចំណតរថភ្លើងវិញ។

អ៊ុន សុដាវី

# ប្រជាជនរស់នៅស្រុកអន្លង់វែង រៀបរាប់ពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម

***សម្ភាសន៍ដោយនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង***

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅក្នុងឆ្នាំ១៩៧៩ ប្រទេសកម្ពុជាមិនទាន់ទទួលបានសន្តិភាពនៅឡើយទេ។ ក្រុមខ្មែរក្រហមបានប្រមូលផ្តុំនៅតំបន់អន្លង់វែង ដើម្បីបន្តចលនាតស៊ូប្រឆាំងនឹងរាជរដ្ឋាភិបាល។ អន្លង់វែង គឺជាអតីតតំបន់ដាច់ស្រយាលស្ថិតនៅតាមបណ្តោយជួរភ្នំដងរែក និងគ្រប់គ្រងយ៉ាងរឹងមាំដោយកងយោធារបស់ខ្មែរក្រហមដែលដឹកនាំដោយ តាម៉ុក។ បន្ទាប់ពីកងយោធារបស់ខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល នៅដើមឆ្នាំ១៩៩៩ អតីតមេដឹកនាំខ្មែរក្រហមនិងអតីតកម្មាភិបាលខ្មែរក្រហមភាគច្រើនបានសម្រេចចិត្តបន្តរស់នៅតំបន់អន្លង់វែង ដើម្បីកសាងជីវិតថ្មីរបស់ខ្លួនរហូតដល់បច្ចុប្បន្ន។

សព្វថ្ងៃនេះ នៅពេលដែលរំឭកដល់តំបន់អន្លង់វែង មនុស្សភាគច្រើនតែងតែគិតថាជាតំបន់ដាច់ស្រយាលរបស់ខ្មែរក្រហម និងតំបន់គួរឲ្យភ័យខ្លាច។ ផ្ទុយស្រឡះពីការគិតទាំងនេះ ទឹកដីនៃតំបន់អន្លង់វែងបានផ្លាស់ប្តូរបន្តិចម្តងៗ ពីទីជនបទស្ងាត់ជ្រងំទៅជាកន្លែងមួយដែលកំពុងតែទាក់ទាញប្រជាជនពីតំបន់ផ្សេងៗឲ្យចូលមករស់នៅ និងប្រកបរបររកស៊ីជាបន្តបន្ទាប់ដោយសារតែធនធានធម្មជាតិដ៏សម្បូរបែបក្នុងសហគមន៍នេះ។ ក្រៅពីធនធានទាំងនេះ អន្លង់វែងក៏មានប្រវត្តិសាស្ត្រដ៏គួរឲ្យសង្វេគដែលប្រជាជនបានឆ្លងកាត់។ ខាងក្រោមនេះ គឺជាការរៀបរាប់អំពីបទពិសោធន៍ជីវិតរបស់ប្រជាជនដែលកំពុងតែរស់នៅក្នុងសហគមន៍អន្លង់វែងសព្វថ្ងៃនេះថា តើគាត់បានឆ្លងកាត់ប្រឈមមុខនិងដោះស្រាយបញ្ហាដែលគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហមដូចម្តេចខ្លះ៖

១) រឿងរ៉ាវរបស់ សៅ លីម ភេទប្រុស អាយុ៦៥ឆ្នាំ មានទីកន្លែងកំណើតនៅភូមិត្បែង ស្រុកសន្ទុក ខេត្តកំពង់ធំ។ សព្វថ្ងៃ លីម និងក្រុមគ្រួសារ កំពុងរស់នៅភូមិសន្តិភាព ឃុំត្រពាំង ប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ខ្ញុំតែងតែរំពឹងទុកថា ខ្ញុំនឹងបានត្រឡប់ទៅផ្ទះជួបជុំក្រុមគ្រួសារ និងសាច់ញាតិ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ប៉ុន្តែអ្វីៗដែលបានកើតឡើងបន្ទាប់ពីរបបខ្មែរក្រហមឡើងកាន់កាប់អំណាច គឺផ្ទុយស្រឡះពីការរំពឹងទុករបស់ខ្ញុំទាំងស្រុង។

មុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ខ្ញុំគឺជាអតីតយោធាខ្មែរក្រហមបម្រើការ ក្នុងកងពលលេខ២៥០។ ខ្ញុំសង្ឃឹមថា ការជួយជណ្តើមអំណាចឲ្យខ្មែរក្រហមអាចធ្វើឲ្យប្រទេសជាតិទទួលបានសន្តិភាពឡើងវិញ ប៉ុន្តែនៅពេលដែលរបបខ្មែរក្រហមទទួលបានជ័យជម្នះ នាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៩ ប្រជាជនទាំងអស់ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញក្នុងរយៈពេលប៉ុន្មានម៉ោងតែប៉ុណ្ណោះ។ ចំណែកខ្ញុំ ត្រូវបានខ្មែរក្រហមផ្លាស់ពីភ្នំពេញឲ្យទៅឈរជើងនៅភូមិភាគឦសានវិញ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានចាប់ផ្តើមផ្លាស់ប្តូរមេដឹកនាំមុនៗ។ ការរស់នៅរបស់ប្រជាជនចាប់ផ្តើមរឹតបន្តឹង និងមានការរំលោភបំពានសិទ្ធិសេរីភាពយ៉ាងខ្លាំង។ ការប្រតិបត្តិសាសនា ការសិក្សាអប់រំ ទំនាក់ទំនងគ្រួសារ និងសកម្មភាពផ្សេងៗក៏ត្រូវបានហាមឃាត់ទាំងស្រុង។ ប្រជាជនទទួលរងការធ្វើបាប ការកាប់សម្លាប់ និងធ្វើទារុណកម្ម។ ស្ថានភាពនៃការរស់នៅពីមួយថ្ងៃទៅមួយថ្ងៃកាន់តែជួបការលំបាក គ្មានអាហារហូបគ្រប់គ្រាន់ និងមានការបែកបាក់គ្នា។

ខ្ញុំគិតថា ខ្ញុំគឺជាមនុស្សម្នាក់ដែលមានភ័ព្វសំណាងណាស់

ក្នុងចំណោមប្រជាជនខ្មែរ ដែលរងគ្រោះពីរបបខ្មែរក្រហមៗ នៅពេលដែលខ្ញុំឈឺថ្កាត់ ខ្ញុំត្រូវបានគ្រូពេទ្យមើលថែរក្សា និង យកចិត្តទុកដាក់ ចំណែកឯចំណីអាហារវិញ ខ្ញុំក៏ទទួលបាន គ្រប់គ្រាន់ដែរ។ ប៉ុន្តែ ខ្ញុំមិនធ្លាប់ដែលបានទំនាក់ទំនងមកក្រុម គ្រួសារទេក្នុងអំឡុងរបបខ្មែរក្រហមៗ ដំណឹងដំបូងដែលខ្ញុំ ទទួលបានពីគ្រួសាររបស់ខ្ញុំ គឺសមាជិកក្នុងក្រុមគ្រួសាររបស់ ខ្ញុំម្នាក់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយសារលួច កាស់ដំឡូងរបស់អង្គការ។

រហូតមកដល់ឆ្នាំ១៩៩៩ ខ្ញុំ និងក្រុមគ្រួសារ ក៏បានជួប ជុំគ្នាវិញ រួចហើយក៏សម្រេចចិត្តមិនត្រឡប់ទៅស្រុកកំណើត នៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំវិញទេ ដោយសម្រេចចិត្ត ចាប់ផ្តើមកសាងជីវិតថ្មីនៅក្នុងភូមិសន្តិភាព ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យរហូតដល់សព្វថ្ងៃនេះ។

(២) រឿងរ៉ាវរបស់ ដោ សារ៉ាន់ ភេទប្រុស អាយុ៥០ឆ្នាំ សព្វថ្ងៃរស់នៅភូមិសន្តិភាព ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ខ្ញុំមានស្រុកកំណើតនៅភូមិក្រាំងឈើនាងឃុំត្បែងទៀន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ បន្ទាប់ពីរបបសាធារណ-រដ្ឋខ្មែរបានដួលរលំ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យមករស់ នៅក្នុងភូមិវាលកណ្តាល ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្ត កណ្តាល។ នៅពេលនោះ ខ្ញុំទើបតែមានអាយុត្រឹមតែ៧ឆ្នាំ តែប៉ុណ្ណោះ។ ខ្ញុំត្រូវបានបំបែកចេញពីគ្រួសារ និងទៅរស់នៅ ក្នុងកងកុមារជាមួយកុមារដទៃជាច្រើននាក់ទៀត ដែលស្ថិត ក្រោមការគ្រប់គ្រង និងមើលថែពីមនុស្សចាស់ក្នុងកងនោះ។ នៅក្នុងរបបខ្មែរក្រហម កុមារក៏ត្រូវតែធ្វើការងារដែរ។ ខ្មែរ ក្រហមបានបញ្ជាឲ្យខ្ញុំកាប់អុស កាប់ដើមទន្ទ្រានខែត្រ និងដើរ រើសអាចម៍គោដើម្បីធ្វើជាជីសម្រាប់ដាក់ស្រែ និងធ្វើការងារ ផ្សេងៗទៀតជាច្រើន។ ខ្ញុំចាំបានថា ការរស់នៅរបស់ប្រជាជន នៅក្នុងសម័យនោះ គឺពិតជាលំបាកខ្លាំងណាស់។ មនុស្សវ័យ ចំណាស់ ត្រូវបានខ្មែរក្រហមប្រើឲ្យមើលក្មេងតូចៗ និងការងារ ស្រាលៗជាច្រើនទៀត។ ចំណែកឯមនុស្សដែលមានអាយុ ចាប់ពីអាយុ១៣ ដល់២៥ឆ្នាំ ត្រូវបានខ្មែរក្រហមជ្រើសរើស ឲ្យទៅធ្វើការងារធ្ងន់ៗជាច្រើន ដូចជា លើកទំនប់ ជីកប្រឡាយ និងធ្វើស្រែចម្ការ។ ប្រជាជនខ្លះទៀតត្រូវបានខ្មែរក្រហមចាត់ ឲ្យទៅធ្វើជាកងទ័ពដែរ។ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជន ធ្វើការងារលើសពី៨ម៉ោងក្នុងមួយថ្ងៃ ដោយមិនអនុញ្ញាត ឲ្យឈប់សម្រាកឡើយ ដើម្បីឲ្យសម្រេចបានលទ្ធផលតាម គោលការណ៍ដែលបានព្រៀងទុក។ ចំពោះអ្នកដែលធ្វើការងារ មិនទាន់តាមផែនការកំណត់ ត្រូវក្រុមឈ្លបខ្មែរក្រហមបាន រាយការណ៍ទៅថ្នាក់លើ និងយកទៅកសាង ឬសម្លាប់ចោល។ ឪពុកម្តាយរបស់ខ្ញុំ ត្រូវបានក្រុមខ្មែរក្រហមយកទៅសម្លាប់ ចោលនៅពេលគាត់កំពុងតែលើកទំនប់។ ខ្មែរក្រហមបានចោទ គាត់ថាជារនុកក្នុង ព្រោះតែឪពុក ម្តាយរបស់ខ្ញុំធ្វើការមិនរួច រាល់តាមការកំណត់របស់ខ្មែរក្រហមដែលបានកំណត់ឲ្យធ្វើ។ បើទោះបីជាឪពុកម្តាយរបស់ខ្ញុំបានស្លាប់ទៅហើយក្តី ក៏ខ្ញុំនៅ តែបន្តរស់ក្នុងមណ្ឌលកុមារដដែល។

នៅក្នុងរបបខ្មែរក្រហម ទោះបីជាធ្វើការងារធ្ងន់យ៉ាង ណា ប៉ុន្តែរបបអាហារគឺទទួលបានត្រឹមតែបបរលាយជាមួយ ដើមផ្ទី និងពោតក្រហម ដែលបបរនោះគឺមានអង្ករត្រឹមតែ២ ទៅ៣កំប៉ុងប៉ុណ្ណោះក្នុងមួយខ្ទះត្នោត។ ការធ្វើការហួសកម្លាំង និងការបរិភោគមិនគ្រប់គ្រាន់បានធ្វើឲ្យប្រជាជនជាច្រើននាក់ ប្រឈមនឹងការឈឺថ្កាត់ និងឈានទៅដល់ការបាត់បង់ជីវិត ជាបន្តបន្ទាប់។

ខ្ញុំពិតជាមានអារម្មណ៍ខឹងរាល់ពេលដែលនឹកឃើញរបប ខ្មែរក្រហមម្តងៗ។ ខ្មែរក្រហមបានរឹបអូសយកសម្ភារៈ ឬទ្រព្យ សម្បត្តិផ្សេងៗ ដាក់ធ្វើជាកម្មសិទ្ធិរួម។ ចំណែកឯទិន្នផល ដែលទទួលបានពីស្រែចម្ការ ខ្មែរក្រហមបានប្រមូលយកទាំង អស់ រីឯអ្នកបញ្ចេញកម្លាំងពលកម្មនិងខិតខំ ធ្វើនោះគឺទទួល បានត្រឹមតែភាពនឿយហត់ប៉ុណ្ណោះ។ ម្យ៉ាងទៀត សម្រាប់ ការជ្រើសរើសគូស្រករវិញគឺ អង្គការបានចាត់ឲ្យមានការ រៀបការចាប់ពី៣០ ទៅ៥០គូ ក្នុងមួយលើក ដែលភាគីទាំង សងខាងសឹងតែមិនធ្លាប់ស្គាល់គ្នា។ យើងអាចនិយាយបានថា

នេះជាការរៀបការដោយបង្ខំ។ ក្រោយពិធីរៀបការ ប្រសិនបើគូស្នេហ៍ណាដែលមិនចុះសម្រុងគ្នា ហើយត្រូវកងឈ្លបស៊ើបដឹង គឺត្រូវទទួលទោស។ ដូច្នេះហើយ ទើបមិនមាននរណាម្នាក់ហ៊ានប្រកែកតវ៉ា ឬហ៊ានបង្ហាញពីភាពមិនពេញចិត្តចំពោះមុខអង្គការឡើយ។

ខ្ញុំពិតរីករាយណាស់នៅពេលដែលប្រទេសកម្ពុជាបានរួចផុតពីរបបដ៏ឃោរឃៅនេះ។ ខ្ញុំសូមផ្តាំផ្ញើទៅកាន់អ្នកជំនាន់ក្រោយៗ ធ្វើយ៉ាងណាកុំឲ្យប្រទេសជាតិធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមដូចទៅនឹងរបបខ្មែរក្រហមទៀត។

៣)រឿងរ៉ាវរបស់ សាំង សារីន ភេទស្រី អាយុ៥៩ឆ្នាំ មានទីកន្លែងកំណើតនៅភូមិអូរក្រពើ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ និងសព្វថ្ងៃរស់នៅក្នុងភូមិសន្តិភាព ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ខ្ញុំបានចងចាំថា នៅពេលដែលខ្មែរក្រហមវាយបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៥ឆ្នាំ។ ខ្ញុំ និងប្រជាជនដទៃទៀតបានចូលរួមអបអរសាទរ និងសប្បាយរីករាយខ្លាំងណាស់ចំពោះជ័យជម្នះនេះ ព្រោះយើងសង្ឃឹមថា សង្គ្រាមត្រូវបានបញ្ចប់។ ប៉ុន្តែមិនយូរប៉ុន្មាន ខ្ញុំនិងប្រជាជនផ្សេងទៀត ត្រូវបានជម្លៀសចេញពីទីកន្លែងដែលកំពុងតែរស់នៅ។ ការជម្លៀសនេះ គឺដើម្បីធ្វើការបង្កបង្កើនផល និងធ្វើការងារដើម្បីផ្គត់ផ្គង់ដល់វិស័យកសិកម្មផ្សេងៗ ដូចជា លើកទំនប់ និងជីកប្រលាយជាដើម។

ទោះបីជាធ្វើការងារធ្ងន់ធ្ងរយ៉ាងណា ខ្ញុំទទួលបានត្រឹមតែបបររាវលាយជាមួយបន្លែតែប៉ុណ្ណោះ។ ខ្ញុំអាចតស៊ូបានគ្រប់ការងារទាំងអស់ទោះបីវាជាការងារដែលលំបាកយ៉ាងណាក៏ដោយ ពីព្រោះខ្ញុំជាអ្នកធ្វើស្រែចម្ការ។

នៅឆ្នាំ១៩៧៦ ការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងវៀតណាម កាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ដោយបានធ្វើឲ្យមនុស្សស្លាប់ជាច្រើននាក់។ ខ្ញុំ និងក្រុមគ្រួសារ ភ័យខ្លាចយ៉ាងខ្លាំង និងបានសម្រេចចិត្តរត់ចូលទៅក្នុងព្រៃ រួចហើយបានធ្វើដំណើររហូតមកដល់ទឹកដីអន្លង់វែង និងបានបន្តការរស់នៅក្នុងតំបន់នេះអស់មួយរយៈ។ ក្នុងកំឡុងពេលនៃការស្នាក់នៅរបស់ខ្ញុំនៅតំបន់អន្លង់វែង ការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហមតែងតែកើតមាន ដូច្នេះប្រជាជនដែលរស់នៅក្នុងតំបន់អន្លង់វែងទាំងអស់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យឡើងលើភ្នំ និងបញ្ជូនឲ្យទៅរស់នៅជំរំនៅក្នុងទឹកដីប្រទេសថៃ។ ជាអកុសលនៅតាមផ្លូវធ្វើដំណើរទៅកាន់ជំរំ ប្អូនប្រុសរបស់ខ្ញុំបានស្លាប់ដោយសារជាន់មីន។ ខ្ញុំ និងម្តាយ


ផ្ទះរបស់ប្រជាជនក្នុង

ព្រមទាំងប្អូនៗចំនួនពានាក់ទៀតនៅតែខិតខំធ្វើដំណើរទៅមុខទៀតរហូតដល់ជំរំគ-៧ (ដងទង់) ក្នុងទឹកដីនៃប្រទេសថៃជាមួយប្រជាជនជាច្រើន។ ខ្ញុំ និងក្រុមគ្រួសារបានបន្តរស់នៅក្នុងជំរំជនភៀសខ្លួនអស់រយៈពេល៥ឆ្នាំដោយតែងតែនឹកគិតនិងព្រួយបារម្ភជានិច្ចចំពោះសុវត្ថិភាពបងស្រីរបស់ខ្ញុំដែលធ្វើការងារនៅក្នុងកងជីកជញ្ជូនរបស់ខ្មែរក្រហមនៅតាមសមរភូមិនៅក្នុងទឹកដីខ្មែរ។

នៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានរៀបការជាមួយបុរសម្នាក់ឈ្មោះ ហេង សារិ និងមានកូនចំនួន ៣នាក់។ នៅក្នុងកំឡុងឆ្នាំ១៩៨១ ខ្មែរក្រហមបានបញ្ជូនប្រជាជនដែលរស់នៅតាមព្រំដែន និងជំរំទាំងអស់ឲ្យត្រឡប់មកតំបន់អន្លង់វែងវិញ។ ក្នុងកំឡុងពេលនោះតំបន់អន្លង់វែងបានស្ថិតក្នុងភាពវឹកវរយ៉ាងខ្លាំង ដែលនេះជាមូលហេតុបណ្តាលឲ្យខ្ញុំនិងប្តីត្រូវបានបែកបាក់គ្នា។ ក្រោយមកនៅឆ្នាំ១៩៨៩ សង្គ្រាមបានបន្តរភាព




រីករាលកាន់តែខ្លាំងឡើងៗនៅតំបន់អន្លង់វែង។ ប្អូនប្រុសរបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យធ្វើកងការពារព្រំដែន ចំណែកខ្ញុំ និងក្រុមគ្រួសារ បានរត់ភៀសខ្លួនទៅកាន់ជំរំជនភៀសខ្លួនភូណយ នៅក្នុងទឹកដីថៃម្តងទៀត ដោយទទួលបានជំនួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ។ ខ្ញុំបានត្រឡប់មករស់នៅក្នុងទឹកដីអន្លង់វែងជាប់តាំងជាប់តាំងពីឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន។

៤) រឿងរ៉ាវរបស់ ទិត្យ រើន ភេទស្រី អាយុ៦០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិសន្តិភាព ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ខ្ញុំ គឺជាកូនទី២ក្នុងចំណោមបងប្អូន៣នាក់។ ឪពុករបស់ខ្ញុំឈ្មោះ មិន ទិត្យ និងម្តាយរបស់ ខ្ញុំឈ្មោះ យិន សៅ។ ខ្ញុំមានស្រុកកំណើតនៅភូមិអាងខ្មៅ ឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ។

មុនពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច គ្រួសាររបស់ខ្ញុំ គឺជាគ្រួសារកសិករមួយដែលមានជីវភាពមធ្យម។ នៅកំឡុងឆ្នាំ១៩៧០ ពេលដែលធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង ខ្ញុំមានអាយុត្រឹមតែ១១ឆ្នាំតែប៉ុណ្ណោះ។ ប្រទេសជាតិបានចាប់ផ្តើមកើត ភាពវឹកវរចលាចល ដោយសារតែការដណ្តើមអំណាចគ្នា។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឮថាខ្មែរក្រហមបានផ្តួលរំលំរបប លន់ នល់ និងឡើងកាន់កាប់អំណាចទាំងស្រុង នៅក្នុងប្រទេសកម្ពុជា។ ចំណែកឯទីក្រុងភ្នំពេញ ត្រូវបានខ្មែរក្រហមកាន់កាប់ទាំងស្រុងនិងបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងទាំងអស់។ ហេតុការណ៍នៅតាមខេត្តផ្សេងៗក៏មិនសូវខុសគ្នាពីទីក្រុងប៉ុន្មានដែរ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីប្រជុំជនឲ្យទៅរស់នៅទីកន្លែងផ្សេងៗតាមទីជនបទដាច់ស្រយាល។ ខ្ញុំនិងក្រុមគ្រួសារពិតជាសំណាងណាស់ ព្រោះយើងមិនត្រូវបានខ្មែរក្រហមជម្លៀសឲ្យចាកចេញពីភូមិឋានទេ។ នៅពេលដែលខ្មែរក្រហមចូលមកដល់កន្លែងដែលខ្ញុំរស់នៅខ្ញុំមានអាយុប្រហែល១៧ឆ្នាំ ជាវ័យដែលខ្មែរក្រហមចាត់ទុកថានៅក្នុងក្រុមយុវជន ដោយខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការងារជាច្រើនដូចជា ដកសំណាប ស្ទូងស្រូវ និងលើកទំនប់ ដែលការងារទាំងអស់នេះគឺមានកម្លាំងមនុស្សជាច្រើននាក់បានចូលរួមធ្វើ។ ប្រជាជនទាំងអស់ធ្វើការដោយមិនមានពេលសម្រាកឡើយ គឺអាចសម្រាកបានក្នុងកំឡុងពេលហូបអាហារតែប៉ុណ្ណោះ។ ចំពោះរបបអាហារក្នុងរបបខ្មែរក្រហម ក៏ប្រជាជនទទួលបានមិនគ្រប់គ្រាន់ដែរ ដោយក្នុង

មួយថ្ងៃ ប្រជាជនអាចទទួលបានអាហារតែ២ពេលប៉ុណ្ណោះ ដែលក្នុងមួយពេលៗទទួលបានបបរចំនួនពីរវែកតែប៉ុណ្ណោះៗ ការធ្វើការងារហួសកម្លាំង និងការបរិភោគមិនគ្រប់គ្រាន់បានធ្វើឲ្យប្រជាជនជាច្រើនធ្លាក់ខ្លួនឈឺជាទម្ងន់ និងស្លាប់ជាបន្តបន្ទាប់ៗ ប្អូនស្រីរបស់ខ្ញុំត្រូវបានចាត់តាំងចូលធ្វើការងារក្នុងកងកុមារ ដែលពេលនោះនាងបានចូលរៀនថ្នាក់ទី១ៗ គ្រូបានឲ្យនាងសូត្រព្យញ្ជនៈខ្មែរ និងរៀនច្រៀងបទចម្រៀង «១៧ មេសា មហាជោគជ័យ» ជាប្រចាំថ្ងៃៗ ក្រៅពីការងាររៀនសូត្រ ខ្មែរក្រហមបានបញ្ជាឲ្យប្អូនស្រីរបស់ខ្ញុំ និងកុមារដទៃទៀតកាប់ដើមទន្ទ្រានខែត្រ រើសអាចម៍គោ និងស្មៅ ដើម្បីធ្វើជាជីសម្រាប់ដាក់ស្រែៗ

ថ្ងៃមួយខ្ញុំនិងសមាជិកគ្រួសារទាំងអស់ត្រូវបានអង្គការចោទប្រកាន់ថាជាខ្មាំង ព្រោះអង្គការគិតថាឪពុករបស់ខ្ញុំធ្លាប់ប្រកបរបរជាអ្នកលក់ដូរៗ ជាសំណាងល្អ ប្រធានឃុំឈ្មោះ សំ ដែលស្គាល់គ្នាជាមួយឪពុករបស់ខ្ញុំបាននិយាយប្រាប់កងឈ្លបខ្មែរក្រហមថា ឪពុករបស់ខ្ញុំមិនមែនជានាយទុនរកស៊ីអ្វីទេៗ បន្ទាប់មកកងឈ្លបទាំងអស់ក៏បានធ្វើដំណើរចាកចេញទៅៗ

នៅឆ្នាំ១៩៧៧ ខ្ញុំបានឃ្លាតឆ្ងាយពីក្រុមគ្រួសារ ដោយអង្គការបានផ្លាស់ប្តូរទីកន្លែងធ្វើការងាររបស់ខ្ញុំទៅកាន់ភូមិផ្សេងទៀតក្នុងខេត្តតាកែវ ដែលគ្រប់គ្រងដោយមេក្រុមឈ្មោះ ផាចៗ ការងារចម្បងនៅក្នុងភូមិរបស់ខ្ញុំ គឺការដកស្ទូង និងជីកប្រឡាយ ដោយក្នុងមួយក្រុមមានសមាជិកចំនួន១២នាក់ ដែលក្នុងមួយក្រុមត្រូវស្ទូងឲ្យបានចំនួន ៥ហិចតាក្នុងរយៈពេល២៥ថ្ងៃៗ ខ្ញុំបានខិតខំបំពេញការងារដែលអង្គការបានចាត់តាំងរហូតស្គមសល់តែស្បែកគ្របដណ្តប់ឆ្អឹង និងបន្ទាប់មកខ្ញុំបានធ្លាក់ខ្លួនឈឺៗ ខ្ញុំត្រូវបាន ផាច ដែលជាមេក្រុមបង្ខំឲ្យទៅធ្វើការងារបន្តទៀត ពេលខ្ញុំកំពុងឈឺៗ ក្នុងថ្ងៃនោះនៅពេលចុះទៅដល់ក្នុងវាលស្រែ ខ្ញុំបានងងឹតមុខដួលកប់ភក់ ប៉ុន្តែសំណាងល្អបានសមមិត្ត តេង និងសមមិត្ត សោម ដែលជាអ្នកធ្វើការជាមួយគ្នារត់មកជួយ លើកនិងលុបមុខលាងខ្លួនឲ្យខ្ញុំៗ នៅព្រឹកបន្ទាប់ ខ្ញុំបានដឹងខ្លួនឡើងវិញ ហើយត្រូវបានទទួលការស្តីបន្ទោសពីមេក្រុមយ៉ាងខ្លាំងថា «មិត្តឯងខ្ជិលខ្លាំងណាស់ ធ្វើពុតជាឈឺបែបនេះ ប្រយ័ត្នកង់ប្រវត្តិសាស្ត្រកិនបែកក្បាល»ៗ ទោះបីជាត្រូវទទួលការស្តីបន្ទោស ខ្ញុំនៅតែសម្រាកព្យាបាលព្រោះមិនអាចទៅធ្វើការងារបានៗ ខ្ញុំបានលេបថ្នាំម្យ៉ាងដែលមានរូបរាងដូចអាចម៍ទន្សាយ និងបានជាសះស្បើយបន្ទាប់ពីសម្រាកព្យាបាលរយៈពេល៣ថ្ងៃៗ

ថ្ងៃមួយ ខ្ញុំបានទៅសួរសុខទុក្ខក្រុមគ្រួសាររបស់ខ្ញុំ និងត្រូវបានកងឈ្លបចោទថា ជាខ្មាំងគេចវេះពីការងារ ហើយបានចាប់ខ្លួននិងបញ្ជូនខ្ញុំទៅភូមិអាងខ្មៅ ដែលជាភូមិកំណើតរបស់ខ្ញុំវិញៗ បន្ទាប់ពីធ្វើការងារដកស្ទូងរួច ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់កងនារីដឹកជញ្ជូនស្បៀងអាហារ និងសព្វាវុធឲ្យយោធាខ្មែរក្រហមដែលប្រយុទ្ធនៅសមរភូមិៗ

នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំបានត្រឡប់មករស់នៅស្រុកកំណើតវិញ ប៉ុន្តែបងប្រុសរបស់ខ្ញុំបានស្លាប់ដោយសារតែជំងឺគ្រុនចាញ់ និងគ្មានអាហារបរិភោគគ្រប់គ្រាន់ៗ

នៅពេលដែលរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយសារកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពរបស់វៀតណាម ខ្ញុំនិងក្រុមគ្រួសារ បានត្រឡប់មករស់នៅស្រុកកំណើតវិញ រហូតដល់ឆ្នាំ១៩៩៩ៗ បន្ទាប់មក ខ្ញុំនិងក្រុមគ្រួសារក៏បានសម្រេចចិត្តមករស់នៅទឹកដីអន្លង់វែងវិញ ដោយយល់ឃើញថាតំបន់នេះមានដីធ្លីធំទូលាយដែលអាចប្រកបរបរធ្វើស្រែចម្ការបានៗ

៥) រឿងរ៉ាវរបស់ ជុំ វង់ ភេទប្រុស អាយុ៧១ឆ្នាំ មានទីកន្លែងកំណើតនៅខេត្តកំពត និងសព្វថ្ងៃរស់នៅក្នុងភូមិអូរុន ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យៗ

ខ្ញុំមានអាយុប្រហែល២៨ឆ្នាំ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ៗ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនមកធ្វើជាកងទ័ពៗ ដំបូងខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅធ្វើការហ្វឹកហាត់ លត់ដំ និងបន្ទាប់មកក៏បញ្ជូនខ្ញុំឲ្យទៅប្រយុទ្ធនៅសមរភូមិតែម្តងៗ ខ្ញុំបាន

ហ៊ឺកហាត់តាំងពីព្រលឹមរហូតដល់ថ្ងៃរសៀលជាមួយកងទ័ពដទៃទៀត ទើបមេទ័ពខ្មែរក្រហមអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកហូបបាយ និងបន្តការហ៊ឺកហាត់ដល់ល្ងាចទើបអាចឈប់សម្រាកហូបបាយល្ងាចម្តងទៀត។ ប្រជាជនដែលរស់នៅក្នុងតំបន់ដែលខ្ញុំបានរស់នៅ ត្រូវបានខ្មែរក្រហមបែងចែកជា៣ក្រុម គឺក្រុមកុមារ ក្រុមវ័យជំទង់ និងក្រុមមនុស្សចាស់ជរា។ ប្រជាជនទាំងអស់នៅតាមសហករណ៍ ត្រូវបានអង្គការបញ្ជាឲ្យលើកទំនប់ ជីកប្រឡាយ និងបង្កបង្កើនផល។ ចំណែកឯពេលវេលាធ្វើការងារគឺចាប់ផ្តើមពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់ទើបអាចឈប់សម្រាកដើម្បីបរិភោគអាហារ។ បន្ទាប់មកប្រជាជនត្រូវចាប់ចុះធ្វើការងារបន្តរហូតដល់ម៉ោង៥ល្ងាច។ ចំពោះរបបអាហារវិញ ពេលខ្លះប្រជាជនបរិភោគបាយនិងពេលខ្លះទៀត ប្រជាជនត្រូវហូបបបររាវស្ទើរតែគ្មានគ្រាប់អង្ករ។ ប៉ុន្តែខ្ញុំដែលជាកងទ័ព ការបរិភោគមានគ្រប់គ្រាន់ ហើយរៀងរាល់ពីរសប្តាហ៍ម្តង ចុងភៅតែងតែធ្វើបង្អែមសម្រាប់ឲ្យក្រុមកងទ័ព បរិភោគ។

នៅកំឡុងឆ្នាំ១៩៧៦ ខ្ញុំត្រូវបានអង្គការរបស់ខ្មែរក្រហមផ្សំផ្គុំឲ្យរៀបការជាមួយនារីម្នាក់។ ការផ្សំផ្គុំរៀបអាពាហ៍ពិពាហ៍នេះ កើតឡើងដោយការរៀបជាគូ ដែលមានចាប់ពី១០គូរហូត ដល់១០០គូ។ ក្រោយពីរៀបការហើយ អង្គការបានអនុញ្ញាតឲ្យខ្ញុំ និងគូផ្សេងទៀតរស់នៅជុំប្តីប្រពន្ធរយៈពេលត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ។ បន្ទាប់ពីរួមរស់ជាមួយប្រពន្ធរបស់ខ្ញុំអស់រយៈពេល ៣ថ្ងៃ យើងបានបែកផ្លូវគ្នា ដើម្បីទៅបម្រើការងាររៀងៗខ្លួន។ មួយរយៈក្រោយមក ខ្ញុំបានធ្លាក់ខ្លួនឈឺ ហើយត្រូវបានពេទ្យខ្មែរក្រហមមកព្យាបាលយ៉ាងយកចិត្តទុកដាក់ និងត្រូវបានខ្មែរក្រហមឲ្យពេលឈប់សម្រាកពីការងារហ៊ឺកហាត់រហូតដល់ជាសះស្បើយ។

នៅឆ្នាំ១៩៧៧ កងកម្លាំងរបស់ខ្មែរក្រហមបានប៉ះទង្គិចជាមួយកងទ័ពវៀតណាមនៅតាមបណ្តោយព្រំដែនជាញឹកញាប់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានផ្តួលរលំដោយកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម។ លុះមកដល់ឆ្នាំ១៩៨១ ខ្ញុំ និងប្រជាជនជាច្រើននាក់ទៀតត្រូវបានអំណាចបញ្ជូនឲ្យត្រឡប់មកស្រុកកំណើតវិញ។ បើទោះជាប្រទេសជាតិបានរំដោះទៅហើយក្តី ក៏យោធាខ្មែរក្រហមដែលនៅសេសសល់នៅតែបន្តអុកឡុក និងប្រមូលផ្តុំបង្កើតជាចលនាតស៊ូជាបន្តបន្ទាប់។ នៅឆ្នាំ១៩៨៩ ខ្ញុំបាននាំក្រុមគ្រួសារមកកាន់តំបន់អន្លង់វែង ប៉ុន្តែក្នុងខណៈពេលនោះ ទឹកដីអន្លង់វែងកំពុងស្ថិតក្នុងស្ថានភាពវឹកវរយ៉ាងខ្លាំង។ ខ្ញុំ និងក្រុមគ្រួសារត្រូវបានកម្លាំងខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅក្នុងជំរំក្នុងទឹកដីប្រទេសថៃ។ ប្រជាជនទាំងអស់ដែលរស់ក្នុងទឹកដីថៃ ត្រូវបានផ្គត់ផ្គង់និងទំនុកបម្រុង គ្រឿងឧបភោគ បរិភោគដោយអង្គការសហប្រជាជាតិ។ នៅឆ្នាំ១៩៩០ ឪពុកម្តាយរបស់ខ្ញុំ បានស្លាប់បាត់បង់ជីវិត។ នៅឆ្នាំ១៩៩៨ ខ្ញុំក៏បានត្រឡប់មកពីប្រទេសថៃមករស់នៅក្នុងទឹកដីអន្លង់វែងរហូតដល់សព្វថ្ងៃនេះ។

**អ៊ុន សុដាវី**



កុមារនៅក្នុងសហគមន៍អន្លង់វែង។

# ផ្កា «ខេមីលា» ជាតំណាងឲ្យសន្តិភាព យុត្តិធម៌ និងការរស់ឡើងវិញ នៅកោះជេជូ

ផ្កា «ខេមីលា» គឺជាផ្កាមួយប្រភេទដែលមានពណ៌ចម្រុះ ដុះនៅតាមព្រៃភ្នំ និងរីកស្គុះស្គាយនៅក្នុងរដូវត្រជាក់ៗ ផ្កានេះក៏បានដុះនៅតាមតំបន់ព្រៃភ្នំនៅលើកោះជេជូនៃប្រទេសកូរ៉េខាងត្បូងដែរៗ «ផ្កាខេមីលា» ចាប់ផ្តើមដុះឡើងវិញនៅពេលដែលនិទាឃរដូវបានចូលមកដល់ បន្ទាប់មកក៏ចាប់ផ្តើមរីកនៅក្នុងកំឡុងខែមេសាៗប្រជាជននៅលើកោះជេជូ បានហៅផ្កា «ខេមីលា» ជាភាសាកូរ៉េថា «ផ្កាដុងបែក» ដែលផ្កានេះគឺជាជីវិត និងការចាប់កំណើត ហើយក៏តំណាងឲ្យសន្តិភាព យុត្តិធម៌ និងការរស់ឡើងវិញនៃកោះជេជូដែរៗ

«ផ្កាខេមីលា» បានបង្កប់នូវអត្ថន័យយ៉ាងជ្រាលជ្រៅសម្រាប់ប្រជាជនកូរ៉េដែលរស់នៅលើកោះជេជូៗ ផ្កានេះ មិនត្រឹមតែជាការតំណាងឲ្យសេចក្តីស្លាប់របស់ប្រជាជនកូរ៉េនៅលើកោះជេជូនោះទេ ប៉ុន្តែវាបានដើរតួនាទីជាអ្នកជួយរំឭកអំពីប្រវត្តិសាស្ត្ររបស់កោះជេជូ ចំពោះការតស៊ូ ការលះបង់ និងការស្លាប់របស់ប្រជាជនកូរ៉េនៅលើកោះជេជូ នៅក្នុងកំឡុងពេលនៃការបះបោររបស់ក្រុមកុម្មុយនីស្តប្រឆាំងនឹងរដ្ឋាភិបាលនៅលើកោះជេជូនៃប្រទេសកូរ៉េខាងត្បូង នាថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៤៨ៗ ចលនានៃការបះបោរនេះ បានប្រែក្លាយកោះជេជូពីទីកន្លែង ដែលធ្លាប់តែស្ងៀមស្ងាត់ និងមានបរិយាកាសស្រស់ស្អាតទៅជាគុកសម្រាប់ឃុំឃាំង និងជាកន្លែងសម្រាប់ធ្វើទារុណកម្មមនុស្ស ថែមទាំងជាវាលពិឃាដយ៉ាងសាហាវព្រៃផ្សៃនៅក្នុងប្រទេសកូរ៉េខាងត្បូងៗ ការសម្លាប់រង្គាលបាន



ផ្កាខេមីលា

កើតឡើងនៅលើកោះជេជូនៅក្នុងកំឡុងពេលដែលរដ្ឋាភិបាលនៃប្រទេសកូរ៉េខាងត្បូង បានធ្វើយុទ្ធនាការប្រឆាំងនឹងក្រុមកុម្មុយនីស្ត ដើម្បីបង្ក្រាបការបះបោររបស់ប្រជាជនដែលរស់នៅលើកោះជេជូ រហូតឈានទៅដល់ការចាប់ឃុំឃាំង ការបង្អត់អាហារ និងការសម្លាប់ដោយមិនលើកលែងរួមមានទាំងក្មេង និងមនុស្សចាស់។ មូលហេតុចម្បងនៃការបះបោរនេះ គឺពាក់ព័ន្ធនឹងការបោះឆ្នោតដែលគ្រោងធ្វើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៤៨ ដើម្បីរៀបចំឡើងដោយគណៈកម្មការបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសកូរ៉េ ដើម្បីបង្កើតរដ្ឋាភិបាលថ្មីមួយសម្រាប់ប្រទេសកូរ៉េទាំងពីរ។ ការបោះឆ្នោតត្រូវបានគ្រោងសម្រាប់ភាគខាងត្បូងនៃប្រទេសដែលពាក់កណ្តាលនៃឧបទ្វីបកូរ៉េស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសកូរ៉េ។ ដោយភ័យខ្លាចថា ការបោះឆ្នោតនឹងពង្រឹងកងពលធំបន្ថែមទៀត ក្រុមយុទ្ធជនបានប្រតិកម្មយ៉ាងហិង្សា ដោយធ្វើការវាយប្រហារទៅលើក្រុមប៉ូលីសក្នុងស្រុក និងក្រុមយុវជនស្តាំនិយម ដែលឈរជើងនៅលើកោះជេជូ។

រឿងរ៉ាវស្រដៀងគ្នាអំពីព្រឹត្តិការណ៍នៃការបះបោរនេះ ក៏បានកើតឡើងនៅក្នុងប្រទេសកម្ពុជាដែរ។ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមអាណានិគមរបស់បារាំងអស់រយៈពេលប្រហែលជិត១សតវត្សរ៍។ ក្នុងកំឡុងពេលនៃការគ្រប់គ្រងរបស់បារាំង ប្រជាជនកម្ពុជាបានទទួលរងការគាបសង្កត់ ការធ្វើបាប ការបំបិតសិទ្ធិសេរីភាព និងរស់នៅយ៉ាងលំបាកលំបិន។ ដោយមិនអាច ស៊ូទ្រាំ និងប្រឈមមុខជាមួយនឹងបញ្ហាទាំងអស់នេះបាន ប្រជាជនកម្ពុជាមួយចំនួនរួមមានព្រះសង្ឃ មន្ត្រីរាជការ ក៏ដូចជាប្រជាជនសាមញ្ញ បានចាប់ផ្តើមធ្វើការបះបោរប្រឆាំងនឹងបារាំង ដើម្បីទាមទារសិទ្ធិសេរីភាពរបស់ខ្លួនត្រឡប់មកវិញ។ តែជាលទ្ធផល ចលនានៃការបះបោរតស៊ូប្រឆាំងនឹងបារាំង បានទទួលរងការប៉ះទង្គិចដែលបានបណ្តាលឲ្យប្រជាជនស្លាប់ ហើយអ្នកដែលដឹកនាំចលនាបះបោរនោះ បានទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរ។ បារាំងបានចាប់អ្នកបះបោរទៅដាក់នៅក្នុងគុកដែលស្ថិតនៅលើកោះដាច់ស្រយាលមួយ ឈ្មោះថាកោះត្រឡាច។ នៅក្នុងសម័យអាណានិគមបារាំងកោះត្រឡាចគឺជាកោះមួយដ៏ស្រស់ស្អាតស្ថិតក្នុងទិសនិរតីនៃប្រទេសកម្ពុជា បន្ទាប់មកត្រូវបានប្រែក្លាយជាគុកឧក្រិដ្ឋជាកន្លែងធ្វើទារុណកម្មដ៏ឃោរឃៅនិងជាកន្លែងសម្លាប់មនុស្សដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងហេតុការណ៍ដែលបានកើតឡើងនៅលើកោះជេជូនៃប្រទេសកូរ៉េខាងត្បូងដែរ។ ប្រជាជនជាច្រើននាក់ត្រូវបានបារាំងចាប់ខ្លួនយកទៅឃុំឃាំងនៅលើកោះត្រឡាច ដោយបានបង្ខំឲ្យធ្វើការងារដូចជាទាសករ ថែមទាំងធ្វើទារុណកម្ម និងសម្លាប់ដោយផ្ទាល់ និងដោយប្រយោល។

កោះត្រឡាច និងកោះជេជូ សុទ្ធសឹងតែជាកោះដ៏ស្រស់ស្អាត មានភាពស្ងប់ស្ងាត់ និងស្ថិតនៅដាច់ឆ្ងាយពីគេ ប៉ុន្តែកោះទាំងពីរនេះ ត្រូវបានជ្រើសរើសជាទីកន្លែងសម្រាប់ធ្វើជាគុក និងបន្ទាប់មកក៏ក្លាយជាវាលពិឃាដដោយសារតែជម្លោះ។ បច្ចុប្បន្ន កោះទាំងពីរនេះ បានបន្សល់ទុកនូវអនុស្សាវរីយ៍ និងរឿងរ៉ាវដ៏សែនគ្រោតគ្រាតនាពេលអតីតកាលជាច្រើនដែលមនុស្សជាតិមិនអាចបំភ្លេច។

ផ្កាខេមីលា គឺជាដួងព្រលឹងប្រជាជនកូរ៉េនៅលើកោះជេជូ ដែលបានលះបង់ជីវិត។ នៅពេលដែលអ្នកទៅទស្សនាកោះជេជូ អ្នកនឹងឃើញចម្លាក់ផ្កាខេមីលា តាំងលម្អនៅតាមបូជនីយដ្ឋាន ឬនៅតាមទីតាំងដែលជនរងគ្រោះ៣០.០០០នាក់ត្រូវបានសម្លាប់នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៤៨។ ដោយឡែកចម្លាក់ ផ្កាខេមីលា ក៏ត្រូវបានប្រទះឃើញមានការតាំងលម្អនៅតាមចេតិយមួយចំនួននៅក្នុងប្រទេសកម្ពុជាដែរ ដូចជាចេតិយរបស់ស្តេចអង្គដួង ដែលបានសាងសង់ឡើងនៅលើកំពូលភ្នំឧដុង្គជាដើម។ ទោះបីជាវប្បធម៌រវាងប្រទេសកូរ៉េខាងត្បូង និងប្រទេសកម្ពុជា មានលក្ខណៈខុសគ្នា ប៉ុន្តែអត្ថន័យនៃផ្កាខេមីលា បានប្រើប្រាស់ និងពន្យល់នៅក្នុងន័យរួមគ្នាគឺវាជាផ្កាតំណាងឲ្យសេចក្តីស្លាប់ និងការរស់ឡើងវិញ។

**អ៊ុន សុដាវី**

# ក្មួនខ្ញុំឈ្មោះ សៅ រី ស្លាប់ដោយសារកើតកញ្ជ្រិល

ខ្ញុំឈ្មោះ អ៊ុច សាត។ កាលពីវ័យកុមារ ខ្ញុំរស់នៅជាមួយឪពុកម្តាយដែលប្រកបរបរជាកសិករនៅក្នុងភូមិគោកចាស់ ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ ខ្ញុំមិនបានរៀនសូត្រច្រើនទេដោយគ្រួសារខ្ញុំមានជីវភាពខ្វះខាត។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ស្រី២ នាក់និងប្រុស២នាក់។ ខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។ បន្ទាប់ពីរបប លន់ នល់ ដួលរលំនៅក្នុងឆ្នាំ ១៩៧៥ ភ្លាម ខ្ញុំក៏បានរៀបការជាមួយប្តីឈ្មោះ បឿក ប៊ឺត ដែលជាអ្នកស្រុកភូមិជាមួយគ្នា។ នៅពេលនោះ ខ្ញុំមានវ័យ ២២ឆ្នាំ។ នៅពេលដែលខ្ញុំរៀបការ ខ្មែរក្រហមមិនទាន់ចូលមកគ្រប់គ្រងនៅក្នុងភូមិរបស់ខ្ញុំរស់នៅនោះទេ ដូច្នេះការរៀបការរបស់ខ្ញុំបានប្រព្រឹត្តទៅតាមប្រពៃណីទំនៀមទម្លាប់ខ្មែរ។

ក្រោយរៀបការមិនយូរប៉ុន្មានខ្មែរក្រហមក៏បានចូលមកកាន់កាប់នៅក្នុងស្រុករបស់ខ្ញុំ ហើយបានប្រមូលយកសម្ភារប្រើប្រាស់ និងទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងភូមិដាក់ជាកម្មសិទ្ធិរួម។ ដោយហេតុថា ខ្មែរក្រហមចូលមកគ្រប់គ្រងភូមិរបស់ខ្ញុំក្រោយភូមិផ្សេងទៀត។ ដូច្នេះកម្មាភិបាលខ្មែរក្រហមបានចាត់ទុកប្រជាជនក្នុងភូមិខ្ញុំថា ប្រជាជនថ្មី ឬប្រជាជន ១៧ មេសា ដែរ បើទោះបីជាប្រជាជនទាំងនេះមិនដែលជម្លៀសចេញពីភូមិរបស់ខ្លួន និងរស់នៅក្នុងតំបន់រំដោះតាំងពីយូរមកហើយក៏ដោយ។ បន្ទាប់មកខ្មែរក្រហម ក៏បានចាត់ចែងការងារឲ្យប្រជាជនក្នុងភូមិធ្វើរៀងៗខ្លួន។ ខ្ញុំនិងប្តីរបស់ខ្ញុំ បានចូលក្នុងកងចល័ត និងធ្វើការងារជាច្រើន ដូចជា ជីកប្រឡាយ



អ៊ុម សាត និងប្តី បឿក ប៊ឺត ព្រមទាំងចៅៗ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

លើកទំនប់ និងដកស្ទូងជាដើម។ ចំណែកឯឪពុកម្តាយរបស់ខ្ញុំ ត្រូវខ្មែរក្រហមចាត់តាំងឲ្យនៅកងចិញ្ចឹមសត្វ កិនស្រូវ និង ដាំដំណាំ។ បងប្អូនរបស់ខ្ញុំត្រូវបានបែងចែកឲ្យទៅរស់នៅភូមិ ផ្សេងៗ។ នៅសម័យនោះ ការរស់នៅរបស់ប្រជាជនខុសគ្នា គឺប្រជាជនថ្មីលំបាកជាងប្រជាជនមូលដ្ឋាន។

ជារៀងរាល់ថ្ងៃខ្ញុំ ក៏ដូចជាប្រជាជនដទៃទៀត ត្រូវក្រោក ពីព្រលឹមដើម្បីបំពេញការងារ។ ចំពោះរបបអាហារមួយ ថ្ងៃខ្ញុំទទួលបានរបបអាហារពីរពេល។ នៅពេលម៉ោងឈប់ សម្រាកប្រជាជនទាំងអស់ត្រូវទៅហូបបាយរួម។ ប្រជាជន ទាំងអស់អង្គុយតាមកន្លែងរៀងៗខ្លួន បន្ទាប់មកចុងភៅដើរ ដាក់អាហារតាមកន្លែងអង្គុយ។ ម្ហូបអាហារប្រចាំថ្ងៃមាន ដូចជា បបរត្រកួន សម្លត្រកួន ឬសម្លប្រលិត។ របបអាហារ បែបនេះ មិនបានផ្តល់វីតាមីនគ្រប់គ្រាន់ដល់ប្រជាជនឡើយ ហើយវាក៏មិនសាកសមទៅនឹងប្រជាជនដែលត្រូវធ្វើការងារ ដោយប្រើប្រាស់កម្លាំងទាំងស្រុងដែរ។ ប្រជាជនទាំងអស់ ស្រេកឃ្លានយ៉ាងខ្លាំង ដោយការហូបចុកមិនគ្រប់គ្រាន់ គួប ផ្សំនឹងការធ្វើការងារហួសកម្លាំង។ពេលខ្លះខ្ញុំ ត្រូវចល័តទៅ ឆ្ងាយពីផ្ទះ ហើយត្រូវសម្រាកនៅតាមវាលស្រែដោយគ្មាន ដំបូលបាំងឡើយ។ ពេលវេលាការងារមិនទៀងទាត់ឡើយ គឺអាស្រ័យទៅលើទំហំការងារ និងផែនការ ដែលអង្គការបាន កំណត់។ ពេលខ្លះកងចល័តត្រូវធ្វើការនៅកន្លែងមួយរយៈ១ ខែ២ខែឬក៏១ឆ្នាំក៏មាន។ នៅពេលដែលខ្ញុំចង់ទៅលេងឪពុក ម្តាយនៅផ្ទះខ្ញុំត្រូវសុំការអនុញ្ញាតពីមេកងចល័តជាមុនសិន។ ប្រសិនបើទទួលបានការអនុញ្ញាត ខ្ញុំអាចទៅលេងផ្ទះបាន១ ថ្ងៃ។នៅពេលខ្ញុំមានផ្ទៃពោះ ខ្មែរក្រហមមិនលើកលែងឲ្យខ្ញុំ ទៅធ្វើការងារស្រាលឡើយ។ នៅពេលដែលខ្ញុំគ្រប់ខែសម្រាល កូន ខ្មែរក្រហមបានបញ្ជូនឆ្មបបុរាណឲ្យមកជួយសម្រាលកូន ឲ្យខ្ញុំ។ ក្រោយពីឈប់សម្រាកសម្រាលកូនបានកន្លះខែ ខ្ញុំត្រូវ ចេញទៅធ្វើការដូចធម្មតាវិញដោយទុកកូនរបស់ខ្ញុំឲ្យមនុស្ស ចាស់នៅក្នុងភូមិជាអ្នកមើលថែទាំ។ ខ្ញុំអាចជួបកូនរបស់ខ្ញុំ តែ នៅពេលយប់ប៉ុណ្ណោះ។ ខ្ញុំបានដាក់ឈ្មោះកូនស្រីដំបូងរបស់ ខ្ញុំថា សៅ រី ប៉ុន្តែជាអកុសលកូននោះបានស្លាប់នៅអាយុ២ឆ្នាំ ដោយសារតែជំងឺកញ្ជ្រិល។ ទោះបីជាសម័យនោះមានថ្នាំខ្លះ ដែរដូចជា ថ្នាំចាក់ ថ្នាំអាចម៍ទន្សាយ ប៉ុន្តែមិនមានច្រើនគ្រប់ គ្រាន់សម្រាប់ប្រជាជនទូទៅឡើយ។

រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេច គឺនៅពេលមួយ ខ្ញុំ និង ប្រជាជនដទៃទៀតកំពុងដកស្ទូងនៅតាមវាលស្រែ ស្រាប់តែ ឃើញយោធាខ្មែរក្រហមមករកមនុស្សក្នុងភូមិទៅដឹកអំបិល។ យោធាទាំងនោះបានបានជ្រើសរើសបងថ្លៃរបស់ខ្ញុំ រួចនាំគាត់ ទៅ។ ខ្ញុំមិនហ៊ានសួរនាំអ្វីឡើយ ហើយក៏បន្តធ្វើការងារធម្មតា។ កន្លងមកជាច្រើនថ្ងៃ ដោយមិនឃើញបងថ្លៃរបស់ខ្ញុំត្រឡប់ មកភូមិវិញ ទើបខ្ញុំបានសន្និដ្ឋានថា បងថ្លៃរបស់ខ្ញុំត្រូវបានយោធា ខ្មែរក្រហមសម្លាប់ហើយ។ បងរបស់ខ្ញុំបានធ្វើអ្វីខុសទេនៅ ពេលនោះ។ រឿងរ៉ាវស្រដៀងៗគ្នានេះបានកើតឡើងជារឿយៗ ទៅលើប្រជាជនក្នុងភូមិរបស់ខ្ញុំ។ បើទោះបីជាការនាំខ្លួនប្រ-ជាជនទៅដោយមិនមានការវិលត្រឡប់នោះកើតឡើងជាច្រើន លើកច្រើនសារ ក៏ពុំមាននរណាម្នាក់ក្លាហានហ៊ានសួរនាំអំពី ដំណឹងរបស់អ្នកទាំងនោះដែរ គឺមានតែកើតទុក្ខសោកអាណិត អាសូរដល់អ្នកដែលបាត់ខ្លួន ហើយខិតខំធ្វើការតាមផែនការ ដែលអង្គការដាក់ឲ្យតែប៉ុណ្ណោះ។ ខ្ញុំមិនដែលត្រូវបានឈ្លប ខ្មែរក្រហមធ្វើទារុណកម្ម ឬសួរចម្លើយឡើយនៅសម័យនោះ ពីព្រោះខ្ញុំតែងតែខិតខំធ្វើការងារឲ្យសម្រេចតាមផែនការរបស់ អង្គការដោយមិនហ៊ានជំទាស់តវ៉ាអ្វីឡើយ និងតែងគោរពតាម ច្បាប់វិន័យរបស់អង្គការ។ នៅពេលយប់ ខ្ញុំតែងតែឃើញ យោធាខ្មែរក្រហមបណ្តើរប្រជាជនដែលមានចំណងជាប់នឹង ដៃទាំងជួរៗដោយក្នុងមួយជួរ មានប្រជាជនចន្លោះពី១០ ទៅ ២០នាក់ ឆ្លងកាត់តាមភូមិរបស់ខ្ញុំ។ ខ្ញុំបានដឹងថា យោធា ទាំងនោះនាំយកប្រជាជនទៅកាន់រណ្តៅក្បែរភ្នំដែលជាវាល ពិឃាត។

ខ្ញុំរស់នៅក្នុងរបបខ្មែរក្រហមរហូតថ្ងៃមួយ ខ្ញុំនិងប្រជា-ជនដទៃទៀតមិនឃើញប្រធានកងចល័តមកបញ្ជាឲ្យធ្វើការ ដូចសព្វដង ដូច្នេះយើងក៏នាំគ្នាអង្គុយរង់ចាំនៅវាលស្រែ។

ខ្ញុំ និងប្រជាជនទាំងនោះមិនហ៊ានធ្វើអ្វីផ្សេងឡើយ លុះត្រាតែមានបញ្ជាពីប្រធានកងចល័ត។ យើងបានរង់ចាំអស់រយៈ ៣ ថ្ងៃ ទើបដឹងថាប្រធានចល័ត កម្មាភិបាល និងយោធាខ្មែរក្រហមធំៗបានរត់គៀសខ្លួនអស់ហើយ ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជារួមជាមួយកងទ័ពវៀតណាមបានចូលមករំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ និងបានទទួលជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ខ្ញុំ និងប្រជាជនដទៃទៀតបានសម្រេចចិត្តត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។ ខ្ញុំមានចិត្តសប្បាយរីករាយជាខ្លាំង ដែលខ្ញុំមានសេរីភាព និងអាចរស់នៅជួបជុំគ្រួសារសារជាថ្មីម្តងទៀត។ ក្រោយការដួលរលំនៃរបបខ្មែរក្រហម ខ្ញុំនិងប្តីបានរស់ក្នុងស្រុកក្រឡាញ់អស់រយៈពេល១៧ឆ្នាំ និងមានកូនចំនួន៩នាក់ ស្រី៦នាក់ និងប្រុស៣នាក់។ ក្នុងអំឡុងពេលខ្ញុំរស់នៅក្នុងស្រុកក្រឡាញ់ ខ្ញុំតែងតែមានជំងឺជាប់ខ្លួនដែលត្រូវការការព្យាបាលជាប្រចាំ ដោយជីវភាពគ្រួសារមានការខ្វះខាត ខ្ញុំ និងប្តីក៏សម្រេចចិត្តលក់ដីស្រែដើម្បីយកថវិកាព្យាបាលជំងឺ។ រហូតនៅក្នុងឆ្នាំ១៩៩៦ ខ្ញុំ និងប្តី ក៏សម្រេចចិត្តនាំកូនមករស់នៅក្នុងភូមិគោកសំព័រ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សព្វថ្ងៃ ខ្ញុំមានអាយុ៦៣ឆ្នាំហើយ ហើយខ្ញុំរស់នៅជាមួយប្តី ព្រមទាំងកូនៗ។

ជាចុងក្រោយ ខ្ញុំពិតជាមិនចង់ឃើញរបបប្រល័យពូជសាសន៍នេះកើតឡើងម្តងទៀតឡើយ ព្រោះគ្រប់ទិដ្ឋភាពដែលខ្ញុំបានឃើញ និងបទពិសោធន៍ដែលខ្ញុំបានឆ្លងកាត់នៅតែស្ថិតក្នុងការចងចាំជានិច្ច។ ក្មេងៗជំនាន់ក្រោយគួរតែខិតខំសិក្សារៀនសូត្រឲ្យមានចំណេះវិជ្ជាក្នុងខ្លួន និងសិក្សាស្វែងយល់ពីរបបនេះបន្ថែម ព្រមទាំងធ្វើយ៉ាងណាទប់ស្កាត់ កុំឲ្យរបបនេះកើតឡើងលើទឹកដីប្រទេសកម្ពុជាម្តងទៀត។

**សាន ធីតា គរុសិស្សឆ្នាំទី១**



ទិដ្ឋភាពបឹងអន្លង់វែង ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

# ឪពុកម្ដាយខ្ញុំស្លាប់ដោយសារជំងឺ និងព្រួយចិត្តបែកពីកូន

ខ្ញុំឈ្មោះ ស៊ិន គីមអេង អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅភូមិព្រែកទន្លាប់ ឃុំលើកដែក ស្រុកលើកដែក ខេត្ត



ស៊ិន គីមអេង

កណ្ដាល។ សព្វថ្ងៃខ្ញុំមានមុខរបរជាកសិកររស់នៅក្នុងឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ មុនឆ្នាំ១៩៧៥ ខ្ញុំបានរស់នៅជាមួយគ្រួសារដែលមានសមាជិក៥នាក់។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ គ្រួសាររបស់ខ្ញុំបានរស់នៅជួបជុំគ្នាយ៉ាងសុខសាន្ត។ នៅពេលនោះខ្ញុំទើបតែមានអាយុ១០ឆ្នាំប៉ុណ្ណោះ ដូច្នេះខ្ញុំពុំសូវចងចាំពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងរបបនោះបានច្រើនទេ។ ខ្ញុំគ្រាន់តែដឹងថា នៅក្នុងសម័យនោះ ខ្ញុំបានឃើញការទម្លាក់គ្រាប់បែក និងមានសង្គ្រាមកើតឡើងគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួលជ័យជម្នះលើទាហាន លន់ នល់។ នៅពេលនោះ ប្រជាជនកម្ពុជាទាំងអស់ ក៏ដូចជាគ្រួសាររបស់ខ្ញុំបានចូលរួមអបអរសាទរចំពោះជ័យជម្នះខ្មែរក្រហមដោយបានគិតថា សង្គ្រាមនៅក្នុងកម្ពុជាបានបញ្ចប់ហើយ សន្តិភាពនឹងកើតមានឡើងវិញមិនខាន ប៉ុន្តែអ្វីៗគ្រប់យ៉ាងបែរជាមានភាពផ្ទុយស្រឡះពីការគិតនេះ។

នៅពេលដែលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានជម្លៀស និងបង្ខំប្រជាជនចេញពីផ្ទះសម្បែង ឲ្យទៅរស់តំបន់ជនបទដាច់ស្រយាលនៅទូទាំងប្រទេសកម្ពុជា។ នៅពេលនោះ គ្រួសាររបស់ខ្ញុំដែលធ្លាប់រស់នៅជុំគ្នា ត្រូវបានខ្មែរក្រហមជម្លៀសចេញ និងបំបែកមិនឲ្យរស់នៅជុំគ្នាដូចមុនឡើយ។ នៅពេលនោះខ្ញុំទើបតែមានអាយុប្រហែលជា១៥ឆ្នាំតែប៉ុណ្ណោះ។ ខ្មែរក្រហមបានបង្ខំខ្ញុំ និងឪពុកម្ដាយឲ្យធ្វើដំណើរដោយថ្មើរជើងពីទីក្រុងភ្នំពេញ រហូតដល់ខេត្តបន្ទាយមានជ័យ ដោយមិនអនុញ្ញាតឲ្យឈប់សម្រាកតាមចិត្តឡើយ។ នៅពេលធ្វើដំណើរដល់គោលដៅ ខ្មែរក្រហមបានបែងចែកឲ្យឪពុកម្ដាយរបស់ខ្ញុំរស់នៅក្នុងសហករណ៍មួយនៅស្វាយស៊ីសុផុន ហើយឲ្យខ្ញុំនៅក្នុងកងកុមារដែលមានសមាជិកសរុប ២៤នាក់។ ចំណែកបងប្អូនប្រុសរបស់ខ្ញុំពីរនាក់ទៀតត្រូវបានខ្មែរក្រហមបំបែកឲ្យទៅរស់នៅភូមិមួយ ស្ថិតនៅក្នុងស្រុកភ្នំស្រុក ដោយសារខ្មែរក្រហមបានចាត់ទុកគ្រួសាររបស់ខ្ញុំថាជាប្រជាជនថ្មី។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅធ្វើការងារកសិកម្មដែលខ្ញុំមិនដែលធ្លាប់ធ្វើពីមុនមក ដូចជា លើកទំនប់ លើកភ្លឺស្រែ ជីកប្រឡាយនៅតាមបណ្ដោយថ្នល់ជាតិនិងការដកស្ទូង ដោយមិនមានពេលទំនេរឡើយ។ នៅរដូវស្ទូង ប្រធានកងបានផ្លុំកញ្ចែញាប់រន្ថាន់ជាសញ្ញាប្រាប់ឲ្យយើងខិតខំស្ទូងតាមសំឡេងកញ្ចែ ប្រសិនបើយើងស្ទូងមិនទាន់តាមផែនការទេ ប្រធានកងនឹងស្ដីបន្ទោសយើងមិនខាន។

នៅពេលដំបូង ខ្ញុំមានការលំបាកយ៉ាងខ្លាំងក្នុងការស្ទូង ដោយសារតែខ្ញុំមិនធ្លាប់ធ្វើកិច្ចការនេះពីមុនមក។ ខ្ញុំតែងតែទទួលការស្ដីបន្ទោស និងគំរាមកំហែងពីប្រធានកង។ ប៉ុន្តែជាបុណ្យសំណាង ខ្ញុំមិនត្រូវបានប្រធានកងធ្វើទារុណកម្ម ឬវាយធ្វើបាបឡើយ។ ខ្ញុំត្រូវចេញទៅធ្វើការពីម៉ោង៥ព្រឹក រហូតដល់ម៉ោង៦ល្ងាច ទើបអាចត្រឡប់មកសហករណ៍។ នៅពេលកំពុងធ្វើការងារប្រធានកងមិនអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកទេ ទោះបីជាខ្ញុំនឿយហត់យ៉ាងណាក៏ដោយ។ ចំណែក

របបអាហារវិញ ខ្ញុំទទួលបានត្រឹមតែបបរកន្លះវែកមួយចានប៉ុណ្ណោះក្នុងមួយពេល ដោយខ្ញុំទទួលបានរបបអាហារពីរពេលក្នុងមួយថ្ងៃ។ ពេលខ្លះក្នុងបបរដែលខ្ញុំទទួលបាន មានលាយបណ្តូលចេក គល់ចេក ឬគល់ល្ហុង ប្រៀបបាននឹងបបរសម្រាប់សត្វជ្រូកដែរ។ នៅពេលដែលខ្ញុំមានជំងឺ អង្គការក៏មានចែកថ្នាំឲ្យលេបដែរ ប៉ុន្តែភាគច្រើនខ្ញុំមិនបានស្នើសុំថ្នាំពីអង្គការឡើយព្រោះខ្លាចអង្គការស្តីបន្ទោស។ ដូច្នេះនៅពេលឈឺក្បាល ឬក្តៅខ្លួន ខ្ញុំតែងតែបេះត្រួយទៀបបារាំង និងត្រួយសាវម៉ាវព្រៃមកបុកលាយជាមួយទឹកអង្ករដាំដឹក ព្យាបាលជំងឺដោយខ្លួនឯង។ នៅសម័យនោះ មិនមានថ្នាំពេទ្យល្អៗសម្រាប់ព្យាបាលជំងឺទេ ទើបបណ្តាលឲ្យអ្នកជំងឺក្នុងភូមិជាច្រើននាក់បានស្លាប់។ ពេលនឹកឃើញដល់រឿងនេះ បានធ្វើឲ្យខ្ញុំក្រៀមក្រំ និងឈឺចាប់យ៉ាងខ្លាំង ព្រោះឪពុកម្តាយរបស់ខ្ញុំបានស្លាប់នៅឆ្នាំ១៩៧៧ ដោយសារជំងឺ និងព្រួយចិត្តដែលកូនៗត្រូវបានអង្គការបំបែកឲ្យទៅរស់នៅឆ្ងាយ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានក្លាយជាក្មេងកំព្រា ហើយត្រូវរស់នៅតែម្នាក់ឯង និងគ្មានអ្នកទីពឹងអាស្រ័យ។

បន្ទាប់ពីឪពុកម្តាយខ្ញុំស្លាប់ទៅ នៅអំឡុងឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យទៅលើកទំនប់នៅអាងត្រពាំងថ្ម។ ពេលនោះ អង្គការមានបំណងឲ្យខ្ញុំទៅជីករណ្តៅសម្រាប់កប់សាកសពមនុស្សដែលអង្គការមានគម្រោងសម្លាប់ចោល ហើយខ្ញុំក៏ជាមនុស្សម្នាក់ដែលស្ថិតនៅក្នុងផែនការសម្លាប់នោះដែរ។ រណ្តៅនោះមានទំហំធំ និងមានជម្រៅជ្រៅ។ នៅអំឡុងពេលជីករណ្តៅនោះ ខ្ញុំសង្កេតឃើញមានមនុស្សធ្លាក់ចូលទៅក្នុងរណ្តៅនោះ និងស្លាប់៦នាក់ទៅ៧នាក់ ក្នុងមួយថ្ងៃៗដោយសារតែប្រជាជនទាំងនោះហេវហត់អស់កម្លាំងខ្លាំងពេក។ នៅអំឡុងពេលកំពុងធ្វើការ ខ្ញុំបានឃើញឈ្លបខ្មែរក្រហមបណ្តើរមនុស្ស៣០នាក់ទៅ៤០នាក់ទាំងដៃជាប់ចំណងខ្សែគោ យកទៅសម្លាប់ និងកប់នៅក្នុងរណ្តៅដែលរៀបចំទុកជាស្រេចនៅក្បែរៗនោះ។ មុនពេលយកទៅសម្លាប់ឈ្លបខ្មែរក្រហម បានឲ្យអ្នកទោសដែលស្លៀកពាក់ខោអាវថ្មីៗ ដោះខោអាវចេញ រួចហើយឈ្លបបានយកត្បូងចប អង្រែ និងដំបងវាយលើកញ្ចឹងកអ្នកទោសម្នាក់ចូលរណ្តៅ។ ពេលនឹកឃើញដល់ហេតុការណ៍នោះ ខ្ញុំពិតជាមានសេចក្តីរន្ធត់យ៉ាងខ្លាំងដោយសារខ្ញុំគិតថាថ្ងៃណាមួយនឹងរឿងរ៉ាវនេះកើតឡើងលើខ្ញុំមិនខាន។ ខ្ញុំធ្វើការនៅអាងត្រពាំងថ្មបានរយៈពេល បួនថ្ងៃ ទើបឪពុកធម៌របស់ខ្ញុំឈ្មោះ «តាហឿន» គឺជាប្រធានសហករណ៍ បានផ្លាស់ខ្ញុំឲ្យទៅធ្វើការនៅភូមិផ្សេងវិញ។

ក្រោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមជាមួយកងទ័ពរបស់វៀតណាម បានវាយផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានផ្លាស់មករស់នៅផ្សារទួលតាឯក ក្នុងទីរួមខេត្តបាត់ដំបង ជាមួយបងស្រីចិញ្ចឹម។ ខ្ញុំបានប្រកបមុខរបរលក់ដូរបន្តិចបន្តួចនៅក្នុងផ្សារដើម្បីចិញ្ចឹមជីវិត។ នៅឆ្នាំ១៩៨០ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ញ៉ែម ប៊ុល និងបានរស់នៅជាមួយគ្នាតាំងពីពេលនោះមក។

ខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំង ដោយសារបងប្អូនរបស់ខ្ញុំបាត់បង់ជីវិតរហូតដល់៧នាក់ក្នុងរបបខ្មែរក្រហម។ ហេតុការណ៍នៅក្នុងរបបខ្មែរក្រហមបានដក់ជាប់ក្នុងចិត្តរបស់ខ្ញុំជានិច្ច។ ខ្ញុំតែងតែរៀបរាប់ប្រាប់កូនរបស់ខ្ញុំពីអ្វីដែលខ្ញុំបានជួបប្រទះ និងបានឆ្លងកាត់នៅរបបខ្មែរក្រហម។ ដំបូងកូនរបស់ខ្ញុំមិនជឿការរៀបរាប់របស់ខ្ញុំទេ។ ប៉ុន្តែក្រោយមកកូនរបស់ខ្ញុំបានដឹងរឿងរ៉ាវពីរបបខ្មែរក្រហមនេះតាមរយៈការសិក្សារៀនសូត្រនៅក្នុងថ្នាក់ អានឯកសារ និងមើលភាពយន្តឯកសារទើបពួកគេជឿ។

ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង ដែលរឿងរ៉ាវរន្ធត់ឃោរឃៅបែបនេះបានកើតមានឡើងក្នុងប្រទេសកម្ពុជា ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រហែលជិតបីលាននាក់ស្លាប់បាត់បង់ជីវិត រួមទាំងសមាជិកគ្រួសាររបស់ខ្ញុំ។ ខ្ញុំសូមផ្តាំផ្ញើទៅក្មេងៗជំនាន់ក្រោយឲ្យជួយថែរក្សាសន្តិភាព ជំរុញឲ្យមានការផ្សះផ្សាជាតិ ហើយធ្វើយ៉ាងណាកុំឲ្យរបបដ៏ឃោរឃៅនេះកើតឡើងម្តងទៀត។

*សុន ស្រីពេជ្រ*

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្រាវជ្រាវដែលគ្រូបង្រៀន ឬអតីតគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន២០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរ«ប្រវត្តិសាស្ត្រចេញពីភូមិ» ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម ចេញពីភូមិឃុំដែលខ្លួនកំពុង ឬធ្លាប់បំពេញភារកិច្ចជាគ្រូបង្រៀន។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់អ្នកស្រាវជ្រាវ នឹងត្រូវបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនវិញដើម្បីប្រើប្រាស់ជាសម្ភារឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។

   

***លក្ខខណ្ឌជ្រើសរើស***

១) អ្នកស្រាវជ្រាវ ត្រូវតែជាអតីត ឬគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កណ្តាល (ស្រុកមុខកំពូល, ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យ ឬការងារដ៏ទៃទៀតដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជា ការធ្វើបទសម្ភាសន៍ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word & Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីធ្វើកិច្ចការនេះ។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឲ្យបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

***លក្ខខណ្ឌការងារ***

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ ឯកសារយោង, កំណត់គោលដៅសម្រាប់សម្ភាសន៍, ការសម្ភាសន៍, វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុក និងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូ និងប្រិយមិត្តដ៏ទៃទៀតមានការចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរ តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល៖ truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ៖ ០១២ ៦៩៦៩៦១ ឬអ៊ីមែល៖ truthrasy.p@dccam.org ។

# ដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហមលើសំណុំរឿង អោ អាន

## *ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម*

(តពីលេខមុន)

*សេចក្តីសង្ខេបអំពីការយល់ឃើញនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង ០០៤/២*

*ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨*

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជឿថា ភ័ស្តុតាងដែលប្រមូលបាននៅក្នុងអំឡុងពេលស៊ើបសួរ គាំទ្រការយល់ឃើញដូចខាងក្រោម៖

នៅចុងឆ្នាំ១៩៧៦ ដល់ដើមឆ្នាំ១៩៧៧ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត និងតាម៉ុក បានបញ្ជូន អោ អាន ពីភូមិភាគនិរតីនៃសម័យកម្ពុជាប្រជាធិបតេយ្យ ទៅភូមិភាគកណ្តាល ហើយបន្ទាប់មក គាត់បានកាន់តួនាទីដូចខាងក្រោមនៅទីនោះនៅក្នុងអំឡុងពេលផ្សេងៗនៃរយៈពេលសេសសល់ទាំងអស់នៃសម័យកម្ពុជាប្រជាធិបតេយ្យ៖ អនុលេខាភូមិភាគកណ្តាល សមាជិកនៃគណៈកម្មការធិការភូមិភាគកណ្តាល និងលេខាតំបន់៤១ នៃភូមិភាគកណ្តាល។

នៅក្នុងអំឡុងពេលនេះ អោ អាន រួមជាមួយនឹងលេខាភូមិភាគកណ្តាល កែ ពក និងកម្មាភិបាលផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) បានប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ដោយមានគោលបំណងរួម ដើម្បីអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅភូមិភាគកណ្តាល៖

១) ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន

២) ការកសាង «សមាសភាពមិនល្អ» និងការសម្លាប់ «ខ្មាំង» ទាំងនៅក្នុងជួរ ប.ក.ក ទាំងនៅក្រៅជួរ ប.ក.ក

៣) ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា ដូចជាកម្មាភិបាល ប.ក.ក នៅភូមិភាគកណ្តាល អតីតមន្ត្រីសាធារណរដ្ឋខ្មែរ «ប្រជាជន១៧ មេសា» (ជាទូទៅសំដៅលើអ្នកខ្ពង់ខ្ពស់រស់នៅក្នុងក្រុង និងអ្នកចេះដឹង ចាប់ពីថ្ងៃដែលភ្នំពេញធ្លាក់ចូលការគ្រប់គ្រងរបស់ខ្មែរក្រហម) ប្រជាជនភូមិភាគបូព៌ា ជនជាតិចាម និងគ្រួសាររបស់ពួកគេ និង

៤) ការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍ដោយបង្ខំតាមរយៈ ជាអាទិ៍ ការរៀបអាពាហ៍ពិពាហ៍ឲ្យអ្នកនៅភូមិភាគកណ្តាលដោយបង្ខំ។

អោ អាន បានអនុវត្តគោលនយោបាយ ប.ក.ក ទាំងនេះ ដោយបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤, ៥, ២៩ និង ៣៩ នៃច្បាប់ អ.វ.ត.ក ព្រមទាំងការធ្វើមនុស្សឃាតតាមច្បាប់ជាតិនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ បន្ថែមពីលើការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម អោ អាន ទទួលខុសត្រូវចំពោះការរៀបចំផែនការ ការបញ្ជា ឬការជំរុញឧក្រិដ្ឋកម្មទាំងនេះ ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ។

អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត ដែលបានប្រព្រឹត្តនៅការដ្ឋានទំនប់អន្លង់ជ្រៃ។ អោ អាន បានអនុវត្តគោលនយោបាយ ប.ក.ក អំពីសហករណ៍ និងការដ្ឋាន ដោយបានត្រួតពិនិត្យ និងតាមដានការកសាង និងការផលិតនៅការដ្ឋាននានា រួមមាន ទំនប់អន្លង់ជ្រៃ ដែលមានមនុស្សរាប់ពាន់នាក់ត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងស្ថានភាពលំបាកយ៉ាងខ្លាំង និងក្រោមការគំរាមកំហែងសម្លាប់ប្រសិនបើពួកគេធ្វើខុស ឬបំពេញការងារក្នុងរបៀបមួយដែលចាត់ទុកថាមិនគួរជាទីពេញចិត្ត។

អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើទារុណ

កម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ដទៃទៀត និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និង សាសនានៅទីកន្លែងផ្សេងៗនៅក្នុងប្រព័ន្ធមន្ទីរសន្តិសុខ និង ទីកន្លែងសម្លាប់មនុស្ស រួមមានៈ

- ទីកន្លែងសម្លាប់មនុស្សគោកព្រីង
- មន្ទីរសន្តិសុខមិត្តសុប
- មន្ទីរសន្តិសុខទួលបេង និងវត្តអន្លួញដី
- មន្ទីរសន្តិសុខវត្តអូរត្រកួន
- មន្ទីរសន្តិសុខវត្តបាធាយ
- មន្ទីរសន្តិសុខវត្តតាមៈ និង
- ទីកន្លែងសម្លាប់មនុស្សវត្តភ្នំប្រុស

អោ អាន បានអនុវត្តគោលនយោបាយ ប.ក.ក ពាក់ព័ន្ធនឹងការកម្ទេចខ្មាំង ដោយដឹកនាំប្រតិបត្តិការ«បោសសម្អាត» មនុស្សនៅតំបន់៤១ ដែលជាប់សង្ស័យថា មិនស្មោះត្រង់ជាមួយនឹង ប.ក.ក។ អោ អាន បានកំណត់អត្តសញ្ញាណ «ខ្មាំង» ដែលត្រូវបោសសម្អាត ហើយកោះអង្គប្រជុំនានាជាមួយថ្នាក់ក្រោមរបស់គាត់ អំពីប្រតិបត្តិការបោសសម្អាត ដោយបញ្ជាអ្នកក្រោមបង្គាប់ឲ្យប្រុងប្រយ័ត្នជានិច្ច ក្នុងការចាប់ខ្លួន និងការសម្លាប់មនុស្ស។ ហេតុនេះ មនុស្សជាច្រើននាក់ត្រូវបានចាប់ខ្លួន ដាក់ឃុំនៅក្នុងស្ថានភាពដ៏វេទនា ត្រូវបានធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សទាំងនេះ។ ការប៉ាន់ស្មានបែបអភិរក្សនិយម គឺមានមនុស្សយ៉ាងតិចបំផុតចំនួន១២,៩៨៤នាក់(រួមមានជនជាតិចាមយ៉ាងតិចបំផុត ១,៧៤៣នាក់) ហើយទំនងជាអាចច្រើនជាងនេះទៀត ត្រូវបានសម្លាប់នៅទីតាំងទាំងនេះ។

ជនរងគ្រោះជាច្រើននាក់ជាប់ជាមុខសញ្ញា ដោយសារពួកគេជាក្រុមមនុស្សដែលគេយល់ថា មានទស្សនៈប្រឆាំង ឬមិនស្របតាមឧត្តមគតិ និងគោលនយោបាយរបស់ ប.ក.ក ហេតុនេះ ត្រូវចាត់ទុកថាជា «ជនក្បត់» «ខ្មាំងផ្ទៃក្នុង» និង «សមាសភាពមិនល្អ»។ អ្នកទាំងនេះរួមមាន កម្មាភិបាល ប.ក.ក នៅភូមិភាគកណ្តាល អតីតមន្ត្រីសាធារណរដ្ឋខ្មែរ «ប្រជាជន ១៧ មេសា» អ្នកមកពី ភូមិភាគបូព៌ា ជនជាតិចាម និងគ្រួសាររបស់ពួកគេ។

អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត ដោយបង្ខំឲ្យមនុស្សប្រុសស្រីរៀបការនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ នៅតំបន់៤១ និងបង្ខំឲ្យពួកគេផ្សំដំណេកតាមរយៈការរួមភេទ។ អោ អាន បានផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយដែលអ្នករស់នៅតំបន់៤១ ត្រូវបានបង្ខំឲ្យរៀបការជាមួយនឹងប្តី/ប្រពន្ធ ដែល ប.ក.ក ជាអ្នកជ្រើសរើស ដោយមិនគិតពីការយល់ព្រមរបស់ប្តីប្រពន្ធឡើយ។ ពិធីរៀបការរួមបានធ្វើឡើងដោយគ្មានលក្ខណៈជាប្រពៃណីខ្មែរ ក្នុងនោះ ប្តីប្រពន្ធត្រូវ បានបង្ខំឲ្យរៀបការជាមួយនឹងមនុស្សដែលខ្លួនមិនដែលបានជួបសោះ ក្នុងករណីជាច្រើន។ ដើម្បីសម្រេចគោលបំណងនៃគោលនយោបាយបង្កើនចំនួនប្រជាជន ប.ក.ក បានណែនាំឲ្យប្តីប្រពន្ធទើបរៀបការរួចរួមភេទជាមួយគ្នា ហើយធ្វើការតាមដាន និងគំរាមកំហែងពួកគេដើម្បីឲ្យប្រាកដថា ពួកគេអនុវត្តតាមសេចក្តីណែនាំនេះ។ ប្តីប្រពន្ធជាច្រើនគូរួមភេទជាមួយគ្នា ដោយសារពួកគេភ័យខ្លាចថា ពួកគេនឹងត្រូវសម្លាប់ ប្រសិនបើមិនព្រម។ ការរៀបការដោយបង្ខំ និងការផ្សំដំណេកដោយបង្ខំនៅក្នុងកាលៈទេសៈបែបនេះបង្កឲ្យមានការឈឺចាប់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយក្នុងករណីខ្លះ បង្កឲ្យមានការឈឺចាប់រាងកាយយ៉ាងធ្ងន់ធ្ងរ និងជាការប្រព្រឹត្តហិង្សាយ៉ាងធ្ងន់ធ្ងរមកលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ។ ការផ្សំដំណេកដោយគ្មានការយល់ព្រមត្រូវតែចាត់ទុកថាជាអំពើរំលោភផ្លូវភេទ។ អោ អាន បានធ្វើជាគណៈអធិបតីដោយផ្ទាល់នៅក្នុងពិធីរៀបការយ៉ាងហោចណាស់ចំនួនប្រាំដង ដោយមានប្តីប្រពន្ធចំនួន៣៨គូនៅទីតាំងផ្សេងៗនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ។

អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មមនុស្សឃាតគិតទុកជាមុន ដែលមានចែងនៅមាត្រា ៣(ថ្មី), ២៩ និង ៣៩ នៃច្បាប់ អ.វ.ត.ក និងមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចំពោះការសម្លាប់មនុស្សនៅទំនប់អន្លង់ជ្រៃ ទីកន្លែងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុបមន្ទីរសន្តិសុខទួលបេង និងវត្តអន្លួញដី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខវត្តតាមៈ និងទីកន្លែងសម្លាប់មនុស្សវត្តភ្នំប្រុស។

ភាគច្រើនក្នុងចំណោមនោះ អោ អាន ទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ជនជាតិចាម នៅខេត្តកំពង់ចាម។ អោ អាន បានព្យាយាមបំផ្លាញប្រជាជនចាមនៅទីនោះ ដោយសារអត្តសញ្ញាណសាសនា និងជាតិពិន្ទុរបស់ពួកគេ។ គាត់បានបញ្ជាលេខាស្រុកនៅតំបន់៤១ ឲ្យប្រមូលបញ្ជីឈ្មោះប្រជាជនចាម ហើយបញ្ជាឲ្យចាប់ខ្លួននិងសម្លាប់ជនជាតិចាមទាំងអស់។

គាត់បានបញ្ជាឲ្យចាប់ខ្លួនជនជាតិចាមជាច្រើននាក់ ជាច្រើនលើក ហើយបានតាមដានការវិវត្តនៃការសម្លាប់នេះ តាមរយៈសេចក្តីរាយការណ៍ដែលផ្តល់ជូនគាត់។ ហេតុនេះប្រជាជនចាមស្ទើរតែទាំងអស់នៅក្នុងភូមិនានានៅទូទាំងតំបន់៤១ ត្រូវបានប្រមូលនិងសម្លាប់ជាប្រព័ន្ធ។ ជនរងគ្រោះជាច្រើននាក់ក្នុងចំណោមជនរងគ្រោះដែលនៅមានជីវិត បានទទួលរងការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬផ្លូវចិត្តដោយសារការប្រព្រឹត្តយ៉ាងព្រៃផ្សៃ នៅក្នុងការសម្លាប់មនុស្សនេះ។ កម្មាភិបាល ប.ក.ក ក៏បានធ្វើសកម្មភាពសម្លាប់ជនជាតិចាមហួសពីតំបន់៤១ទៀត គឺនៅតំបន់ផ្សេងទៀត នៅភូមិភាគកណ្តាល (តំបន់៤២ និង ៤៣) ហើយបន្ថែមពីលើនេះទៀត ជនជាតិចាមរាប់ពាន់នាក់ ត្រូវបានផ្លាស់ទីពីភូមិភាគបូព៌ា ទៅភូមិភាគកណ្តាលដើម្បីយកទៅសម្លាប់។ ការសម្លាប់នេះបានកើតឡើងខ្លាំងបំផុត សាហាវបំផុត និងជាទូទៅបំផុតនៅតំបន់៤១ ដែល អោ អាន ធ្វើជាលេខាតំបន់។ ដោយសារមានការសម្លាប់មនុស្សយ៉ាងច្រើនបែបនេះ ទើបមានការប៉ាន់ស្មានបែបអភិរក្សនិយមកំណត់ថា យ៉ាងតិចបំផុតមានជនជាតិចាម ចំនួន ១៧,១១៥ នាក់ ត្រូវបានសម្លាប់នៅភូមិភាគកណ្តាល (រួមមានជនជាតិចាមចំនួន ១,៧៤៣ នាក់ដែលត្រូវបានសម្លាប់នៅទីតាំងដែលបានបង្ហាញខាងលើ) ទោះបីជាចំនួន ជាក់ស្តែងទំនងជាខ្ពស់ជាងនេះឆ្ងាយក៏ដោយ។ មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្របទចោទដូចខាងក្រោមឡើយ ៖

ទីកន្លែងសម្លាប់មនុស្សគោកព្រីង ៖ បទចោទទាំងអស់នៃការធ្វើទុក្ខបុកម្នេញមកលើអតីតទាហាន លន់ នល់។

មន្ទីរសន្តិសុខវត្តតាមៈ ៖ ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយតាមរយៈការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត។

មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ញដី ៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាតាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត។



អោ អាន

មន្ទីរសន្តិសុខមិត្តសុប ៖ បទចោទទាំងអស់នៃការធ្វើទុក្ខបុកម្នេញមកលើទាហាន លន់ នល់។

មន្ទីរសន្តិសុខវត្តបាធាយ ៖ ការធ្វើទុក្ខបុកម្នេញលើអ្នកភូមិភាគបូព៌ា ដោយមូលហេតុនយោបាយតាមរយៈការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាតាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត។

មន្ទីរសន្តិសុខវត្តអូរត្រកួន ៖ ការធ្វើទុក្ខបុកម្នេញដោយ

មូលហេតុសាសនាតាមរយៈការធ្វើទារុណកម្ម។

ការធ្វើដោយចេតនាឲ្យទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងដើម្បីបំផ្លិចបំផ្លាញរាងកាយ ដែលជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជនជាតិចាម។ បទចោទទាំងនេះត្រូវបានលើកលែង។

អោ អានត្រូវស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អ.វ.ត.ក ក្នុងនាមជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅសម័យកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើតួនាទីរបស់គាត់ នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់គាត់ ដោយមិនគិតថា គាត់ក៏ជាមេដឹកនាំជាន់ខ្ពស់ដែរឬអត់នោះទេ។ គាត់មានតួនាទីខ្ពស់មួយនៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ដែលគាត់បានប្រើប្រាស់ដើម្បីបំផ្លាញជនជាតិចាម និងសម្លាប់មនុស្សយ៉ាងតិចបំផុតរាប់ពាន់នាក់នៅភូមិភាគកណ្តាល ព្រមទាំងបន្តឲ្យមានរបួស និងការឈឺចាប់ធ្ងន់ធ្ងរដល់មនុស្សរាប់មិនអស់ផ្សេងទៀតបង្កើតបានជាបរិយាកាសមួយគួរភ័យខ្លាចយ៉ាងខ្លាំង ដែលសាក្សីម្នាក់បានរៀបរាប់ថាជា «ឋាននរកនៅក្នុងឋានកណ្តាល»។ ហេតុនេះ អោ អាន គួរត្រូវជំនុំជម្រះចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងនេះ។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤/២។

ត្រូវគូសបញ្ជាក់ថា នៅពេលនេះ អោ អាន នៅតែត្រូវចាត់ទុកថាគ្មានទោស។ ដីកាបញ្ជូនទៅជំនុំជម្រះមិនមែនជាសាលក្រមឡើយ គឺគ្រាន់តែជាការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថាមានបទចោទគ្រប់គ្រាន់ដើម្បីបញ្ជូន អោ អាន ទៅជំនុំជម្រះតែប៉ុណ្ណោះ។

ដោយសារថា ម្យ៉ាងនេះគឺជាលើកទីមួយហើយដែលមានដីកាដំណោះស្រាយផ្ទុយគ្នា ហេតុនេះយោងតាមវិធានផ្ទៃក្នុង ៧៧(១៣) មិនច្បាស់ថាតើដីកាបញ្ជូនទៅជំនុំជម្រះក្តីនេះនឹងមានសុពលភាពដែរឬអត់ ប្រសិនបើមិនមានសេចក្តីសម្រេចសំឡេងភាគច្រើន នៅពេលបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះទេ ហើយម្យ៉ាងទៀត ដោយសារថា អោ អាន បានដឹងជាច្រើនឆ្នាំមកហើយថាគាត់ស្ថិតនៅក្រោមការស៊ើបសួរ ប៉ុន្តែគាត់មិនបានព្យាយាមរត់គេច ឬរំខានដល់យុត្តាធិការរបស់ អ.វ.ត.ក ឡើយ ទើបមិនគួរពិចារណាចេញដីកាបង្គាប់ឲ្យឃុំខ្លួនគាត់ដើម្បីរង់ចាំការជំនុំជម្រះក្តីឡើយ។

**ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ លើដីកាដំណោះស្រាយ**

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីប្រកាសព័ត៌មានស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញលើដីកាដំណោះស្រាយ ហើយដាក់សំណៅសាធារណៈដែលមានការកោសលុបនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង អោ អាន ០០៤/០២ ដូចតទៅ ៖ នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់សំណៅសាធារណៈដែលមានការកោសលុបនៃដីកាដំណោះស្រាយនិងឧបសម្ព័ន្ធIII នៅក្នុងសំណុំរឿង០០៤/០២ ហើយបានចេញដីកាសម្រេចថា ដីកាដំណោះស្រាយ និងឧបសម្ព័ន្ធIII ដែលសហចៅក្រមអន្តរជាតិ បានដាក់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ត្រូវធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញទៅជាឯកសារសម្ងាត់ ពីព្រោះថាមានការលើកឡើងដោយចៃដន្យនូវឈ្មោះពេញលេញរបស់សាក្សីពីរនាក់ ដែលត្រូវការពារ។

ការផ្សព្វផ្សាយណាមួយអំពីសំណៅគ្មានការកោសលុបនៃដីកាដំណោះស្រាយ និងឧបសម្ព័ន្ធIII របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង០០៤/០២ ឬការផ្សព្វផ្សាយណាមួយអំពីឈ្មោះរបស់សាក្សីទាំងពីរនាក់ដែលត្រូវការពារ អាចត្រូវដាក់ទោសដោយ អ.វ.ត.ក ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចយោងតាមវិធានផ្ទៃក្នុង២៩(៥) និង៣៥(១)(ក) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក។

**សោម ប៊ុនថន**

# សំណុំរឿង០០៣ ទាក់ទងនឹង មាស មុត

## *ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម*

### *ប្រវត្តិសំណុំរឿង០០៣*

*មាស មុត ភេទប្រុស ទីកន្លែងកំណើតនៅភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត។ មាស មុត ត្រូវបានតុលាការខ្មែរក្រហមចោទប្រកាន់ថា គឺជាសមាជិកគណៈមជ្ឈិម លេខាធិការរង លេខាកងពល១៦៤ (រាប់បញ្ចូលទាំងកងទ័ពជើងទឹក) លេខាតំបន់ស្វយ័តកំពង់សោម។ មាស មុត ត្រូវបានតុលាការខ្មែរក្រហមចោទប្រកាន់ក្នុងសំណុំរឿង០០៣ទៅលើករណីសំខាន់ៗដូចជា៖*

១) *អំពើប្រល័យពូជសាសន៍*

២) *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដ៏ទៃទៀត (ការប្រព្រឹត្តអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភលើផ្លូវភេទ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន)*

៣) *អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការធ្វើទារុណកម្ម និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់*

៤) *ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ក្នុងនោះរួមមាន មនុស្សឃាតដោយចេតនា*

*ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទថា បានប្រព្រឹត្តនៅលើទីតាំងផ្សេងៗគ្នាគឺ៖*

១) *នៅមន្ទីរសន្តិសុខផ្សេងៗ ក្នុងនោះរួមមាន មន្ទីរសន្តិសុខ ស-២១ (ទួលស្លែង)*

២) *ឧក្រិដ្ឋកម្មមកលើសមាជិកកងពលលេខ ១៦៤, ៥០២, ១១៧ និង ៣១៩*

៣) *នៅមន្ទីរសន្តិសុខវត្តឥន្ទញាន*

៤) *នៅការដ្ឋានស្ទឹងហាវ*

៥) *ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅលើកោះ និងជុំវិញកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន*

៦) *នៅសហករណ៍តំបន់រាម រួមមាន ការដ្ឋាននៅកងកេង និងបិតត្រាំង ទីតាំងសម្លាប់មនុស្សចម្ការដូនេ និងមន្ទីរសន្តិសុខទឹកសាប*

៧) *និងនៅកំពង់សោម។*

*សំណុំរឿង០០៣ គឺជាសំណុំរឿងដែលត្រូវបានចោទប្រកាន់ទៅលើជនសង្ស័យ២រូបគឺ មាស មុត និង ស៊ូ ម៉េត ដោយសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំឲ្យបើកការស៊ើបអង្កេតលើឧក្រិដ្ឋកម្មពាក់ព័ន្ធនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។ បន្ទាប់មក នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ការស៊ើបអង្កេតរបស់តុលាការប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានបញ្ចប់បន្ទាប់ពីគាត់បានស្លាប់។ មាស មុត ត្រូវបានចោទប្រកាន់ដោយកំបាំងមុខនៅក្នុងខែមីនា ឆ្នាំ២០១៥ ហើយគាត់បានបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅចំពោះមុខសហចៅក្រមអង្កេតអន្តរជាតិនៅក្នុងខែធ្នូ ឆ្នាំ២០១៥។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រម*

ស៊ើបអង្កេតអន្តរជាតិ បានបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ ប្រឆាំងនឹង មាស មុត។ ក្រោយមក នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននៅក្នុងសំណុំរឿង០០៣ ហើយនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ មាស មុត បានដាក់ឯកសារឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ២ ដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង០០៣ ដូចខាងក្រោម៖

***សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង មាស មុត សំណុំរឿងលេខ០០៣/ ០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស***

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា នៅក្នុងសំណុំរឿង មាស មុត ដោយសារខ្វែងយោបល់គ្នាថា តើ មាស មុត ត្រូវស្ថិត ឬក៏មិនត្រូវស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

សហចៅក្រមស៊ើបអង្កេតជាតិ យល់ឃើញថា មាស



មាស មុត អតីតប្រធានកងទ័ពជើងទឹក កងពល១៦៤ របស់កម្ពុជាប្រជាធិបតេយ្យ
កំពុងដឹកនាំក្បួនដង្ហែរសព តាម៉ុក នៅអន្លង់វែង ក្នុងឆ្នាំ២០០៦

មុត មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងនាមមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ហើយលើកលែងការចោទប្រកាន់លើ មាស មុត ដោយសារមូលហេតុនេះ។ នៅពេលដែលឈានដល់សេចក្តីសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាលើកម្រិតនៃការចូលរួមរបស់ មាស មុត និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ព្រមទាំងកត្តាផ្សេងៗទៀត ដូចជា ខ្លឹមសារនៃច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក ព្រមទាំងគោលបំណងនៃអ្នកតាក់តែងកិច្ចព្រមព្រៀង និងច្បាប់ទាំងនោះ។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា មាស មុត ត្រូវស្ថិតនៅក្នុងយុត្តាធិការ បុគ្គលរបស់ អ.វ.ត.ក ក្នុងនាមជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតហើយ មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទបញ្ជូនគាត់ទៅជំនុំជម្រះចំពោះបទចោទនៃអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើមនុស្សឃាតគិតទុកជាមុន យោងតាមច្បាប់កម្ពុជា។ បទចោទខ្លះមិនអាចមានភស្តុតាងបញ្ជាក់ទេនៅក្នុងអំឡុងពេលស៊ើបសួរ ហេតុនេះត្រូវលើកលែងបទចោទទាំងនោះ។

សហចៅក្រមស៊ើបអង្កេតទាំងពីរ បានដាក់ដីកាដំណោះស្រាយរបស់ខ្លួនជាភាសាផ្លូវការរៀងខ្លួន ដោយសំណៅបកប្រែ នឹងដាក់តាមក្រោយឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតទាំងពីរ ផ្តល់ជូនសេចក្តីសង្ខេបនៃសំអាងហេតុរៀងខ្លួនជាភាសាខ្មែរ ទាំងជាភាសាអង់គ្លេស ដើម្បីធានាថាសាធារណជនទទួលបានព័ត៌មានគ្រប់គ្រាន់អំពីលទ្ធផលនៃសំណុំរឿង រហូតដល់ពេលសំណៅបកប្រែទាំងស្រុងត្រូវបានដាក់។ សេចក្តីសង្ខេបទាំងនេះ មានភ្ជាប់ជាមួយនឹងសេចក្តីប្រកាសព័ត៌មាននេះ ហើយសហចៅក្រមស៊ើបអង្កេតទាំងពីរ សូមយោងលើសេចក្តីសង្ខេបទាំងនេះសម្រាប់សេចក្តីលម្អិតថែមទៀត។

សហចៅក្រមស៊ើបអង្កេតទាំងពីរ ក៏បានចេញដីកាសម្រេចដាច់ដោយឡែកពីគ្នា លើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

## សេចក្តីសង្ខេបរបស់សហចៅក្រមស៊ើបអង្កេតជាតិ

សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាភស្តុតាង និងឯកសារ ក្នុងសំណុំរឿង០០៣ ដែលទទួលបានតាមរយៈការស៊ើបអង្កេត និងផ្ទេរពីសំណុំរឿង០០១ និង០០២ ដើម្បីសម្រេចថា តើ មាស មុត ស្ថិត ឬមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក។

ដូចដែលបានបង្ហាញរួចមកហើយ ក្នុងសំណុំរឿង ០០៤/១ និង០០៤/២ ធាតុផ្សំចំនួនពីរគឺ ភាពធ្ងន់ធ្ងរនៃបទល្មើស និងកម្រិតនៃការចូលរួមរបស់ មាស មុត ត្រូវបានពិចារណា។ សហចៅក្រមស៊ើបអង្កេតជាតិ មិនបដិសេធនូវបទឧក្រិដ្ឋធ្ងន់ធ្ងរកើតមានឡើង ដូចដែលបានបង្ហាញរួចហើយក្នុងសំណុំរឿង០០១ និង០០២។ អាស្រ័យហេតុនេះ ដើម្បីកំណត់នូវយុត្តាធិការបុគ្គល ក្នុងបរិបទនៃយុត្តាធិការបុគ្គលបែបជ្រើសរើស កម្រិតនៃការចូលរួមរបស់ជនត្រូវចោទត្រូវបានផ្តល់ទម្ងន់ជាង ដែលនឹងផ្តល់ផលដែរនូវការប្រព្រឹត្តស្មើគ្នាក្នុងចំណោមជនសង្ស័យ។

ភស្តុតាងបានបង្ហាញថា មាស មុត ជាមេបញ្ជាការកងពលលេខ៣ដែលក្រោយមកក្លាយជាកងពលមជ្ឈិមលេខ ១៦៤ ទទួលបន្ទុកទ័ពជើងទឹក គ្រប់គ្រងលើដែនកោះក្នុងភូមិសាស្ត្រកំពង់សោមខណៈដែលកងពលលេខ១ ទទួលខុសត្រូវលើដែនទឹកក្នុងខេត្តកោះកុង។ គាត់ទទួលខុសត្រូវជាសំខាន់លើកិច្ចការងារនយោបាយ។

ផ្អែកតាមភស្តុតាង វានៅមានភាពមន្ទិលថា មាស មុត ជាអគ្គរងសេនាធិការ។ ទោះបីវាជាការពិត គាត់ស្ថិតនៅក្នុងតំណែងនេះ ប្រហែលជាមួយខែមុនដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៩។ បន្ថែមពីលើនេះ គាត់ក៏មិនមែនជាសមាជិកគណៈកម្មាធិការមជ្ឈិម ក៏ប៉ុន្តែ គាត់អាចជាជំនួយការនៃគណៈកម្មាធិការនេះ ដែលគាត់គ្មានសិទ្ធិ ក្នុងការបោះឆ្នោតលើសេចក្តីសម្រេចសំខាន់ៗទេ។

មាស មុត បានចូលរួមប្រជុំជាមួយ សុន សេន និង លេខាកងពលដទៃទៀត ដើម្បីរាយការណ៍ពីការងាររបស់អង្គភាពរាប់បញ្ចូលការបង្ក្រាបសត្រូវ។ ក្នុងចំណោមអង្គប្រជុំទាំងអស់ដែលគាត់បានចូលរួម គាត់បានបង្ហាញពីការគាំទ្រនូវគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែមិនមានភ័ស្តុតាងបង្ហាញថា គាត់ផ្តួចផ្តើមនូវផែនការដើម្បីបង្ក្រាបទាហានក្រោមបង្គាប់ ឬជនស៊ីវិលក្នុងតំបន់ដែលត្រូវបានអះអាងថា គ្រប់គ្រងដោយកងពលលេខ១៦៤ នោះទេ។ មានគេឡេក្រោមពីអនុលេខាកងពលលេខ១៦៤ ទៅកាន់គណៈកម្មាធិការមជ្ឈិម ដែលនេះបង្ហាញថា មិនមែនមានតែ មាស មុត ទេក្នុងកងពលលេខ១៦៤ អាចរាយការណ៍ផ្ទាល់ទៅ សុន សេន ឬគណៈកម្មាធិការមជ្ឈិម។

កិច្ចការងារដែនដីទឹកកម្ពុជា ស្ថិតនៅក្នុងដែនអធិបតេយ្យភាពរបស់រដ្ឋដែលរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវដាក់ក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម ហើយដោយសារកងទ័ពត្រូវមានភារកិច្ចការពារជាតិពីសត្រូវឈ្លានពាន ទើបកងពលលេខ១៦៤ ត្រូវតែគោរពតាមដាច់ខាតនូវបទបញ្ជារបស់គណៈកម្មាធិការមជ្ឈិម។ គ្មានកម្មាភិបាលណាមួយហ៊ានជំទាស់ទេ ប្រសិនបើមិនដូចនេះ ជីវិតពួកគេគេចមិនរួចពីហានិភ័យឡើយ។

ដើម្បីគោរពតាមគោលនយោបាយដ៏តឹងរឹង ដូចដែលភ័ស្តុតាងបានបង្ហាញ មាស មុត ត្រូវសហការជាមួយមន្ទីរសន្តិសុខស-២១ ដើម្បីឃាត់ខ្លួននិងបញ្ជូនសត្រូវទៅស-២១។ ភ័ស្តុតាងបង្ហាញថា មានទាហានជាង៥ពាន់នាក់ក្នុងចំណោមជនរងគ្រោះក្នុងមន្ទីរសន្តិសុខ ស-២១ ចំនួនជាង១២.០០០នាក់ (មួយម៉ឺននាក់) បានស្លាប់ ឬត្រូវបានសម្លាប់។ ក្នុងនោះ មិនមានចំនួនជនរងគ្រោះជាកងទ័ពច្រើនទេពីកងពល១៦៤។

ជាសរុប តំណែង និងតួនាទី ផ្តោតលើការងារសម្របសម្រួល និងមិនសកម្មក្នុងការគាក់តែងគោលនយោបាយ ដោយសារតែកងពលលេខ១៦៤ ធ្វើការងារពាក់ព័ន្ធនឹងកងការពារដែនទឹក និងស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម។ ការចូលរួមរបស់គាត់ មិនកៀកកិតនឹងការប្រព្រឹត្តបទឧក្រិដ្ឋ និងមិនសកម្មក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតជាតិសម្រេចថា មិនមានយុត្តាធិការបុគ្គលលើ មាស មុត និងសម្រេចលើកលែងការចោទប្រកាន់។

## សេចក្តីសង្ខេបរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើ មាស មុត ក្នុងនាមជាជនម្នាក់ក្នុងចំណោមជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់គឺជាមន្ត្រីខ្មែរក្រហមនៅក្នុងពេលវេលានៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងនៅក្នុងពេលវេលាដែលបទល្មើសបានកើតឡើងដោយសារគាត់យោងតាមការចោទប្រកាន់។ មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ប៉ុន្តែគាត់ស្ថិតនៅជិតស្និទ្ធខ្លាំងជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយសារតួនាទីរបស់គាត់(១) ជាមេបញ្ជាការកងពល១៦៤ ត្រូវជាមេបញ្ជាកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ដែលជាកងកម្លាំងប្រដាប់អាវុធមួយក្នុងចំណោមកងកម្លាំងប្រដាប់អាវុធទាំងបីរបស់កម្ពុជាប្រជាធិបតេយ្យ ហើយត្រូវទទួលខុសត្រូវដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ (២)សមាជិកបម្រុងនៃគណៈអគ្គសេនាធិការ និងជាអនុម្នាក់ក្នុងចំណោមអនុរបស់ សុន សេន និង (៣)ជាសមាជិកបម្រុងនៃ គណៈមជ្ឈិមពីចុងឆ្នាំ១៩៧៨។ មាស មុត ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដោយសារឋានៈ និងទំហំសិទ្ធិអំណាចរបស់គាត់បូករួមបញ្ចូលគ្នានៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ និងដោយផ្អែកលើចរិតលក្ខណៈ និងវិសាលភាពនៃឧក្រិដ្ឋកម្មរបស់គាត់។ ការយល់ឃើញនេះគឺស្រដៀងគ្នានឹងជនត្រូវចោទ ឬជនជាប់ទោសផ្សេងទៀតដែរ។ មាស មុត បានកាន់តួនាទីជាន់ខ្ពស់មួយនៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ដោយធ្វើការនៅថ្នាក់ខ្ពស់បំផុតនៃរចនាសម្ព័ន្ធបញ្ជាការយោធារបស់កម្ពុជាប្រជាធិបតេយ្យ

នៅក្រោមថ្នាក់ដឹកនាំនយោបាយថ្នាក់ជាតិ។ គាត់ត្រូវបានគេកោះហៅឲ្យអនុវត្តការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា (ក.ប.ក) ហួសពីតំបន់ប្រតិបត្តិការធំរបស់គាត់នៅកំពង់សោម និងហួសពីភារកិច្ចរបស់គាត់ជាមេបញ្ជាការកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ បន្ថែមពីលើតួនាទីជាន់ខ្ពស់ជាផ្លូវការរបស់ មាស មុត ស្ថានទម្ងន់នៃអំពើរបស់គាត់ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដោយសារអំពើទាំងនោះ ដូចមានលម្អិតនៅក្នុងដីការដំណោះស្រាយ គឺជាសំអាងហេតុអាចសន្និដ្ឋានថា គាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។

បទចោទសំខាន់ដែលត្រូវតែចោទ មាស មុត ហើយច្បាស់ជាឲ្យគាត់ស្ថិតនៅក្នុងក្របខណ្ឌនៃយុត្តាធិការបុគ្គល គឺបទចោទនៃអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងការសម្លាប់រង្គាលលើជនជាតិថៃដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ចាប់បាននៅក្នុងដែនទឹក និងកោះនៅតាមបណ្ដោយឆ្នេររបស់កម្ពុជាប្រជាធិបតេយ្យ។ មាស មុត បានធ្វើឲ្យដែនទឹកទាំងនេះក្លាយជាអន្ទាក់ដ៏ធំសម្រាប់ជនណាដែលចូលមក។ មាស មុត មិនបានជំរុញអ្នកក្រោមបង្គាប់របស់គាត់ឲ្យអត់ធ្មត់ទេ តែផ្ទុយមកវិញៈ បទបញ្ជារបស់គាត់ឲ្យសម្លាប់មនុស្សបានបន្តមិនចេះចប់។ ជនជាតិវៀតណាមតែងតែត្រូវបានសម្លាប់ ហើយមានឱកាសតែមួយគត់ដែលជនជាតិថៃខ្លះក្នុងចំណោមជនជាតិថៃដែលត្រូវចាប់បាន បានគេចផុតពីការសម្លាប់ គឺដោយសារដោះដូរ ពួកគេយកទំនិញ។ តាមការគណនាចំនួនលក្ខណៈអភិរក្សនិយមយ៉ាងខ្លាំង យ៉ាងតិចបំផុតមានជនជាតិថៃចំនួន១.២០០នាក់ និងជនជាតិវៀតណាមចំនួន ៣.២៧៦នាក់ ត្រូវបានសម្លាប់នៅក្នុងប្រតិបត្តិការចាប់ខ្លួនរបស់កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ នៅក្រោមការគ្រប់គ្រងរបស់ មាស មុត ប៉ុន្តែចំនួនទាំងនេះទំនងខ្លាំងអាចច្រើនជាងនេះឆ្ងាយ។ ចំនួនជនរងគ្រោះអាស្រ័យលើតែចំនួនចាប់ខ្លួនជនជាតិថៃ និងជនជាតិវៀតណាមដែលបានចូលដែនទឹក គឺមានន័យថា ប្រសិនបើចាប់ខ្លួនបានកាន់តែច្រើន នោះការសម្លាប់ក៏មានកាន់តែច្រើនដែរ។ របៀបឃោរឃៅនៃការបោះចោលសាកសព និងការប្រមាថទាំងស្រុងលើភាពថ្លៃថ្នូរនៃសាកសពជនរងគ្រោះតាមរយៈការប្រើប្រាស់សាកសពជាជីដាក់ដើមដូរេន តាមការបញ្ជារបស់ មាស មុត គឺលើសពីភាពធម្មតានៃភាពឃោរឃៅព្រៃផ្សៃរកម្រិតខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ។

ជាងនេះទៅទៀត មាស មុត ក៏ទទួលខុសត្រូវផងដែរ ចំពោះឧក្រិដ្ឋកម្មមួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មថ្នាក់ជាតិ ដូចមានបង្ហាញយ៉ាងលម្អិតនៅក្នុងដីការដំណោះស្រាយ ជាពិសេស តួនាទីសំខាន់របស់គាត់នៅក្នុងការបោសសម្អាតកងពល១១៧, កងពល១៦៤, កងពល៣១០ និងកងពល៥០២ របស់ក.ប.ក ព្រមទាំងការត្រួតពិនិត្យ និងការចាត់ចែងការដ្ឋាន និងមន្ទីរសន្តិសុខនានានៅកំពង់សោម គឺបិតត្រាំង និងកងកេង ស្ទឹងហាវ ទឹកសាប វត្តឥន្ទញ្ញាន ចម្ការដូរេន និងឧក្រិដ្ឋកម្មនៃការរៀបការដោយបង្ខំ។ ចំនួនជនរងគ្រោះជាអប្បបរមាដែលត្រូវបានសម្លាប់នៅក្នុងការបោសសម្អាត ក.ប.ក អាចដោយសារ មាស មុត ដោយផ្អែកលើការបញ្ជូនទៅមន្ទីរ ស-២១ និងការសម្លាប់នៅហ្វឹកកន្ទែង គឺមានចំនួន២.១៩២នាក់។ ចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅទីតាំងឧក្រិដ្ឋកម្មនានានៅកំពង់សោម មិនអាចបែងចែកទាំងស្រុង និងឲ្យបានត្រឹមត្រូវទៅតាមទីតាំងនីមួយៗបានទេ ប៉ុន្តែ មាស មុត ខ្លួនគាត់ផ្ទាល់បានរាយការណ៍នៅពេលនោះថា កម្លាំងការងាររួមរបស់គាត់មានមនុស្សចំនួន១៧.០០០នាក់។ ក្រៅពីការបញ្ជាក់នេះ ភ័ស្តុតាងអាចឲ្យធ្វើការគណនាបានថា ជាអប្បបរមាមានមនុស្សតែ២.០០០នាក់ប៉ុណ្ណោះដែលស្ថិតក្នុងកម្លាំងពលកម្ម ដោយបង្ខំនៅទីតាំងដែលស្ថិតនៅក្នុងបទចោទជាក់ស្ដែង។ ប៉ុន្តែនៅក្នុងបរិបទនៃយុត្តាធិការបុគ្គល គឺអាចប្រើប្រាស់ចំនួនសរុបនៅកំពង់សោម ទាំងមូល ជាសូចនាករនៃឥទ្ធិពល និងតួនាទីជារួមរបស់គាត់។ ភ័ស្តុតាងគាំទ្រសេចក្ដីសន្និដ្ឋានដែលថាក្នុងចំណោមមនុស្សទាំង១៧.០០០នាក់ មាន

តែមួយចំនួនតូចប៉ុណ្ណោះដែលជាយោធាកំពុងបម្រើការងារ ក្នុងចំណោមយោធាចំនួនជាង៨.០០០នាក់ នៅក្នុងកងពល ១៦៤ ក្រៅពីយោធាពិការ និងកុមារចំនួនពីរបីរយនាក់ ប៉ុន្តែ ដើម្បីឲ្យកាន់តែប្រយ័ត្នប្រយែងអាចដកយោធាចំនួន២.០០០ នាក់ចេញពីចំនួន១៧.០០០នាក់ ហេតុនេះនៅសល់មនុស្ស យ៉ាងតិច១៥.០០០នាក់ ដែលត្រូវធ្វើពលកម្មដោយបង្ខំនៅ ក្នុងស្ថានភាពគួរឲ្យតក់ស្លុតយ៉ាងខ្លាំង ដោយផ្អែកលើភស្តុតាង ទាំងអស់ពីទីតាំងឧក្រិដ្ឋកម្ម។

សរុបមក ទាំងតួនាទី ទាំងអំពើរបស់ មាស មុត ធ្វើឲ្យ គាត់ក្លាយជាអ្នកដើរតួនាទីយ៉ាងសំខាន់ម្នាក់ នៅក្នុងរបប សម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកចូលរួមដោយមាន ឆន្ទៈ និងកម្លាំងចិត្តនៅក្នុងការអនុវត្តយ៉ាងព្រៃផ្សៃ នូវគោល នយោបាយឧក្រិដ្ឋកម្ម និងអមនុស្សធម៌របស់កម្ពុជាប្រជា ធិបតេយ្យ។ គាត់គួរត្រូវជំនុំជម្រះចំពោះឧក្រិដ្ឋកម្មរបស់ គាត់។

អ៊ុន សុដាវី

# សូមចែករំលែករឿងរ៉ាវជីវិត ពីសម័យខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ

ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមបោះពុម្ពផ្សាយដំបូងបង្អស់នៅខែមករា ឆ្នាំ២០០០។ ទស្សនាវដ្តីស្វែងរកការពិត បាននិងកំពុងសរសេរ ព្រមទាំងបោះពុម្ពផ្សាយពីរឿងរ៉ាវផ្សេងៗដែលបានកើត ឡើងនៅក្នុងរបបខ្មែរក្រហម ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់ត្រង់ប្រមាណជិតពីរលាននាក់បាត់បង់ជីវិត បែកបាក់ គ្រួសារ និងរងការឈឺចាប់រហូតមកដល់សព្វថ្ងៃ។ អត្ថបទទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឲ្យធូរ ស្បើយផ្លូវចិត្តសម្រាប់អ្នកដែលនៅរស់រានមានជីវិត ការជំរុញឲ្យមានយុត្តិធម៌ និងការផ្សះផ្សានៅក្នុងសង្គមកម្ពុជាទាំង មូល។ ការសរសេរសាច់រឿងពិតចេញពីបទពិសោធន៍របស់ប្រជាជនកម្ពុជា គឺជាការចូលរួមចំណែកដ៏ធំធេងក្នុងការថែ រក្សាការចងចាំ និងជាសារមួយដ៏សំខាន់សម្រាប់អប់រំក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីរឿងរ៉ាវរបស់មនុស្សដែលកំពុង រស់នៅជុំវិញខ្លួន ជាពិសេសសាច់ញាតិរបស់ខ្លួន និងប្រវត្តិសាស្ត្រដែលបានកើតឡើងនៅប្រទេសកម្ពុជាក្នុងអំឡុងរបប កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ថែមលើរឿងរ៉ាវប្រវត្តិសាស្ត្រ ទស្សនាដ្តីស្វែងរកការពិតក៏បានសរសេរ និងចែករំលែកនូវព័ត៌មានពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ដែរ។

បច្ចុប្បន្ន មានប្រជាជនកម្ពុជា និងជនបរទេសបានអាន និងគាំទ្រដល់ការងាររបស់ទស្សនាវដ្តីស្វែងរកការពិតនៃ មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកទាំងនេះបានសរសេរ និងបានផ្ញើរឿងរ៉ាវជីវិតផ្ទាល់ខ្លួន រួមទាំងសាច់ញាតិរបស់ខ្លួនមក ចុះផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិតទៀតផង។

ដូច្នេះ ប្រសិនបើ អ៊ំ ពូ មីង បងប្អូន មានបំណងចង់បន្តចូលរួមសរសេរ និងមានអត្ថបទ ទាក់ទងនឹងរឿងរ៉ាវ ពីរបបខ្មែរក្រហម ហើយចង់ចុះផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិត សូមផ្ញើអត្ថបទទាំងនេះមកកាន់ខ្ញុំបាទ សោម ប៊ុនថន លេខទូរសព្ទ ៖ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthbunthorn.s@dccam.org ឬ តាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ។ សូមអរគុណ!

# ហេតុអ្វីបានអំពើប្រល័យពូជសាសន៍នៅតែបន្តកើតមាន?

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ គឺជាថ្ងៃដែលអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវបានអនុម័តដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយសេចក្តីសម្រេចលេខ២៦០។ ការអនុម័តនេះ គឺមានរយៈពេលមុនមួយថ្ងៃ នៃការប្រកាសសិទ្ធិមនុស្សជាសកល នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលបានអនុម័តដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅឯមហាសន្និបាតលើកទី៣ ជាមួយសេចក្តីសម្រេចលេខ២១៧ នៅព្រះរាជវាំងឆាឡូត ក្នុងទីក្រុងប៉ារីស ប្រទេសបារាំង ដែលមានសមាជិកចំនួន៤៨ប្រទេសក្នុងចំណោម៥៨ប្រទេស បានបោះឆ្នោតគាំទ្រ។

មកដល់ខែធ្នូ ឆ្នាំ២០១៨ នេះ អនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងសេចក្តីប្រកាសសិទ្ធិមនុស្សជាសកល មានរយៈពេល៧០ឆ្នាំមកហើយ ប៉ុន្តែយើងនៅតែសង្កេតឃើញថា អំពើប្រល័យពូជសាសន៍នៅតែកើតមាននៅជុំវិញពិភពលោកដដែល។

ប្រទេសកម្ពុជាបានចូលជាសមាជិករបស់អង្គការសហប្រជាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ (គឺមានរយៈពេលពីរឆ្នាំបន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យទាំងស្រុងពីប្រទេសបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣)។ ប៉ុន្តែប្រទេសកម្ពុជាមានកាតព្វកិច្ចត្រូវគោរពតាមធម្មនុញ្ញ ដែលអនុម័តដោយអង្គការសហប្រជាជាតិ រួមមាន អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ការប្រកាស



រាប់ពីឆ្វេងទី១៖ ប៉ុល ពត ជានាយករដ្ឋមន្ត្រី និងជាលេខាបក្សកុម្មុយនីស្តកម្ពុជា, នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា, អៀង សារី ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស, សុន សេន ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង វ៉ន វេត (ឈរពីក្រោយ សុន សេន) ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

ជាសកលស្តីពីសិទ្ធិមនុស្ស។

នៅពេលអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងសេចក្តីប្រកាសសិទ្ធិមនុស្សជាសកលត្រូវបានយកចិត្តទុកដាក់ពីអង្គការ និងសហគមន៍អន្តរជាតិនានា ជាពិសេសប្រទេសលោកខាងលិច ខណៈនោះក្រុមខ្មែរក្រហម បានខិតខំឆ្លៀតឱកាសឃោសនា អូសទាញទឹកចិត្តប្រជាជននៅតាមទីជនបទដាច់ស្រយាលកាន់តែខ្លាំងឡើង ឲ្យងាកមកគាំទ្រចលនាតស៊ូបដិវត្តន៍របស់ខ្លួនប្រឆាំងនឹងរបបដឹកនាំមុនៗ។ ខ្មែរក្រហមបានបណ្តុះគំនិតប្រជាជនឲ្យមានគំនិតស្អប់ គុំគួន និងចងកំហឹងចំពោះមេដឹកនាំ និងរបបមុនៗ។ ចាប់តាំងពីខ្មែរក្រហមបានឡើងកាន់អំណាច ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបនេះបានហាមឃាត់ប្រជាជនក្នុងការប្រើប្រាស់សិទ្ធិសេរីភាព ដែលប្រទេសកម្ពុជាបានទទួលស្គាល់ និងដែលបានចែងក្នុងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្សថា គ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិ នយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។

ខ្មែរក្រហមមិនត្រឹមតែមិនបានអនុវត្តសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្សទាំងនោះទេ ផ្ទុយទៅវិញខ្មែរក្រហមបានប្រព្រឹត្តរំលោភបំពានថែមទៀតទៅលើអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលបានចែងថា អំពើប្រល័យពូជសាសន៍គឺជាអំពើដែលបានប្រព្រឹត្តដោយមានចេតនាជាក់លាក់ដើម្បីបំផ្លាញទាំងស្រុង ឬដោយផ្នែកទៅលើក្រុមជាតិ ក្រុមជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ អំពើទាំងនោះរួមមាន៖

១) អំពើមនុស្សឃាតលើសមាជិកក្រុម។
២) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើរាងកាយ ឬផ្លូវចិត្តនៃសមាជិកក្រុម។
៣) ការដាក់ដោយចេតនានូវក្រុមមនុស្សនៅក្រោមលក្ខខណ្ឌរស់នៅលំបាកដែលនាំឲ្យមានការបំផ្លាញសុខភាពទាំងស្រុង ឬដោយផ្នែក។
៤) វិធានការដែលរារាំងដល់ការមានគភ៌ដល់សមាជិកក្រុម។
៥) ការជម្លៀសកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត។

ដោយបានអនុវត្តនូវការគ្រប់គ្រងតាមបែបផ្តាច់ការ និងគឺងរឹងជ្រុលហួសហេតុ របបខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរស្លូតត្រង់អស់ប្រមាណជិតពីរលាននាក់។ ទោះបីរបបនេះបានដួលរលំ នៅឆ្នាំ១៩៧៩ ទៅហើយក្តី ប៉ុន្តែរបបនេះបានបំផ្លាញស្ទើរទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សកម្ពុជា និងបានបន្សល់នូវស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការ ការបែកបាក់ និងជំងឺបាក់ស្បាតរហូតមកដល់សព្វថ្ងៃនេះ។

សហគមន៍អន្តរជាតិ ធ្លាប់បានដឹងឮពីការកាប់សម្លាប់រង្គាលនៅក្នុងប្រទេសកម្ពុជា ពីចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដែលបានប្រព្រឹត្តដោយក្រុមខ្មែរក្រហម និងប្រទេសមួយចំនួនទៀត ដូចជា ប្រទេសបូស្នី រ្វ៉ាន់ដា និងប្រទេសយូហ្គោស្លាវី រួចហើយក្តី ក៏រហូតមកដល់សព្វថ្ងៃ ក៏យើងនៅតែសង្កេតឃើញការសម្លាប់រង្គាលនៅតែបន្តកើតមាននៅប្រទេសមួយចំនួនរួមមាន៖ នៅភាគខាងជើងប្រទេសអ៊ីរ៉ាក់ នៅប្រទេសស៊ីរី និងនៅប្រទេសភូមា។ ជារឿយៗវិធានការទប់ស្កាត់ការសម្លាប់រង្គាល់តែងតែមានភាពយឺតយ៉ាវ និងមិនត្រូវបានអើពើ និងយកចិត្តទុកដាក់ដោយសារពាក់ព័ន្ធនយោបាយក្នុងតំបន់ និងសកលលោក។ ដូច្នេះដើម្បីទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍នេះកើតឡើងទៅថ្ងៃខាងមុខ មេដឹកនាំប្រទេសទាំងអស់ត្រូវតែមានឆន្ទៈរួមគ្នា និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងអន្តរាគមន៍ទប់ស្កាត់ឲ្យបានទាន់ពេលវេលាចំពោះអំពើទាំងឡាយណា ដែលនាំទៅរកការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍។

*សោម ប៊ុនថន*

# ពិព័រណ៍សហសម័យ៖ «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា»

មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយសាលាជំនាញសិល្បៈសូនរូប ហ្វាពន្ធីសិល្បៈ បានរៀបចំការតាំងពិព័រណ៍មួយស្តីអំពី៖ «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា»ដែលប្រារព្ធធ្វើនៅក្នុងវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទីករីត អាគារ H នៃវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។ ការតាំងពិព័រណ៍នេះ បានបើកឲ្យមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់សាធារណៈជនទាំងអស់ដែលមានបំណងចង់ស្វែងយល់អំពីអត្ថន័យនៃការតាំងពិព័រណ៍ និងទស្សនារូបគំនូរស្អាតៗចំនួន១៩ផ្ទាំង ដែលរូបគំនូរទាំងអស់នេះ គឺជាស្នាដៃសិល្បៈរបស់និស្សិតឆ្នាំទី២ ដែលកំពុងតែសិក្សានៅក្នុងសាលាជំនាញសិល្បៈសូនរូបហ្វាពន្ធីសិល្បៈ ស្ថិតនៅខេត្តបាត់ដំបង និងត្រូវបានយកមកដាក់តាំងបង្ហាញនៅក្នុងព្រឹត្តិការណ៍នេះ។

ពិព័រណ៍សហសម័យ៖ «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា» បានកើតចេញពីគំនិតស្រមើស្រមៃរបស់និស្សិតទៅលើសម័យសង្គមរាស្ត្រនិយម ដែលជាសម័យកាលមួយដែលប្រទេសកម្ពុជាទើបតែទទួលបានឯករាជ្យពីប្រទេសបារាំង និងមិនទាន់បានរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរពីសង្គ្រាម។ យើងមើលឃើញថាប្រទេសកម្ពុជានាសម័យនោះ បានចាប់ផ្តើមរស់ឡើងវិញនៃវប្បធម៌អរិយធម៌ខ្មែរដែលនាំឲ្យមានការរីកចម្រើនយ៉ាងខ្លាំងលើវិស័យសិល្បៈ ដូចជា ចម្រៀង ខ្សែភាពយន្ត និងស្ថាបត្យកម្មដែរ។

លោក ស្រី បណ្ឌុល ស្ថាបនិករបស់សាលាជំនាញសិល្បៈសូនរូបហ្វាពន្ធីសិល្បៈបាននិយាយថា គោលគំនិតសំខាន់ចំពោះប្រធានបទនេះ គឺកើតឡើងមកពីកិច្ចពិភាក្សាគ្នាជាមួយនឹងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំកន្លងទៅនេះ។ លោកពិតជាមានការបារម្ភយ៉ាងខ្លាំងចំពោះសំណង់ដែលកំពុងតែសាងសង់សព្វថ្ងៃនេះ ស្ថិតនៅទីតាំងក្បែរវិមានឯករាជ្យនិងព្រះបរមរាជវាំង។ ដូចនៅក្នុងប្រទេសកូរ៉េខាងត្បូងដែរ បន្ទាប់ពីសង្គ្រាមបានបញ្ចប់សេដ្ឋកិច្ចប្រទេសនេះបានចាប់ផ្តើមរីកចម្រើនយ៉ាងខ្លាំង ដោយឃើញមានសំណង់អគារខ្ពស់ៗជាច្រើន ត្រូវបានសាងសង់ដែលអគារទាំងនោះមិនសូវបានរក្សានូវអត្តសញ្ញាណរបស់ប្រទេសកូរ៉េត្បូងទេ។ ដូច្នេះលោក ឆាំង យុ បានឲ្យសិស្សទាំងអស់គូរគំនូររបស់ខ្លួនចេញពីការស្រមើស្រមៃថា ប្រសិនបើប្រទេសកម្ពុជាមិនមានសង្គ្រាមនិងអំពើប្រល័យពូជសាសន៍កើតឡើងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ តើប្រទេសយើងនឹងអាចរីកចម្រើនបានដល់កម្រិតណា។ សិស្សទាំងអស់ក៏បានសិក្សាអំពីទីតាំងពីរផ្សេងគ្នា គឺទេសភាពនៅក្នុងរាជធានីភ្នំពេញ និងវាលពិឃាដជើងឯកនិងទួលស្លែង។

### គោលបំណងនៃការតាំងពិព័រណ៍

ស្នាដៃនៃការតាំងពិព័រណ៍រូបគំនូរនេះគឺជាផ្នែកមួយនៃការជួយជំរុញ លើកទឹកចិត្ត និងការដាស់តឿនស្មារតីដល់ក្មេងៗជំនាន់ក្រោយ និងអ្នកដែលធ្វើការងារពាក់ព័ន្ធនឹងផ្នែកស្ថាបត្យ កម្ម ការតុបតែង អ្នករចនាទីក្រុង និងអាជ្ញាធរដែនដីឲ្យនឹកឃើញទៅនឹងអ្វីដែលយើងបានបាត់បង់ ហើយស្តារឡើងវិញ ដើម្បីការរៀបចំកសាងអគារបែបនេះ ដែលអាចជះឥទ្ធិពលទៅលើផ្នត់គំនិតនៃការកសាងទីក្រុងថ្មីទាំងពេលបច្ចុប្បន្ន និងអនាគតកាល។

### ការរំពឹងទុកចំពោះការតាំងពិព័រណ៍

ការតាំងពិព័រណ៍ស្តីពី «ប្រសិនបើមិនមានសង្គ្រាម និង

អំពើប្រល័យពូជសាសន៍នៅកម្ពុជា» សង្ឃឹមថានឹងមានការចូលរួមទស្សនាយ៉ាងច្រើនកុះករ ជាពិសេសការអញ្ជើញចូលរួមពីគរុសិស្ស ដែលកំពុងតែសិក្សានៅវិទ្យាស្ថានជាតិអប់រំ ព្រោះគរុសិស្សគឺជាធនធានមួយយ៉ាងសំខាន់នៅក្នុងវិស័យអប់រំ ដែលអាចជួយបណ្តុះគំនិតសិស្សពីអ្វីដែលគាត់បានស្វែងយល់អំពីការតាំងពិព័រណ៍នេះ។ ព្រឹត្តិការណ៍នៃការតាំងពិព័រណ៍ ក៏អាចចែករំលែកដល់ក្មេងៗជំនាន់ក្រោយឲ្យយល់ដឹងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមនិងផលវិបាកដែលបានបន្សល់ទុកនៃរបបនេះ ឲ្យបានកាន់តែទូលំទូលាយថែមទៀត។



សិស្សានុសិស្សទស្សនាពិព័រណ៍សហសម័យ ៖ ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៅវិចិត្រសាលសហសម័យវិទ្យាស្ថានស្ទឹករីត។

**ផលវិបាក**

ដំណើរការនៃការតាំងពិព័រណ៍ មិនសូវមានអ្វីជាឧបសគ្គខ្លាំងនោះទេ។ សិស្សមួយចំនួនបានបោះបង់ការគូរគំនូររបស់ខ្លួនព្រោះដោយសារតែភាពមមាញឹកក្នុងការសិក្សា និងជួបប្រទះផលវិបាកនៃការប្រើប្រាស់គំនិតក្នុងការស្រមើស្រមៃអំពីស្ថានភាពរបស់ប្រទេសកម្ពុជាដែលគ្មានសង្គ្រាមបំផ្លិចបំផ្លាញក៏ដូចជាការខ្វះភាពអត់ធ្មត់របស់និស្សិត ទៅលើការគូរគំនូររបស់ខ្លួន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការគូររូបគំនូរចំនួន១៥ផ្ទាំង និងការតាំងពិព័រណ៍នេះត្រូវបានរៀបចំឡើងដោយជោគជ័យ។

អត្ថន័យរបស់ផ្ទាំងគំនូរនីមួយៗ ៖

១) ផ្ទាំងគំនូរទី១

*យឿត យៀង គឺជានិស្សិតឆ្នាំទី២នៃសាលាហ្វាពន្លឺសិល្បៈ ស្ថិតនៅក្នុងខេត្តបាត់ដំបង។ យៀង បានបកស្រាយអំពីរូបគំនូររបស់គាត់ថា៖ គំនូររបស់ខ្ញុំ គឺមានការផ្សំផ្គុំក្បាច់ខ្មែរបុរាណជាច្រើនចូលគ្នាទៅលើអាគារទំនើប។ ខ្ញុំបានធ្វើការស្រាវជ្រាវតាមរយៈការស្រមើស្រមៃ ការថតរូបនៅក្នុងទីក្រុងភ្នំពេញក្បែរវិមានឯករាជ្យ ការសិក្សាពីរូបគំនូរវិចិត្រករល្បីៗ និងការស្រឡាញ់ក្បាច់បុរាណខ្មែរសម្រាប់ខ្លួនខ្ញុំផ្ទាល់តែម្តង។ ខ្ញុំបានប្រើប្រាស់រចនាបទខ្មែរទាំងអស់នៅក្នុងរូបគំនូររបស់ខ្ញុំ និងបានបន្ថែមពណ៌នៅលើរូបគំនូររបស់ខ្ញុំឲ្យមានភាពល្អឆើតឆាយ រស់រវើកនៅក្នុងទីក្រុងដ៏ចំណាស់មួយនេះ។ ខ្ញុំបានប្រើប្រាស់រយៈពេលប្រហែល១ខែសម្រាប់ការគូរគំនូរនេះ ហើយក៏បានជួបប្រទះការលំបាកខ្លះចំពោះសម្ភារសម្រាប់គូរដូចជាក្រណាត់ហាក់បីដូចជាក្រាស់បន្តិចដែលធ្វើឲ្យខ្ញុំពិបាកក្នុងការគូសក្បាច់។ ប៉ុន្តែទោះបីជាយ៉ាងណា ខ្ញុំបានគូសរូបតាមការស្រមើស្រមៃរបស់ខ្ញុំចំពោះទីក្រុងភ្នំពេញ ប្រសិនបើគ្មានសង្គ្រាម និងអំពើប្រល័យពូជសាសន៍កើតឡើង។ ខ្ញុំសង្ឃឹមថាគំនូររបស់ខ្ញុំអាចចែករំលែកដល់អ្នកទស្សនាស្គាល់នូវអត្តសញ្ញាណក្បាច់ខ្មែរនៅក្នុងសម័យទំនើបមួយ។*

*២) ផ្ទាំងគំនូរទី២*

*ខ្ញុំឈ្មោះ លឹម ស្រីឈីង ជានិស្សិតឆ្នាំទី២នៃសាលាជំនាញសិល្បៈសូនរូបហ្វាពន្លឺសិល្បៈ និងកំពុងតែសិក្សាជំនាញគណនេយ្យនៅសាកលវិទ្យាល័យបាត់ដំបង។ ខ្ញុំមិនមែនជាអ្នកពូកែគូរគំនូរអ្វីទេប៉ុន្តែរូបគំនូររបស់ខ្ញុំគឺជាអ្វីដែលបានកើតចេញពីក្តីស្រមើស្រមៃចំពោះទីក្រុងភ្នំពេញថាតើទីក្រុងនេះនឹងមានភាពស្រស់ស្អាត និងរក្សាបាននូវវប្បធម៌ដ៏ត្រចះត្រចង់របស់ខ្មែរដូចម្តេចខ្លះប្រសិនបើមិនទទួលរងការបំផ្លិចបំផ្លាញដោយសារសង្គ្រាមដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំចង់បានទីក្រុងទំនើបមួយដែលសាងសង់អគារមានលាយឡំជាមួយក្បាច់រចនាបុរាណខ្មែរ និងមានធម្មជាតិនៅអមជាមួយ។ ការគូររូបគំនូរនេះពិតជាពិបាកណាស់សម្រាប់ខ្ញុំព្រោះខ្ញុំត្រូវអត់ធ្មត់ និងធ្វើការស្រមើស្រមៃខ្ពស់ទៅនឹងអ្វីដែលមិនអាចកើតឡើងបានព្រោះសង្គ្រាមបានកើតឡើងរួចទៅហើយ។ ខ្ញុំគិតថាប្រសិនបើគ្មានសង្គ្រាមទេ ទីក្រុងភ្នំពេញនឹងអាចរក្សាបាននូវរចនាបទរបស់ខ្លួនបានយ៉ាងច្រើន។ ខ្ញុំបានចំណាយពេលប្រហែលជិតពីរខែសម្រាប់គូរគំនូរ១ផ្ទាំងនេះ។ ខ្ញុំសង្ឃឹមថារូបគំនូររបស់ខ្ញុំនឹងអាចបណ្តុះគំនិតអ្នកទស្សនា សម្រាប់ការចូលរួមកែលម្អទីក្រុងភ្នំពេញនាពេលអនាគត។*

*៣) ផ្ទាំងគំនូរទី៣*

*ខ្ញុំឈ្មោះ យ៉េន ស៊ីណា គឺជាព្រះសង្ឃ ដែលសព្វថ្ងៃកំពុងតែសិស្សឆ្នាំទី២ នៃសាលាជំនាញសិល្បៈសូនរូប ហ្វាពន្លឺសិល្បៈ។ ខ្ញុំបានគូររូបគំនូរចំនួនពីរផ្ទាំងហើយបានយកមកដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាលសិល្បៈសហសម័យ វិទ្យាស្ថានស៊ីករីតថ្ងៃនេះ។ ខ្ញុំបានចំណាយពេលប្រហែល៤សប្តាហ៍ក្នុងការគូររូប២ផ្ទាំងនេះ។ រូបគំនូរទាំងនេះ កើតចេញពីគំនិតនិងការណែនាំរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានបង្កើតប្រធានបទសម្រាប់គំនូរទាំងនេះឡើងថា ប្រសិនបើគ្មានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា តើប្រទេសយើងនឹងរីកចម្រើនយ៉ាងដូចម្តេច។ ដូចច្នេះហើយ ខ្ញុំបានចាប់ផ្តើមគិតពីវប្បធម៌ប្រពៃណីរបស់ខ្មែរពីសម័យមុន ដោយបាននឹកឃើញដល់រូបចម្លាក់ក្បាច់ខ្មែរបុរាណ ថាតើខ្ញុំគួរតែយកក្បាច់បុរាណទាំងអស់ភ្ជាប់ទៅលើអគារទំនើបខ្ពស់ៗយ៉ាងដូចម្តេចទើបអាចបង្ហាញពីវប្បធម៌របស់ខ្មែរបាន។ ខ្ញុំជួបការលំបាកខ្លះដែរ ព្រោះខ្ញុំត្រូវការស្វែងរកគំនិតច្រើនក្នុងការគូររូបធ្វើយ៉ាងណាឲ្យអ្នកទស្សនាស្គាល់ថា ជាទីក្រុងមួយមានដែលលក្ខណៈបុរាណ ប៉ុន្តែស៊ីវិល័យ។ ខ្ញុំគិតថា រូបគំនូរ២ផ្ទាំងនេះអាចផ្តល់ផលប្រយោជន៍បានអាស្រ័យទៅលើចំណាប់ចំណូលចិត្តរបស់អ្នកទស្សនា និងការយកទៅប្រើប្រាស់ ប៉ុន្តែខ្ញុំសង្ឃឹមថារូបគំនូរនេះអាចផ្តល់ផលប្រយោជន៍ដល់វិស្វករដែលមានគម្រោងសាងសង់អគារនៅក្នុងទីក្រុងក៏ដូចជានៅក្នុងប្រទេសកម្ពុជានាពេលអនាគតដែរ។*

*៤) ផ្ទាំងគំនូរទី៤*

ខ្ញុំឈ្មោះ វ៉េន វណ្ណា គឺជានិស្សិតឆ្នាំទី២នៃសាលាជំនាញសិល្បៈសូនរូបហ្វាពន្លឺសិល្បៈដែលស្ថិតនៅក្នុងខេត្តបាត់ដំបង។ រូបគំនូរនេះ គូរចេញពីក្តីស្រមើស្រមៃរបស់ខ្ញុំចំពោះទីក្រុងភ្នំពេញប្រសិនបើមិនធ្លាប់បានជួបប្រទះសង្គ្រាម។ រូបគំនូររបស់ខ្ញុំ គឺជាគំនូរបែបសហសម័យដែលបានបង្ហាញសិល្បៈរបស់ខ្មែរ និងអាចជួយឲ្យបរទេស ឬក្មេងៗជំនាន់ក្រោយបានស្គាល់។ ខ្ញុំបានចំណាយពេលប្រហែលជិត២ខែសម្រាប់គូររូបគំនូរ១ផ្ទាំងនេះ ហើយបានជួបផលលំបាកខ្លាំងចំពោះការផាត់ពណ៌ ព្រោះខ្ញុំត្រូវរៃលកថាតើរូបគំនូរនេះត្រូវផាត់ពណ៌យ៉ាងណាឲ្យសមស្របគ្នាជាមួយនឹងប្រធានបទ។ ខ្ញុំបានសង្កេតមើលឃើញអ្នកទស្សនាភាគច្រើនចាប់អារម្មណ៍ទៅនឹងគំនូរដែលកំពុងតែដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាលនេះ។ នៅថ្ងៃអនាគតខ្ញុំចង់ឲ្យទីក្រុងភ្នំពេញទទួលបានការរីកចម្រើនខ្លាំង ប៉ុន្តែអាចរក្សាបាននូវអ្វីដែលជាតំណាងឲ្យប្រទេសកម្ពុជា និងសិល្បៈរបស់ខ្មែរឲ្យនៅគង់វង្ស។

**ទស្សនៈរបស់អ្នកចូលរួមទស្សនាការតាំងពិព័រណ៍**

១) ព្រំ គិតម៉ាន់ ភេទប្រុស គឺជានិស្សិតឆ្នាំទី២ ជំនាញរដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

«នៅពេលដែលខ្ញុំបានទទួលដំណឹងថាមានការដាក់តាំងពិព័រណ៍ ដែលនិយាយអំពី «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា» ខ្ញុំពិតជាចាប់អារម្មណ៍ណាស់ ហើយក៏បានមកចូលរួមក្នុងថ្ងៃនេះ។ ខ្ញុំគិតថាពិព័រណ៍នេះមានលក្ខណៈប្លែកពីគេ និងអាចរៀបរាប់ប្រាប់យើងបានថាប្រសិនបើប្រទេសយើងមិនបានជួបប្រទះនឹងសង្គ្រាមនោះទេគឺ ប្រទេសយើងនឹងមានទិដ្ឋភាពស្អាតៗដូចរូបគំនូរដែលកំពុងតែដាក់តាំងបង្ហាញនៅក្នុងពិព័រណ៍នេះ ឬក៏អាចរីកចម្រើនជាងអ្វីដែលបានគូសនៅក្នុងរូបគំនូរនេះថែមទៀត។ រូបគំនូរទាំងនេះ អាចឲ្យយើងយល់ដឹងកាន់តែច្បាស់ អំពីផលវិបាកដែលបានបន្សល់ទុកពីសង្គ្រាមដែលបានកើតឡើងអស់រយៈពេលជាច្រើនទសវត្សរ៍នៅក្នុងប្រទេសកម្ពុជា និងជាសារមួយអាចជួយអប់រំក្មេងៗជំនាន់ក្រោយឲ្យចេះថែរក្សាប្រពៃណីទំនៀមទម្លាប់ និងរួមគ្នាការពារកុំឲ្យសង្គ្រាមកើតមានម្តងទៀតនៅពេលអនាគត»។

២) យន់ ស៊ីណូត ភេទស្រី គឺជាគរុនិស្សិតផ្នែកព័ត៌មានវិទ្យានៃវិទ្យាស្ថានជាតិអប់រំ។ «ខ្ញុំបានទទួលដំណឹងអំពីការតាំងពិព័រណ៍រូបគំនូរនេះតាមរយៈមិត្តភក្តិរៀនជាមួយគ្នា។ ខ្ញុំពិតជាចាប់អារម្មណ៍ចំពោះការតាំងពិព័រណ៍រូបគំនូរនេះណាស់ ព្រោះខ្ញុំចូលចិត្តរូបគំនូរ។ ខ្ញុំសង្កេតឃើញថារូបគំនូរទាំងអស់នេះ បានប្រើប្រាស់រចនាបទខ្មែរលើអគារខ្ពស់ៗ ក្នុងសម័យទំនើប ដែលនេះបានបង្ហាញថាប្រសិនបើប្រទេសយើងគ្មានសង្គ្រាមទេ យើងនឹងមានការអភិវឌ្ឍន៍ខ្លាំងជាងសព្វថ្ងៃនេះ។ ការដាក់តាំងពិព័រណ៍នេះពិតជាល្អណាស់សម្រាប់ក្មេងៗជំនាន់ក្រោយ។ វាពិតជាកាន់តែមានសារប្រយោជន៍បន្ថែមទៀតប្រសិនបើមានការដាក់តាំងពិព័រណ៍រូបគំនូរទាំងអស់នេះនៅទីកន្លែងផ្សេងៗទៀតជាពិសេសតាមសាលារៀន ដើម្បីឲ្យសិស្សអាចទទួលបានព័ត៌មានទាំងអស់នេះ។ ចំពោះខ្ញុំ ការទស្សនាការតាំងពិព័រណ៍នេះគឺវាជាការកំសាន្តអារម្មណ៍ និងក៏ជាការរំឭកឡើងវិញអំពីសម័យបុរាណ និងអ្វីៗដែលខ្មែរយើងធ្លាប់មានកាលពីអតីតកាល។ ខ្ញុំនឹងចែករំលែកអ្វីៗដែលខ្ញុំបានឃើញក្នុងថ្ងៃនេះ ទៅដល់សិស្សរបស់ខ្ញុំនាពេលអនាគត។ ដោយសារតែប្រទេសយើងធ្លាប់ជួបប្រទះអំពើប្រល័យពូជសាសន៍ទើបយើងត្រូវចាប់ផ្តើមកសាងប្រទេសពីចំណុចសូន្យឡើងវិញ»។

៣) ខ្ញុំឈ្មោះ ឈួន សុលីណា ភេទស្រី គឺជាគរុនិស្សិតជំនាន់ទី២៨មុខវិជ្ជាគណិតវិទ្យានៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំគិតថាការតាំងពិព័រណ៍រូបគំនូរនេះគឺពិតជាល្អណាស់ ព្រោះអាចឲ្យខ្ញុំទទួលបានឱកាសរៀនសូត្រពីអ្វីដែលថ្មីៗ និងរូបភាពស្អាតៗដែលបានឆ្លុះបញ្ចាំងពីទីក្រុងមួយ ដែលកំពុងតែរីកចម្រើនខ្លាំង។ រូបគំនូរនេះក៏ជួយឲ្យខ្ញុំដឹងថាប្រទេសកម្ពុជាយើងធ្លាប់មានអរិយធម៌ដ៏ត្រចះត្រចង់កាលពីអតីតកាលដែរ។

**អ៊ុន សុដាវី**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុង សៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

គុយ ឆេងឡាយ មានអាយុ៤១ឆ្នាំ ក្នុងឆ្នាំ១៩៧៥ ស្រុកកំណើតនៅសង្កាត់លេខ៤ ក្រុងភ្នំពេញ ជាកូនរបស់អ៊ំ គុយ យូរ និងអ៊ំស្រី គីម ហុង ជាកម្មកររោងចក្ររទេះភ្លើង មានប្រពន្ធឈ្មោះនាងគីមឡាយ មានកូនប្រុស១នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅទួលគោក ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកស្លែងក្នុងផ្ទះ យ បន្ទប់ធំ ២ បន្ទប់តូច ៣។ ខ្មែរក្រហមបញ្ជូន គុយ ឆេងឡាយ ចូលគុកទួលស្លែងនៅថ្ងៃបន្ទាប់គឺថ្ងៃទី២១ខែវិច្ឆិកាឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦៩ថ្ងៃ។

គុយ ជា ខ្មែរនិយាយវិទ្យុរុស្ស៊ី ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុង១៩៧៦នៅរុស្ស៊ី។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា គុយ ជា ធ្លាប់នៅបឹងត្របែក ត្រូវបានខ្មែរក្រហមចាប់បញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២៩៧៦។ ខ្មែរក្រហមសម្លាប់ គុយ ជា នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៧៥ថ្ងៃ។

គុយ ឈុនត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រកន្ទុកក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសា-មញ្ញក្នុងតុលាការកម្ពុជា រកឃើញថា គុយ ឈុន គឺជាប្រពន្ធរបស់ ព្រូ ស្រុន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនដល់គុកទួលស្លែងនៅថ្ងៃទី៤ខែតុលាឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១១ថ្ងៃ។ ប្តីឈ្មោះ ព្រូ ស្រ៊ុន ត្រូវបានខ្មែរក្រហមចាប់ខ្លួនមកជាមួយប្រពន្ធ ព្រមទាំងកូនប្រុសឈ្មោះ ស្រ៊ុន ហ៊ុន និងកូនស្រីឈ្មោះ ស្រ៊ុន ហន់។ ខ្មែរក្រហមសម្លាប់ប្តីក្រោយប្រពន្ធ គឺនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ស្រ៊ុន ហ៊ុន នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៦។ រីឯឈ្មោះ ស្រ៊ុន ហន់ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គុយ លៀងហៅណាតមានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភូមិប្រូនាង ជាកូនរបស់ពូ អ៊ីង និងមីង អ៊ើង ជាពេទ្យកងពល៣១០ តំបន់ ៣១ មានប្តីឈ្មោះ កែវ ថៅ ហៅ ណាង មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦ នៅកងពល៣១០ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ២ បន្ទប់តូច ១៦ នៅថ្ងៃដដែល។ ខ្មែរក្រហមសម្លាប់ គុយ លៀង (លាង) នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៧ ថ្ងៃ។

គុយ អែត មានអាយុ២៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាកូនរបស់ពូ ស្រិន គុយ និងមីង ជា សួង មានប្រពន្ធឈ្មោះ ញ៉ាយ លាង មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅអូជ្រៅ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ៣ បន្ទប់តូច ១។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការចាប់ខ្លួន និងសម្លាប់នៅឡើយ។

គុល សឿន មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ត្រាច ខេត្តកំពត ជាកូនរបស់អ៊ំ គុល វិត និងអ៊ំស្រី អៀម សៀង មានប្រពន្ធឈ្មោះ សួន សុផុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៧៦ នៅព្រៃនប់ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៨ បន្ទប់តូច ១៤។

គុលសាវឿន ដឺម៉ុងតេរ៉ូ មានអាយុ៤៥ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតពេទ្យ មានស្រុកកំណើតនៅរលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាកូនរបស់អ៊ំ គុលសាវ៉ៃ ដឺម៉ុងតេរ៉ូ និងអ៊ំស្រី នាង វ៉ែន មានប្រពន្ធឈ្មោះ គីម លី មានកូនប្រុស៣នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅរកាកោង ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៥ បន្ទប់តូច ៨។ ខ្មែរក្រហមបញ្ចូល គុលសាវឿន ក្នុងគុកទួលស្លែងនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៦ ខែឆ្នាំដដែល។

គូ ស៊ុំ សុវង់ មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំស្រុក ខេត្តបន្ទាយមានជ័យ ជាមូនរបស់អ៊ំ គូ ស៊ុំ គុក និងអ៊ំស្រី មុង ខែង អ្នកយាមម៉ាស៊ីននៅរោងចក្រអគ្គិសនីចាក់អង្រែ មានប្រពន្ធឈ្មោះ ឃ្លឹង ស៊ីហ៊ាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ១។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គួយ គ្រី អាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៦ តំបន់២៥ (ស្រុកកៀនស្វាយ ខេត្តកណ្តាល) ជាកូនរបស់ពូ គួយ មាំង និងមីង ហាក់ សាង យុទ្ធជនកង១៣ ២១យ កងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់បញ្ជូន គួយ គ្រី មកដាក់គុកទួលស្លែងមកពីមន្ទីរ ស-២១ យ និងសម្លាប់នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

(គួយ) គួយ សឿន មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក៥១ (ស្រុកភ្នំស្រួច) ខេត្តកំពង់ស្ពឺ ជាកូនរបស់អ៊ំ ប៉ៅ គួយ និងអ៊ំស្រី ញ៉ែម យ៉ែម លេខាស្រុកត្រពាំងវែង មានប្រពន្ធឈ្មោះ ចាប ខំ មានកូនប្រុស១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦ នៅស្រុក២៨ តំបន់៣២ ខេត្តកំពង់ស្ពឺ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ យ បន្ទប់ធំ ៤ បន្ទប់តូច ៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គួរទីញោ អង់ជ្រេហ្កាស្តុង មានអាយុ៣០ឆ្នាំ ក្នុងឆ្នាំ ១៩៧៦ ជនជាតិបារាំង ស្មៀននៅទូតបារាំង ខាងវ៉ាយអត្តលីលេខ ស្រុកកំណើតនៅលីវ៉ា ខេត្តបារាំង មានឪពុកម្តាយ គួរទីញោ ម៉ាក់ តូ និង និល ផន ជាកសិករស្ទូងនិងមើលគោ មានប្រពន្ធឈ្មោះ ធាយ រាសី មានកូនប្រុស១នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៦ នៅស្រុកកំពង់ក្តី (ខេត្តសៀមរាប) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៧ បន្ទប់ធំ ៩។ ខ្មែរក្រហមសម្លាប់ គួរទីញោ អង់ជ្រេហ្កាស្តុង នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៦។

គៀត សំអឿន អាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅពញាឮ ខេត្តកណ្តាល ជាកូនរបស់អ៊ំ គៀតសំអឿន និងអ៊ំស្រី អ៊ុម ដាភ្លឹម ជាកម្មករអគ្គិសនី មានប្រពន្ធឈ្មោះ អឹម ដាភ្លឹម មានកូនប្រុស១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥ នៅអគ្គិសនីផ្សារតូច ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៨ បន្ទប់តូច ១៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការចាប់ខ្លួន និងសម្លាប់នៅឡើយ។

គៀង វ៉ាន់នី ហៅ ខន មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៥ នៅរៀន មានស្រុកកំណើតនៅមុខកំពូល ខេត្តកណ្តាល ជាកូនរបស់ពូ គៀង យឿក និងមីង ជាច់ ចំហៀង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅដីឥដ្ឋ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៦ បន្ទប់តូច ១៧។ ខ្មែរក្រហមសម្លាប់ គៀង វ៉ាន់នី នៅថ្ងៃទី២៧ ខែឧសភា

ឆ្នាំ១៩៧៦។

គៀង សូលី មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតពេទ្យនៅកោះកុង មានស្រុកកំណើតនៅមុខកំពូល ខេត្តកណ្តាល ជាកូនរបស់ពូ គៀង ឈឿន និងមីង នាង ថាចបៀ កម្មករអគ្គីសនីរោងចក្រផ្សារតូច មានប្រពន្ធឈ្មោះ នាង សំសាវី មានកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅមន្ទីរសួរចម្លើយ ភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៧ បន្ទប់តូច ២២។ ខ្មែរក្រហមបញ្ចូល គៀង សូលី មកគុកទួលស្លែងនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

(គៀត) គៀត សំអាន មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ នៅរៀន មានស្រុកកំណើតនៅពញាឮ ខេត្តកណ្តាល ជាកូនរបស់ពូ គៀត អុល និងមីង ឃឹម គីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ នៅអគ្គីសនីផ្សារតូច ភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១០ បន្ទប់ធំ ៤។ ខ្មែរក្រហមបញ្ចូល គៀត សំអាន មកគុកទួលស្លែងនៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គៀម ពុយ មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្អាង ខេត្តកណ្តាល ជាកូនរបស់អ៊ំ គៀមប៉ាវស៊ិន និងអ៊ំស្រី ឡោ យាន ជាកម្មករអគ្គីសនីផ្សារតូច មានប្រពន្ធឈ្មោះ ហួន លាងឆាយ ហៅ ទូច មានកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៤ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ២០។ ថ្ងៃខែដែលបញ្ចូលមកគុកទួលស្លែងមាន៣ផ្សេងគ្នា គឺ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៥, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦, ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ គៀម ពុយ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦។

កែ ស៊្រិន ហៅ ស៊ិន មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃកប្បាស ខេត្តតាកែវ ជាកូនរបស់អ៊ំ កែវ នៅ និងអ៊ំស្រី កាន់ ញ៉ិល មានប្រពន្ធឈ្មោះ កៅ សារី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៧ នៅរទេះភ្លើងកំពង់សោម។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គ្រី ដា ជាអនុក្រុមមន្ទីរពិការ ៦២ ត្រូវបានខ្មែរក្រហមឃាត់ខ្លួនថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦ នៅមន្ទីរពិការ ៦២។ ខ្មែរក្រហមសម្លាប់ គ្រី ដា នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦។

គ្រីន លាន ហៅ សំ មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជកូនរបស់អ៊ំ គ្រីន ហាក់ និងអ៊ំស្រី កេង នាង ជាយុទ្ធជននៅប-១ សាលាបច្ចេកទេសឫស្សីកែវ មានប្រពន្ធឈ្មោះ អ៊ីវ កន្ធារា ហៅ សី ត្រូវបានខ្មែរក្រហមចាប់នៅខ្លួនថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ នៅឫស្សីកែវ ភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១ បន្ទប់ធំ ៣ បន្ទប់តូច ៨។ ខ្មែរក្រហមសម្លាប់ គ្រីន លាន នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈ ៩៦ ថ្ងៃ។

គ្រុឌ ហោ មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១៦(ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់អ៊ំ សំ គ្រុឌ និងអ៊ំស្រី តូច ឡៀង ជាប្រជាជនមូលដ្ឋាន មានប្តីឈ្មោះ ពុត ប៊ុម មានកូនប្រុស៣នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៦ នៅស្រុក១៦ (ស្រុកស្អាង) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ១៤។ ខ្មែរក្រហមសម្លាប់ គ្រុឌ ហោ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៦។

គ្រួច គីមអេង មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបរិបូរ ខេត្តកំពង់ឆ្នាំង ជាកូនរបស់ពូ គ្រួច ចេង និងមីង នង អុន ជាយុទ្ធជនក្នុងកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ នៅកងពល៣១០ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៣ បន្ទប់តូច ១៤។ ខ្មែរក្រហមបញ្ចូល គ្រួច គីមអេង មកគុកទួលស្លែងនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គ្រួច ឃួន ជាយុទ្ធជននៃកងពល ១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូល គ្រួច ឃួន មកគុកទួលស្លែងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៧ ខែតុលា ឆ្នាំងដដែល។

យន់ ឃិន ហៅ ជុំ ជឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់ ៣៣ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូល យន់ ឃិន ហៅ ជុំ ជឿន មកគុកទួលស្លែងនៅថ្ងៃទី៦-៧ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

ឃិន សារ៉ាត មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក ១៥៤ (ស្រុក) ខេត្តកណ្តាល ជាកូនរបស់ពូ ជា ឃិន និងមីង ញឹម សុល មានប្រពន្ធឈ្មោះ ខៀវ ស៊ីប៉ន ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២៨ ឆ្នាំ១៩៧៧ នៅព្រែកហូរ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០២ បន្ទប់ធំ ៧។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា មានកាលបរិច្ឆេទនៃការបញ្ជូនមកដល់គុកទួលស្លែងពីរផ្សេងគ្នា មួយគឺនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងមួយទៀតគឺថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឃិន សារ៉េត នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៦។

ឃិន អ៊ិន ហៅ អេង កងពល១៧០ (កងពលថ្មី ៥០២) ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៥០២ ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឃី យួន មានអាយុ៥០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក ១៦ (ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់លោកតា ឯក ភី និងលោកយាយ ម៉ែន មឿ ជាប្រជាជនចាស់ មានប្តីឈ្មោះ ឌុល ថ្កេក មានកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែមិនា ឆ្នាំ១៩៧៦ នៅស្រុក ១៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុង បន្ទប់ធំ ០៤។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថាមានភាពច្របូកច្របល់លើកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងរហូតដល់ទៅ៣ផ្សេងគ្នា គឺខែមីនា ឆ្នាំ១៩៧៦, ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៦, និងថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦។ រីឯកាលបរិច្ឆេទនៃការសម្លាប់ក៏ដូច្នេះដែរ គឺថ្ងៃទី១ ខែមិថុនា និងមួយទៀត ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ ដូចគ្នា។

ឃី សុឃឹម មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូ វ៉ុន និងមីង ប៊ិន ជាពេទ្យ (៣)៩៨ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៤ បន្ទប់តូច ២ នៅថ្ងៃដដែល។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឃី សេង អាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ ឡូវ ឆន និងមីង អ៊ី យុន ជាជាងក្រឡឹងដែក មានប្រពន្ធឈ្មោះ យូ លន់ខេង មានកូនប្រុស៥នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៧ នៅរោងចក្រដ-៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៧ បន្ទប់ធំ ១៣។ ខ្មែរក្រហមសម្លាប់ ឃី សេង នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

ឃី ហេង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការបញ្ជូនមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។ (**នៅមានត**)

**វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី**

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# កូវ ជ័រ ៖ ពលទាហាន

ប្រពន្ធរបស់គាត់ឈ្មោះ សំរិត គិត បាននិយាយរៀបរាប់ប្រាប់ថា៖

កូវ ជ័រ បានរៀបការជាមួយខ្ញុំនៅពេលដែលគាត់មានអាយុ២២ឆ្នាំ ចំណែកនាងខ្ញុំអាយុ១៨ឆ្នាំ។ ទោះបីជាយើងបានរស់នៅក្នុងភូមិជាមួយគ្នាក៏ដោយ ក៏យើងមិនដែលធ្លាប់ជួបគ្នាដែរ មុនពេលដែលឪពុកម្តាយរបស់គាត់ចូលមកខាងខ្ញុំដើម្បីរៀបចំភ្ជាប់ពាក្យយើងទាំងពីរនាក់។

ឪពុកម្តាយរបស់ខ្ញុំបានសុំថ្លៃបណ្ណាការចំនួន១០០រៀល ដែលកាលណោះ ប្រាក់១០០រៀល មានតម្លៃខ្លាំងណាស់។ ដោយសារឪពុកម្តាយរបស់គាត់បានស្រឡាញ់ពេញចិត្តខ្ញុំ ទើបគាត់យល់ព្រម។ នៅថ្ងៃពិធីមង្គលការរបស់យើង យើងបានសម្លាប់សត្វជ្រូកជាច្រើនក្បាលដើម្បីធ្វើម្ហូបទទួលភ្ញៀវ។


កូវ ជ័រ

បន្ទាប់ពីយើងរៀបការរួច ប្តីរបស់ខ្ញុំបានចូលមករស់នៅខាងឪពុកម្តាយរបស់ខ្ញុំ។ យើងជាអ្នកក្រីក្រ ហើយកម្រមានអាហារហូបគ្រប់គ្រាន់ណាស់។ ជ័រ មិនមានចម្ការទេ ហើយយើងក៏មិនមានស្រែដែរ ដូច្នេះគាត់បានធ្វើការផ្សេងៗ ដូចជា លក់ខស និងលក់នំ។ នៅពេលខ្លះ យើងបានចេញពីភូមិរបស់យើងនៅក្នុងខេត្តកណ្តាល ទៅភ្នំពេញបួន ឬប្រាំថ្ងៃ ដើម្បីលក់ទំនិញនៅតាមផ្សារ។ ក្រោយមកគាត់បានចូលបម្រើកងទ័ព លន់ នល់។

កូនប្រុសរបស់ខ្ញុំឈ្មោះ កូវ ជឿន បានបួសជាសង្ឃចំនួនបីវស្សា មុនពេលចូលធ្វើជាទាហាន។ ជឿន ជាក្មេងសុភាពរាបសារ និងមិនដែលប្រើពាក្យគ្រោតគ្រាតឡើយ។ ជឿន ជាកូនប្រុសតែមួយគត់ នៅក្នុងចំណោមកូន១៣នាក់របស់យើង។ កូនស្រីៗរបស់ខ្ញុំបានឈ្លោះប្រកែកគ្នារាល់ពេល ប៉ុន្តែ ជឿនប្លែកពីគេ។ ប្រសិនបើបងប្អូនស្រីៗវ៉ៃគ្នាដណ្តើមសាច់ត្រីពេលហូបបាយល្ងាច ជឿន ហូបបាយតែបន្តិចបន្តួចប៉ុណ្ណោះ ហើយក៏ដើរចេញពីផ្ទះទៅ។

ជឿន បានសម្រេចចិត្តចូលបម្រើកងទ័ព លន់ នល់ បន្ទាប់ពីបានឮការឃោសនា។ ការចូលធ្វើកងទ័ពនេះ គឺចូលដោយបង្ខំចិត្ត។ ជឿន បានរៀបការជាមួយស្ត្រីម្នាក់ឈ្មោះ ឈូក រុំ ហើយបានមករស់នៅខាងផ្ទះប្រពន្ធ និងមានកូនប្រុសម្នាក់។

ជឿន ត្រូវបានបញ្ជូនទៅសមរភូមិកប់ស្រូវ ប្រហែល ១៥ថ្ងៃ មុនពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ។ ជឿន ត្រូវរបួសចំជើង ហើយបានបញ្ជូនទៅមន្ទីរពេទ្យរុស្ស៊ី

ប៉ុន្តែបានស្លាប់ដោយសារការព្យាបាលមិនបានដិតដល់។ ខ្ញុំបានយកសពរបស់ ជឿន ទៅផ្ទះប្រពន្ធរបស់វានៅស្រុកកំណើតដើម្បីបូជា។ ប្រពន្ធរបស់ ជឿន បានស្រែកយំយ៉ាងខ្លាំងទាល់តែទឹកភ្នែកនាងលែងហូរ។ កូនប្រុសរបស់ ជឿន មានវ័យអាចអង្គុយបាន នៅពេលដែល ជឿន ស្លាប់។

ខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់ ពីការបាត់បង់កូនប្រុសតែមួយរបស់ខ្ញុំ។ ខ្ញុំស្រឡាញ់វាស្មើជីវិតរបស់ខ្ញុំ។ ប្រសិនបើប្រទេសកម្ពុជាមិនមានសង្គ្រាមទេ ជឿន ក៏មិនស្លាប់ដែរ។

មុនពេលខ្មែរក្រហមឡើងកាន់អំណាចបន្តិច គ្រួសារយើងបានចាកចេញពីភូមិ ដើម្បីគេចពីគ្រាប់បែក រួចហើយបានទៅនៅភូមិក្រាំងទ្រា ក្នុងខេត្តកណ្តាល។ យើងមិនបានយករបស់មានតម្លៃទៅតាមខ្លួនទេ ព្រោះយើងមិនមានអ្វីឡើយ យើងយកបានតែខោអាវដែលយើងកំពុងស្លៀកពាក់។ យើងបានត្រឡប់មកភូមិវិញ បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់អំណាចទាំងស្រុង។ លើកនេះខ្ញុំមានឯកសណ្ឋានរបស់ប្តីខ្ញុំ និងរូបថតរបស់គាត់ជាទាហានមួយចំនួន ប៉ុន្តែខ្ញុំបានដុតចោលអស់ហើយ។

ទោះបីជា យើងត្រឡប់មកភូមិវិញក៏ដោយ ក៏ខ្មែរក្រហមបាននិយាយថាយើងជាប្រជាជនថ្មីដែរ។ យើងមិនបានរស់នៅជាមួយប្រជាជនមូលដ្ឋានទេ យើងក៏មិនមានអាហារគ្រប់គ្រាន់ដែរ គឺមានតែបបរលាយជាមួយពោតប៉ុណ្ណោះ។ ក្រោយមកអង្គការបានប្រមូលយករបស់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់យើងមាន អង្ករ ចាន ឆ្នាំង និងអ្វីៗទាំងអស់ដាក់បញ្ចូលទៅក្នុងសហករណ៍ លើកលែងតែខោអាវដែលយើងកំពុងស្លៀកពាក់។ ការងាររបស់ខ្ញុំ ជាអ្នកប្រមូលសំរាមតាមផ្ទះ ហើយយកទៅដាក់នៅកន្លែងមួយសម្រាប់ខ្ញុំលាយធ្វើជាជី។ ដូច្នេះអង្គការបានឲ្យបបរខ្ញុំបីវែក ចំនួនពីរពេលក្នុងមួយថ្ងៃ ដែលវាមិនគ្រប់គ្រាន់ឡើយសម្រាប់ការងារដែលខ្ញុំធ្វើ។ ក្រពះរបស់ខ្ញុំមិនដែលពេញឡើយ បន្ទាប់ពីយើងចាប់ផ្តើមរស់នៅក្នុងសហករណ៍។

អង្គការសង្ស័យលើប្រជាជនដែលកោរសក់ក្បាលដើម្បីកុំឲ្យចៃ ដោយគិតថាអ្នកកោរសក់ទាំងនោះប្រាថ្នាធ្វើបុណ្យ និងបន់ស្រន់នៅក្នុងព្រះវិហារ។ ប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅរៀនសូត្រឡើងវិញ និងសួរសំណួរដេញដោលជាច្រើន។

ជ័រ បានទៅសម្រាកនៅមន្ទីរពេទ្យចំនួនពីរខែដើម្បីព្យាបាលជំងឺរាកមួល។ គាត់មិនចង់លេបថ្នាំគ្រាប់អាចម៍ទន្សាយដែលផលិតដោយអង្គការទេ។ ខ្ញុំចាប់បានអន្ទង់មួយចំនួនរួចលាក់យកទៅឲ្យគាត់ហូប ប៉ុន្តែអង្គការបានឆែកឃើញរួចក៏ដកហូតយកទាំងអស់។ បន្ទាប់មកប្តីខ្ញុំក៏បានស្លាប់ ប្រជាជនថ្មីមួយចំនួនបានជួយសែងសាកសពប្តីខ្ញុំយកទៅកប់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ ខ្ញុំបានត្រឡប់ទៅផ្ទះរបស់ ជ័រ។ ខ្ញុំបានជីកកកាយដីរកឃើញលលាដ៍ក្បាល និងធ្មេញរបស់គាត់។ ខ្ញុំបានយកឆ្អឹងរបស់គាត់ទៅវត្ត ដើម្បីប្រារព្ធពិធីបុណ្យបង្សុកូលឧទ្ទិសជូនគាត់។ ខ្ញុំមិនមានអារម្មណ៍ល្អឡើយ ដោយសារខ្ញុំមិនមានឱកាសនិយាយជាមួយ ជ័រ ព្រោះអង្គការមិនអនុញ្ញាតឲ្យខ្ញុំស្នាក់នៅថែទាំគាត់នៅក្នុងមន្ទីរពេទ្យ។

ខ្ញុំបានរក្សាទុករូបថតពីរសន្លឹកនេះយ៉ាងប្រយ័ត្នប្រយែងនៅក្នុងរបបនោះ។ ខ្ញុំបានទុកដាក់រូបថតនោះនៅក្នុងថង់ប្លាស្ទិកមួយ រួចដាក់នៅក្នុងថង់មួយទៀតនៅខាងក្នុងហោប៉ៅអាវរបស់ខ្ញុំទោះជាដើរទៅទីណាក៏ដោយ ព្រោះអីខ្ញុំខ្លាចអង្គការរកឃើញរូបថតនោះនៅផ្ទះរបស់ខ្ញុំ។ យប់មួយនោះនៅពេលដែលខ្ញុំដើរតាមប្រឡាយ ខ្ញុំបានដើរទាក់នឹងខ្សែដែលភ្ជាប់នឹងអំពូលភ្លើងសម្រាប់បំភ្លឺដល់អ្នកធ្វើការនាពេលយប់។ ខ្ញុំភ័យតក់ស្លុតយ៉ាងខ្លាំង ធ្វើឲ្យខ្ញុំធ្លាក់ចូលទៅក្នុងប្រឡាយទឹក ទទឹកសើមជោគ។ នៅពេលដែលខ្ញុំមកដល់ផ្ទះវិញ ខ្ញុំបានយករូបថតនោះចេញមកហាលឲ្យស្ងួតដោយលាក់លៀម។ ហេតុដូច្នេះបានជារូបថតនោះមានស្នាមប្រេះប្រតាកមកដល់ថ្ងៃនេះ។

ប៉ាង ពីរ័ន្ត និង វេនី ខកហ្មៀល

# ខ្ញុំនៅតែចង់ដឹងពីវាសនាពូរបស់ខ្ញុំ

ខ្ញុំឈ្មោះ ម៉ូនីកា ត្រាន អាយុ៣២ឆ្នាំ សព្វថ្ងៃរស់នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ខ្ញុំមានជីតាឈ្មោះ ត្រាន កាន សព្វថ្ងៃអាយុ៨៥ឆ្នាំ និងយាយឈ្មោះ ត្រាន គាវ ង៉ូ (បានស្លាប់កាលពី ១៥ ឆ្នាំមុន)។ តា និងយាយរបស់ខ្ញុំមានកូនទាំងអស់៤នាក់ ៖ កូនទី១) ត្រូវជាឪពុករបស់ខ្ញុំ កូនទី២) ត្រូវជាពូរបស់ខ្ញុំដែលបានបាត់ខ្លួន កូនទី៣) ត្រូវជាមីង និងកូនទី៤) ត្រូវជាពូ។ បន្ទាប់ពីយោធាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តា យាយ ឪពុករបស់ខ្ញុំ និងពូមីង បានភៀសខ្លួនទៅប្រទេសវៀតណាម ដោយចំណាយពេលធ្វើដំណើររយៈពេលប្រហែល៤០ថ្ងៃ។ មូលហេតុដែលគ្រួសាររបស់ខ្ញុំធ្វើដំណើរទៅប្រទេសវៀតណាម ដោយសារយាយរបស់ខ្ញុំមានសាច់ញាតិរស់នៅទីនោះ។ ប៉ុន្តែ ក្នុងអំឡុងពេលភៀសខ្លួននោះ មិនមានវត្តមានពូរបស់ខ្ញុំម្នាក់ (ត្រូវជាកូនទីពីររបស់យាយតាខ្ញុំ) រស់នៅម្តុំផ្សារដើមគរធ្វើដំណើរទៅជាមួយទេ ហើយយើងក៏មិនបានដឹងថា មានរឿងរ៉ាវអ្វីកើតឡើងចំពោះគាត់ដែរ។ ខ្ញុំតែងតែសង្ឃឹមថា យ៉ាងហោចណាស់ក្រុមគ្រួសាររបស់ខ្ញុំអាចទទួលបានព័ត៌មានខ្លះពីគាត់ ទោះមានរឿងរ៉ាវអ្វីកើតឡើង ចំពោះគាត់ក៏ដោយ។ ការបាត់ខ្លួនពូរបស់ខ្ញុំ បានធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំទាំងមូលទទួលរងការឈឺចាប់យ៉ាងខ្លាំងដូចជាក្រុមគ្រួសារផ្សេងទៀតដែលបានបាត់



រូបថតក្រុមគ្រួសាររបស់ ម៉ូនីកា ត្រាន

សមាជិករបស់ខ្លួនដូច្នេះដែរ។ រឿងរ៉ាវបែកបាក់របស់ក្រុមគ្រួសារខ្ញុំបានកន្លងផុតអស់រយៈពេលជាង ៤០ឆ្នាំ មកហើយ ប៉ុន្តែហេតុការណ៍ដែលខ្ញុំនៅតែចង់ដឹង គឺជោគវាសនាពូរបស់ខ្ញុំ ដែលបានបែកពីក្រុមគ្រួសារក្នុងអំឡុងពេលយោធាខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស និងបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥។ ក្នុងអំឡុងពេលនោះ ពូរបស់ខ្ញុំបានស្នាក់នៅម្តុំផ្សារដើមគក្រុងភ្នំពេញ ប៉ុន្តែដោយសារស្ថានការណ៍ចលាចល ទើបធ្វើឲ្យពូរបស់ខ្ញុំដែលមានអាយុ១៧ឆ្នាំ វង្វេងបែកពីក្រុមគ្រួសារ និងយាយតារបស់ខ្ញុំ។ បច្ចុប្បន្ន ទោះបីជាខ្ញុំខិតខំប្រមែប្រមូលសាច់រឿងពូរបស់ខ្ញុំពីអ្នកដែលធ្លាប់ស្គាល់គាត់ និងក្រុមគ្រួសាររបស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែទទួលបានព័ត៌មានតិចតួចនៅឡើយ។ ដូច្នេះហើយទើបខ្ញុំសម្រេចចិត្តសរសេរសារអេឡិចត្រូនិចនេះផ្ញើទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកដែលធ្វើការទំនាក់ទំនងជាមួយនឹងការស្រាវជ្រាវរកបងប្អូនដែលបាត់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម ដើម្បីស៊ើបរកព័ត៌មានបន្ថែមទៀត ដោយខ្ញុំបានភ្ជាប់មកជាមួយនូវរូបថតពូរបស់ខ្ញុំ។ ខាងក្រោមនេះជាសារឆ្លើយឆ្លងរបស់ខ្ញុំជាមួយ សោម ប៊ុនថន បុគ្គលិកទស្សនាវដ្តីស្វែងរក ការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ៖

## ១) ជូនចំពោះលោក-លោកស្រី

លោកតា លោកយាយ និងឪពុកម្តាយរបស់ខ្ញុំ បានរត់ភៀសខ្លួនចេញពីប្រទេសកម្ពុជាក្នុងកំឡុងពេលដែលរបបខ្មែរក្រហមបានទទួលជ័យជម្នះ និងចូលមកដល់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥។ ថ្ងៃមួយនៅពេលដែលកងយោធាខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ហើយបង្ខំឲ្យប្រជាជនចាកចេញទៅកាន់ជនបទ យាយតារបស់ខ្ញុំបានវង្វេងបាត់កូនរបស់គាត់ម្នាក់ដែលត្រូវជាពូរបស់ខ្ញុំ។ ថ្វីត្បិតតែសព្វថ្ងៃនេះ ក្រុមគ្រួសាររបស់ខ្ញុំកំពុងតែរស់នៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំង ប៉ុន្តែក្រុមគ្រួសាររបស់ខ្ញុំនៅតែមានក្តីសង្ឃឹមថានឹងបានជួបពូរបស់ខ្ញុំនៅថ្ងៃណាមួយ។ តើអ្នកអាចប្រាប់ខ្ញុំបានទេថា តើកាកបាទក្រហមនឹងអាចជួយក្រុមគ្រួសាររបស់ខ្ញុំក្នុងការស្វែងរកពូរបស់ខ្ញុំនៅក្នុងខណៈពេលនេះបានដែរឬទេ? យើងនៅមានសេសសល់រូបថតរបស់គាត់មួយសន្លឹក។

យើងក៏មានគម្រោងត្រឡប់ទៅប្រទេសកម្ពុជានៅក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ខាងមុខនេះដែរ។ នេះគឺជាលើកដំបូងបង្អស់ដែលជីតារបស់ខ្ញុំនឹងត្រឡប់ទៅទីក្រុងភ្នំពេញ ចាប់តាំងពីគាត់ត្រូវបានបង្ខំឲ្យចាកចេញនៅថ្ងៃនោះ។ ខ្ញុំពិតជាអរគុណណាស់សម្រាប់ការជួយរបស់អ្នក ហើយក៏ទន្ទឹងរង់ចាំស្តាប់ដំណឹងពីអ្នកវិញដែរ។

ពីខ្ញុំ

ម៉ូនីកា ត្រាន

## ២) ជូនចំពោះលោក សោម ប៊ុនថន

ខ្ញុំពិតជាអរគុណណាស់ សម្រាប់ការឆ្លើយតបលោកមកកាន់ខ្ញុំវិញ។ ខ្ញុំសូមទោសចំពោះការពន្យាពេលក្នុងការឆ្លើយតបទៅលោក ព្រោះក្នុងកំឡុងពេលនេះ ខ្ញុំកំពុងតែខិតខំស្វែងរកប្រភពព័ត៌មានផ្សេងៗ ពីសមាជិកគ្រួសាររបស់ខ្ញុំដើម្បីប្រមូលទិន្នន័យឲ្យបានគ្រប់គ្រាន់ប៉ុន្តែគួរឲ្យសោកស្តាយខ្ញុំមិនអាចទទួលបានព័ត៌មានច្រើនប៉ុន្មានទេ។

ពូរបស់ខ្ញុំកើតនៅក្នុងឆ្នាំ១៩៥៨ នៅក្នុងប្រទេសកម្ពុជាដូច្នេះគាត់មានអាយុ១៧ឆ្នាំក្នុងអំឡុងឆ្នាំ១៩៧៥។ ឪពុករបស់ពូខ្ញុំ (ត្រូវជាជីតារបស់ខ្ញុំ) បានចាកចេញពីប្រទេសកម្ពុជានៅមុនឆ្នាំ១៩៧៥ ព្រោះគាត់គឺជាចុងភៅនៅលើកប៉ាល់ប្រចាំនៅតំបន់អាស៊ីអាគ្នេយ៍។ ចំណែកឯម្តាយរបស់ពូខ្ញុំវិញ (ត្រូវជាយាយរបស់ខ្ញុំ) គឺជាមេផ្ទះ និងចិញ្ចឹមបីបាច់កូនរបស់គាត់ចំនួន៨នាក់។ គ្រួសាររបស់ខ្ញុំគឺមានដើមកំណើតមកពីប្រទេសចិន។ គ្រួសារខ្ញុំធ្លាប់បានរស់នៅម្តុំផ្សារដើមគរ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ សាច់ញាតិរបស់ខ្ញុំបានប្រាប់ខ្ញុំថា គាត់ធ្លាប់បានរស់នៅក្នុងផ្ទះមួយទល់មុខព្រះវិហារ និងនៅក្បែរផ្លូវមួយដែលមានឈ្មោះថា ផ្លូវម៉ៅសេទុង ដែលនៅទីនោះមានរោងកុនមួយឈ្មោះមនោរម្យ។

ទាំងនេះគឺជាព័ត៌មានមួយចំនួនដែលខ្ញុំមាន ប៉ុន្តែ វាប្រហែលជាមិនគ្រប់គ្រាន់ទេ។ ក្រៅពីព័ត៌មានទាំងនេះ ខ្ញុំមានរូបថតមួយសន្លឹករបស់ពូខ្ញុំនៅពេលដែលគាត់មានអាយុប្រហែល១៧ឆ្នាំ។

តើអ្នកមានទិន្នន័យព័ត៌មានណាដែលទាក់ទងទៅនឹងការស្វែងរកសាច់ញាតិរបស់ប្រជាជនផ្សេងទៀតដែរឬទេ?

សូមអរគុណ!

ម៉ូនីកា

### ៣) ជូនចំពោះលោក សោម ប៊ុនថន

លោកនឹងឃើញរូបថតពូរបស់ខ្ញុំ ដែលខ្ញុំបានភ្ជាប់ជាមួយសារអេឡិចត្រូនិចផ្ញើទៅកាន់អ្នក។ ពូរបស់ខ្ញុំឈរនៅខាងស្តាំដៃ និងពាក់អាវយឺតពណ៌ស។



ពូរបស់ខ្ញុំ ចាន់ វើងមាក អាយុ១៧ឆ្នាំ ក្នុងឆ្នាំ១៩៧៥ ឈរនៅខាងស្តាំដៃ និងពាក់អាវយឺតពណ៌ស។

ដោយសារតែយើងមានដើមកំណើតមកពីប្រទេសចិន ដូច្នេះឈ្មោះពូរបស់ខ្ញុំបកប្រែពីភាសាចិនទៅជាអង់គ្លេសថា ចាន់ វើងមាក។ តើមានប្រជាជនផ្សេងទៀតដែរឬទេនៅក្នុងប្រទេសកម្ពុជា ដែលបានបន្តស្វែងរកសាច់ញាតិដែលបានបាត់ខ្លួន? តើអ្នកអាចប្រាប់ខ្ញុំបានទេថា ខ្ញុំគួរតែធ្វើដូចម្តេចដើម្បីស្វែងរកពូរបស់ខ្ញុំឃើញ? ខ្ញុំបានស្វែងរកមើលក្នុងប្រព័ន្ធទិន្នន័យដែលអ្នកបានផ្ញើទៅឲ្យខ្ញុំរួចអស់ហើយ ដោយខ្ញុំបានស្រាវជ្រាវរកឈ្មោះពូរបស់ខ្ញុំចាប់ផ្តើមពីអក្សរស៊ី «C» ប៉ុន្តែខ្ញុំមិនអាចស្វែងរកព័ត៌មានដែលបានរៀបរាប់ពីឈ្មោះពូរបស់ខ្ញុំឃើញទេ។ ដោយសារតែយើងនឹងត្រឡប់ទៅប្រទេសកម្ពុជា នៅខែកុម្ភៈ ឆ្នាំ២០១៩ ខាងមុខនេះ ដូច្នេះយើងពិតជាចាប់អារម្មណ៍ខ្លាំងណាស់ ចំពោះការទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

ដោយក្តីគោរព!

ម៉ូនីកា ត្រាន

### ៤) ជូនចំពោះលោក សោម ប៊ុនថន

ខ្ញុំទើបតែបានទទួលឈ្មោះទីកន្លែង ដែលគ្រួសាររបស់ខ្ញុំធ្លាប់បានរស់នៅជាភាសាខ្មែរគឺ «ផ្សារដើមគរ» ដូចដែលខ្ញុំបានភ្ជាប់មកជាមួយ។ ប្រសិនបើអាច តើលោកអាចផ្ញើឲ្យខ្ញុំនូវកាសែតមួយច្បាប់ បន្ទាប់ពីលោកបានចុះផ្សាយអំពីដំណឹងស្វែងរកពូរបស់ខ្ញុំបានដែរឬទេ? វាកាន់តែប្រសើរ ប្រសិនបើលោកអាចបោះពុម្ពផ្សាយរូបថតក្រុមគ្រួសាររបស់ខ្ញុំនៅលើទំព័រកាសែតនោះ ព្រោះវាប្រហែលជាមានសារប្រយោជន៍កាន់តែច្រើនក្នុងការស្វែងរកដំណឹងពូរបស់ខ្ញុំ។

ខ្ញុំទន្ទឹងរង់ចាំជួបលោកដោយផ្ទាល់។

សូមរក្សាទំនាក់ទំនងនេះ

សូមឲ្យជួបតែសំណាងល្អ!

ម៉ូនីកា

**ម៉ូនីកា ត្រាន**

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ុន សុដាវី
វិទ្យាស្ថានស្ទីករីត, ខែកុម្ភៈ ឆ្នាំ២០១៥

(តពីលេខមុន)

| ល.រ | លេខកូដ | ឈ្មោះ ជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| 141 | 7993 | Unknown | មិនដឹងឈ្មោះ | ? | ? | ? | 93 |
| ១៤២ | ៧៩៩៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៩០ |
| ១៤៣ | ៧៩៩៨ | Ba Vanntha | ប វ៉ាន់ថា | ? | ? | ? | ៩៣ |
| ១៤៤ | ៨០០៤ | Mam Te(m) | ម៉ម តែ(ម) | ប្រុស | ? | ០៤/១០/១៩៨២ | ៩៣ |
| ១៤៥ | ៨០០២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៩៣ |
| ១៤៦ | ៨០០៦ | Ra Yeng | រ៉ា យ៉េង | ? | ? | ? | ៩៣ |
| ១៤៧ | ៨០១០ | Kim Ry | គីម រី | ស្រី | ? | ១៧/០៧/១៩៩២ | ៩៥ |
| ១៤៨ | ៨០១១ | Mao Rann | ម៉ៅ រ៉ាន់ | ? | ? | ? | ៩៦ |
| ១៤៩ | ៨០១៥ | Nguyen Thi Ngoc | ង្វៀង ធីង៉ុក | ? | ? | ? | ៩៦ |
| ១៥០ | ៨០២៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៩៦ |
| ១៥១ | ៨០២៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៩៩ |
| ១៥២ | ៨០២៣ | Say Khon | សាយ ខុន | ស្រី | ? | ? | ៩៦ |
| ១៥៣ | ៨០៤៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៩៩ |
| ១៥៤ | ៨០៤៧ | Kreng Siek | ក្រេង សៀក | ? | ? | ? | ៩៩ |
| ១៥៥ | ៨០៥១ | But Samrong | ប៊ុត សំរ៉ុង | ? | ? | ? | ៩៩ |
| ១៥៦ | ៨០៥២ | Unreadable | មើលមិនច្បាស់ | ? | ? | ? | ៩៩ |
| ១៥៧ | ៨០៥៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៩ |
| ១៥៨ | ៨០៥៨ | Chheav Sophat | ឈាវ សុផាត | ? | ? | ? | ១០២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៥៩ | ៨០៦០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០២ |
| ១៦០ | ៨០៦៣ | Prak Kan | ប្រាក់ កន | ? | ? | ១៣/០៧/១៩៨២ | ១០២ |
| ១៦១ | ៨០៦៦ | Chheang Leng | ឈាង ឡេង | ប្រុស | ? | ១១/០៧/១៩៨៩ | ១០២ |
| ១៦២ | ៨០៦៧ | Kong Lan | គង់ ឡន | ? | ? | ? | ១០២ |
| ១៦៣ | ៨០៧១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៦៤ | ៨០៧២ | ? Sem | ? សែម | ? | ? | ២១/១០/១៩៨-? | |
| ១៦៥ | ៨០៧៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៦៦ | ៨០៨១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៦៧ | ៨០៨២ | Te Sarin (Female child) | កុមារី តិ សារីន | ស្រី | ? | ០៨/១០/១៩៨៧ | |
| ១៦៨ | ៨០៨៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៦៩ | ៨០៨៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៧០ | ៨០៩០ | Lornn? | លន់? | ? | ? | ១០/០៩/១៩៩២ | |
| ១៧១ | ៨០៩៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៦ |
| ១៧២ | ៨០៩៧ | Hang Kal | ហង្ស កល | ប្រុស | ? | ? | |
| ១៧៣ | ៨០៩៩ | Im Reaksmey | អ៊ឹម រស្មី | ? | ? | ? | |
| ១៧៤ | ៨១០៤ | Nou Sambath (Male child) | កុមារា នូ សម្បត្តិ | ? | ? | ? | |
| ១៧៥ | ៨១០៧ | York Lam | យក់ ឡាំម | ស្រី | ? | ១៦/០១/១៩៨៤ | |
| ១៧៦ | ៨១១០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៧៧ | ៨១១១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៧៨ | ៨១១៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៧៩ | ៨១៣១ | Ing Luong | អ៊ឹង លួង | ប្រុស | ៥៨ ឆ្នាំ | ១១/០១/១៩៨៩ | |
| ១៨០ | ៨១៣២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១៨១ | ៨១៣៩ | Pech Bandet | ពេជ្ជ បណ្ឌិត | ? | ? | ? | ១១៥ |
| ១៨២ | ៨១៨២ | Yeay Yin Cheu | យាយ យិន ជឺ | ? | ? | ? | ១១៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៨៣ | ៨១៤៥ | Bun Ly | ប៊ុន លី | ស្រី | ? | ១០/០២/១៩៨៦ | ១១៥ |
| ១៨៤ | ៨១៤៩ | Hin Sophan | ហ៊ិន សុផាន | ? | ? | ? | ១១៥ |
| ១៨៥ | ៨១៥៣ | Sok Penh | សុខ ពេញ | ប្រុស | ៥៨ ឆ្នាំ | ? | ១១៥ |
| ១៨៦ | ៨១៥៦ | Kal Thay | កល់ ថៃ | ? | ? | ១១/០១/១៩៨៤ | ១១៥ |
| ១៨៧ | ៨១៥៩ | Lang | ឡាង | ស្រី | ៧១ ឆ្នាំ | ០៨/០៩/១៩៩២ | ១១៩ |
| ១៨៨ | ៨១៥៦ | Matt Ken | ម៉ាត់ កេន | ស្រី | ? | ? | ១១៦ |
| ១៨៩ | ៨១៦២ | Del Sitha | ដែល ស៊ីថា | ? | ? | ? | ១១៩ |
| ១៩០ | ៨១៨៦ | Ta Sruy | តា ស្រ៊ុយ | ប្រុស | ៦៣ ឆ្នាំ | ២៦/១១/១៩៨៨ | ១២០ |
| ១៩១ | ៨១៨៩ | Makk Sot | ម៉ក់ សុទ | ? | ? | ២០/០៥/១៩៨៧ | ១២០ |
| ១៩២ | ៨១៩១ | Nguon Nakry | ងួន ណាគ្រី | ? | ? | ០៤/០២/១៩៨៦ | ១២០ |
| ១៩៣ | ៨១៩៣ | Pech Pheavin | ពេជ្រ ភាវីន | ? | ? | ? | ១២០ |
| ១៩៤ | ៨១៩៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១២០ |
| ១៩៥ | ៨២០១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១២៣ |
| ១៩៦ | ៨២០៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១២៣ |
| ១៩៧ | ៨២០៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១២៣ |
| ១៩៨ | ៨២០៨ | Sy Hao | ស៊ី ហោ | ? | ៣២ ឆ្នាំ | ? | ១២៤ |
| ១៩៩ | ៨២១១ | Phok Channara | ភោគ ចន្ទណារ៉ា | ? | ? | ? | ១២៤ |
| ២០០ | ៨២១២ | Duong Kinoeun | ឌួង គិនឿន | ? | ? | ០៥/០៣/១៩៩៤ | ១២៤ |
| ២០១ | ៨២១៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ២០២ | ៨២២០ | Me Aoyim | ម៉ែ អោយិម | ? | ? | ? | ១២៤ |
| ២០៣ | ៨២២៣ | Mao Loeng | ម៉ៅ ឡឹង | ប្រុស | ? | ? | ១២៩ |
| ២០៤ | ៨២២៦ | Bach Peikork | បាច ប៉ីគក | ? | ? | ? | ១២៩ |
| ២០៥ | ៨២២៧ | Vann Van | វ៉ាន់ វ៉ាន | ? | ៥៣ ឆ្នាំ | ១៦/១១/១៩៨៧ | ១២៩ |
| ២០៦ | ៨២២៩ | Khiev Vey | ខៀវ វៃ | ? | ? | ? | ១២៩ |
| ២០៧ | ៨២៣២ | Sun Sophay | ស៊ុន សុផៃ | ? | ? | ? | ១៣០ |

(នៅមានត)

# ដំណឹងស្វែងរកឪពុក

នាងខ្ញុំឈ្មោះ ស៊ូ បូរ៉ាមី ភេទស្រី អាយុ៥១ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិ៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។ នាងខ្ញុំជាកូនច្បងនៅក្នុងគ្រួសារ ដែលមានបងប្អូនបង្កើតចំនួន៣នាក់៖ ទី១) នាងខ្ញុំ,ទី២) ស៊ូ ពេជ្រ (ភេទប្រុស),ទី៣) ស៊ូ សុធារី (ភេទស្រី) និង ទី៤) ស៊ូ ស្រីល័ក្ខ (ភេទស្រី)។ នាងខ្ញុំមានម្តាយឈ្មោះ អោម ណារី និងឪពុកឈ្មោះ ស៊ូ ណៃម។

នាងខ្ញុំសូមប្រកាសរកឪពុកឈ្មោះ ស៊ូ ណៃម។ នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ស្ពឺ។ នៅទីនោះមិនបានប៉ុន្មានខែផង ខ្មែរក្រហមក៏បានជម្លៀសគ្រួសារនាងខ្ញុំ ទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅឆ្នាំ១៩៧៦ ឪពុករបស់នាងខ្ញុំត្រូវបានខ្មែរ-ក្រហម ហៅទៅរៀនសូត្រនៅផ្សារមួយក្នុងឃុំព្រះនេត្រព្រះ បន្ទាប់មកខ្មែរក្រហមបានយកគាត់ដាក់នៅវត្តព្រះនេត្រព្រះ ជាមួយឈ្មោះ ម៉ែន ហឿន ដែលជាមិត្តភក្តិជិតស្និទ្ធរបស់គាត់ និងអ្នកដែលមានចំណេះដឹងប្រមាណ ៥០នាក់ទៀត។

ក្រោយរបបខ្មែរក្រហមបានដួលរលំ ម្តាយនាងខ្ញុំបានជួបជាមួយអ្នកធ្លាប់ធ្វើម្ហូប និងដាំបាយនៅគុកទួលស្លែង ដែលផ្ទះរបស់គាត់នៅជាប់ជាមួយផ្ទះរបស់ខ្ញុំកាលពីសង្គមចាស់។ គាត់បានប្រាប់ម្តាយខ្ញុំថា គាត់បានឃើញខ្មែរក្រហមដឹកឪពុករបស់ខ្ញុំ ចូលទៅគុកទួលស្លែងយ៉ាងច្បាស់ផ្ទាល់ភ្នែក។ ទោះបីជាយ៉ាងនេះក្តី នាងខ្ញុំបានខិតខំស្វែងរករូបថត និងចម្លើយសារភាពរបស់ឪពុកខ្ញុំ តែរកមិនឃើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ ឬធ្លាប់ឮឈ្មោះ ឪពុកនាងខ្ញុំឈ្មោះ ស៊ូ ណៃម សូមមេត្តាទំនាក់ទំនងតាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរសព្ទលេខ៖ ០២៣ ២១៨ ០ ០៩ ឬ ០១២ ៩៩៦ ៧៥០ និងសារអេឡិចត្រូនិច៖ truthbunthorn.s@dccam.org។

**សូមអរគុណ!**



ស៊ូ បូរ៉ាមី បច្ចុប្បន្នជាគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ



ឪពុកម្តាយ និងប្អូនប្រុសរបស់ បូរ៉ាមី



ភ្នំពេញថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨
រូបដើរលើកដៃជួរខាងមុខនៅខាងស្តាំ ៖ ប៉ុល ពត នាយករដ្ឋមន្ត្រី និងជាលេខាបក្ស កុម្មុយនីស្តកម្ពុជា
រូបដើរលើកដៃជួរខាងមុខនៅខាងឆ្វេង ៖ វ៉ាង តុងស៊ិន អនុប្រធានគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន
រូបនៅពីក្រោយ វ៉ាង តុងស៊ិន ៖ ហ៊ូ យ៉ាបាង អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន
រូបនៅពីក្រោយ ប៉ុល ពត ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 228, December 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.